**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# មោឃភាព និងការលុបចោល នៅក្នុងកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ៖ **ខួន ថេង** | លោកស្រី **ម៉ូលី បញ្ញា** |
| **ជុំ សុភក្តី** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា | ២០១៤ |
| ជំនាន់ទី ១៨ | | ឆ្នាំសរសេរសារណា | ២០១៨ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ខួន ថេង** និងខ្ញុំបាទឈ្មោះ **ជុំ សុភក្តី** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៤-២០១៨ បានសរសេរសារណា នៅក្នុងគោលបំណងដើម្បីការពារបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី **“មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា”**។

ជាដំបូងយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណលំអោនកាយវាចាចិត្ត និងសម្តែងនូវមហាកតញ្ញូតាធមិដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក **ខួន ឃាង** និងអ្នកម្តាយ **ស៊ូ ចន្ធី**
- លោកឪពុក **ជុំ សុខុម** និងអ្នកម្តាយ **ស៊ឹម សោភា**

លោកអ្នកមានគុណបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅណែនាំ ផ្តល់ដំបូន្មាន និងផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាង ទាំងកំលាំងកាយ និងកំលាំងចិត្ត ទាំងផ្នែកស្មារតី ក៏ដូចជាផ្នែកសម្ភារៈ តាំងពីតូចក្រូចឆ្មា រហូតដល់ធំដឹងក្តី ដោយមិនខ្លាចឡើយភាពនឿយហត់ ដើម្បីឲ្យកូនបានទទួលការអប់រំមួយដែលសមរម្យរហូតមកដល់សព្វថ្ងៃនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ***ឯកឧត្តមសាកលវិទ្យាធិការ សាកវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់*** ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវចំណេះដឹងយ៉ាងច្រើនមកឲ្យយើងខ្ញុំក្នុងរយៈពេល ៤(បួន)ឆ្នាំ កន្លងមកនេះ ជាពិសេសពួកយើងក៏ទទួលបាននូវការតម្រង់ទិសពីសំណាក់លោកគ្រូ អ្នកគ្រូដែលធ្វើឲ្យពួកខ្ញុំបានក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកគ្រូសាស្ត្រាចារ្យ **ប៉ូលី បញ្ញា** ដែលជាសាស្ត្រាចារ្យណែនាំ ក្នុងការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។ អ្នកគ្រូបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ តម្រង់ទិស ផ្តល់នូវឯកសារពាក់ព័ន្ធ ក៏ដូចជាអនុសាសន៍ល្អៗ និងជួយកែលម្អនូវចំណុចខ្វះខាតទាំងឡាយដើម្បីឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យសិរិបវរជូនដល់ *លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងមិត្តរួមជំនាន់* ទាំងអស់សូមប្រកបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានជ្រើសរើសប្រធានបទមួយមកធ្វើការស្រាវជ្រាវ សម្រាប់ការសរសេរសារណាបញ្ចប់ការសិក្សា ស្ដីអំពី **"មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា"**។

សារណាអំពី មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា ត្រូវបានតាក់តែងឡើងក្នុងគោលដៅសិក្សាអំពីដំណើរនៃការបង្កើតកិច្ចសន្យា និងការបំពានកិច្ចសន្យា ឬ ការបំពានលក្ខខណ្ឌសុពលភាព ដែលជាលក្ខខណ្ឌកំណត់អានុភាពនៃកិច្ចសន្យាដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ ជាទូទៅ សុពលភាពនៃកិច្ចសន្យាមានគោលដៅកំណត់សុវត្ថិភាពមិនចំពោះសម្រាប់តែគូភាគីនៃកិច្ចសន្យាប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដ៏ទៃទៀត និងថែមទាំងជួយរៀបចំសណ្ដាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ និងការពារសុចរិតភាព និងភាពស្មោះត្រង់ផងដែរ។ ការសិក្សាអំពីប្រធានបទនេះ បានដកស្រង់ និងសរសេរជាសៀវភៅនេះឡើង ដើម្បីធ្វើការពិពណ៌នាអំពីទិដ្ឋភាពគតិយុត្ត និងបញ្ហាប្រឈមជុំវិញការអនុវត្តជាក់ស្ដែងនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យា ពិសេសគឺពាក់ព័ន្ធទៅនឹងមោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា។

កិច្ចការស្រាវជ្រាវដែលលោកអ្នកកំពុងតែអាននេះ គឺជាលទ្ធផលដែលបានកើតចេញមកពីការសិក្សារៀនសូត្ររបស់យើងខ្ញុំទាំងពីរអ្នកអស់រយៈពេលជិត ៤(បួន)ឆ្នាំ នៅសាកលវិទ្យាល័យ និងនៅតាមវគ្គបណ្ដុះបណ្ដាលនានា ក៏ដូចជាតាមរយៈការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតក្នុងការស្រាវជ្រាវផងដែរ។ សារណានេះ វានឹងអាចក្លាយជាឯកសារមួយនៅក្នុងការជំនួយស្មារតី និងការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតជំនាន់ក្រោយៗ ដែលនឹងសិក្សាស្រាវជ្រាវបន្តដែលទាក់ទងនឹងប្រធានបទមួយនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការសរសេរ ការស្រាវជ្រាវ ក៏ដូចជាការប្រមូលនូវពត៌មានរួមទាំងការពិនិត្យពិច័យកិច្ចការស្រាវជ្រាវនេះ នៅតែមិនអាចឥតខ្ចោះចន្លោះ ដោយសារតែពួកខ្ញុំជានិស្សិតដែលមិនធ្លាប់មានបទពិសោធន៍នៅក្នុងការស្រាវជ្រាវបង្កើតជាឯកសារ ដែលមានលក្ខណៈជាផ្លូវការ និងមានវិជ្ជាជីវៈពីមុនមកទេ ស្របពេលដែលចំណេះដឹងដែលពួកខ្ញុំមាន ក៏មិនទាន់មានភាពគ្រប់គ្រាន់នៅក្នុងការធ្វើឲ្យសារណានេះមានភាពក្បោះក្បាយ តែទោះជាយ៉ាងណា យើងខ្ញុំសង្ឃឹមថា ស្នាដៃនេះក៏អាចយកជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត។ ដោយសារពេលវេលាក្នុងការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត ហេតុនេះ យើងខ្ញុំនឹងរង់ចាំនូវការរិះគន់ការកែលម្អរ ក្នុងន័យស្ថាបនា ពីសំណាក់មិត្តអ្នកអាន អ្នកត្រួតពិនិត្យទាំងអស់គ្នានូវរាល់ចំណុចខ្វះខាត ដើម្បីធ្វើឲ្យសារណារបស់យើងខ្ញុំកាន់តែល្អប្រសើរ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១ ៖ សញ្ញាណទូទៅអំពីមោឃភាព និងការលុបចោល** ........ ៦

**ផ្នែកទី១. សញ្ញាណទូទៅអំពីការមោឃភាព** ........ ៧

**កថាខណ្ឌទី១. មូលហេតុដែលនាំឲ្យមោឃភាព** ........ ៨

**ក. ខ្លឹមសារនៃកិច្ចសន្យា** ........ ៨

១. ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ........ ៨

២. ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ........ ៩

**ខ. មូលហេតុទាក់ទងនឹងលក្ខខណ្ឌទម្រង់ដែលទាមទារ** ........ ៩

**គ. ករណីផ្សេងទៀតដែលបញ្ញត្តិថាមោឃៈ** ........ ១០

១. ករណីការបង្ហាញឆន្ទៈមិនពិត ........ ១០

២. អលទ្ធភាពតាំងពីដំបូង ........ ១១

**កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការមោឃភាព** ........ ១១

**ក. ករណីមោឃភាពទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចសន្យា** ........ ១១

**ខ. ករណីមោឃភាពទាក់ទងទៅនឹងលក្ខខណ្ឌទម្រង់ដែលទាមទារ** ........ ១២

**គ. ករណីការបង្ហាញឆន្ទៈមិនពិត** ........ ១២

**កថាខណ្ឌទី៣. វិធីនៃការមោឃភាព** ........ ១២

**ក. វិធីតាមក្រៅផ្លូវតុលាការ** ........ ១៣

**ខ. វិធីតាមផ្លូវតុលាការ** ........ ១៣

**ផ្នែកទី២. សញ្ញាណទូទៅអំពីការលុបចោល** ........ ១៤

**កថាខណ្ឌទី១. មូលហេតុដែលនាំឲ្យមានការលុបចោល** ..................... ១៤
**ក. ជនខ្វះសមត្ថភាព** ..................... ១៤
១. ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ..................... ១៥
១.១. អនីតិជន ..................... ១៦
១.២. ជនក្រោមអាណាព្យាបាលទូទៅ ..................... ១៦
១.៣. ជនក្រោមហិតូបត្ថម្ភ ..................... ១៧
២. ជនខ្វះសមត្ថភាពខាងឆន្ទៈ ..................... ១៧
**ខ. វិការៈនៃការបង្ហាញឆន្ទៈ** ..................... ១៨
១. ការភាន់ច្រលំ ..................... ១៨
១.១. ការភាន់ច្រលំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ..................... ១៨
១.២. ការភាន់ច្រលំអំពីចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ឬ ចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា ..................... ១៩
១.៣. ការភាន់ច្រលំដោយភាគីទាំងសងខាង ..................... ២០
២. ការឆបោក ..................... ២០
២.១. ករណីឆបោកដោយភាគីម្ខាងទៀត ..................... ២១
២.២. ការឆបោកដោយតតិយជន ..................... ២១
៣. ពត៌មានមិនពិត ..................... ២២
៤. ការរំលោភលើស្ថានភាព ..................... ២៣
៥. ការគម្រាមកំហែង ..................... ២៣
៦. អំពើកេងចំណេញហួសហេតុ ..................... ២៤
៧. បបនីយផ្លូវចិត្ត ..................... ២៥

កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការលុបចោល ........ ២៦
ក. ករណីមូលហេតុជនខ្វះសមត្ថភាព ........ ២៦
ខ. ករណីវិការៈនៃការបញ្ចេញឆន្ទៈ ........ ២៧
កថាខណ្ឌទី៣. វិធីនៃការលុបចោល ........ ២៧
ក. វិធីលុបចោលតាមក្រៅផ្លូវតុលាការ ........ ២៧
ខ. វិធីនៃការលុបចោលតាមផ្លូវតុលាការ ........ ២៨
ផ្នែកទី៣. ប្រៀបធៀបសញ្ញាណទូទៅនៃការមោឃភាព និងការលុបចោល ........ ២៨
កថាខណ្ឌទី១. លក្ខណៈវិនិច្ឆ័យនៃការមោឃភាព និងការលុបចោល ........ ២៨
ក. លក្ខណៈវិនិច្ឆ័យនៃការមោឃភាព ........ ២៨
ខ. លក្ខណៈវិនិច្ឆ័យនៃការលុបចោល ........ ២៩
កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការមោឃភាព និងការលុបចោល ........ ២៩
កថាខណ្ឌទី៣. វិធីនៃមោឃភាព និងការលុបចោល ........ ៣០
ជំពូកទី២ ៖ អត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលនៃកិច្ចសន្យា ........ ៣១
ផ្នែកទី១. ការសិក្សានៅក្នុងដំណាក់កាលមុនកិច្ចសន្យាបានបង្កើត ........ ៣១
កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលមុនកិច្ចសន្យាបានបង្កើត ........ ៣២
កថាខណ្ឌទី២. ការលុបចោល និងដំណាក់កាលមុនកិច្ចសន្យា ........ ៣៤
កថាខណ្ឌទី៣. ការប្រៀបធៀបអត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលមុនពេលកិច្ចសន្យា ........ ៣៦
ផ្នែកទី២. ការសិក្សានៅក្នុងដំណាក់បង្កើតកិច្ចសន្យា ........ ៣៧
កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលបង្កើតកិច្ចសន្យា ........ ៣៨

ក. ខ្លឹមសារផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ ..................... ៣៨

ខ. លក្ខខណ្ឌទម្រង់ដែលទាមទារ ..................... ៤០

កថាខណ្ឌទី២. អត្ថិភាពនៃការលុបចោល និងដំណាក់ការបង្កើតកិច្ចសន្យា ..................... ៤២

ក. ជនខ្វះសមត្ថភាព ..................... ៤២

កថាខណ្ឌទី៣. ការប្រៀបធៀបអត្ថិភាពមោឃភាព និងការលុបចោលក្នុងដំណាក់កាលបង្កើតកិច្ចសន្យា ..................... ៤៤

ផ្នែកទី៣. ការសិក្សានៅក្នុងដំណាក់កាលអនុវត្តនៃកិច្ចសន្យា ..................... ៤៥

កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលអនុវត្តកិច្ចសន្យា ..................... ៤៦

ក. ការបង្ហាញឆន្ទៈមិនពិត ..................... ៤៧

កថាខណ្ឌទី២. អត្ថិភាពនៃការលុបចោល និងដំណាក់កាលអនុវត្តកិច្ចសន្យា ..................... ៤៨

ក. ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត និងការចំនេញហួសហេតុ ..................... ៤៨

ខ. ការរំលោភលើស្ថានភាព និងការគម្រាមកំហែង ..................... ៥១

កថាខណ្ឌទី៣. ការប្រៀបធៀបមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា ..................... ៥២

ជំពូកទី៣ ៖ អានុភាពនៃមោឃភាព និងការលុបចោល ..................... ៥៤

ផ្នែកទី១. អានុភាពនៃការមោឃភាព ..................... ៥៤

កថាខណ្ឌទី១.អានុភាពចំពោះភាគីនៃកិច្ចសន្យា ..................... ៥៤

កថាខណ្ឌទី២. អានុភាពចំពោះតតិយជន ..................... ៥៥

ក. ក្នុងករណីមោឃភាពដោយមូលហេតុទាក់ទងនឹងអត្ថន័យ និងលក្ខខណ្ឌទម្រង់នៃកិច្ចសន្យា ..................... ៥៥

ខ. ក្នុងករណីការបង្ហាញឆន្ទៈមិនពិត ..................... ៥៥

ផ្នែកទី២. អានុភាពនៃការលុបចោល ........ ៥៦
កថាខណ្ឌទី១. អានុភាពចំពោះភាគីនៃកិច្ចសន្យា ........ ៥៧
កថាខណ្ឌទី២. អានុភាពចំពោះតតិយជន ........ ៥៧
ក. ការបែងចែកតតិយជននៅពេលមានការលុបចោលកិច្ចសន្យា ........ ៥៨
ខ. ភាពខុសគ្នារវាងតតិយជនមុនការលុបចោល និងក្រោយការលុបចោល ........ ៥៨
គ. វិធីនៃការការពារតតិយជន ........ ៥៩
កថាខណ្ឌទី៣. ការធ្វើបដិទានឡើងវិញ ........ ៦២
ផ្នែកទី៣. ការប្រៀបធៀបអានុភាពនៃការមោឃភាព និងការលុបចោល ........ ៦៤
កថាខណ្ឌទី១. អានុភាពចំពោះភាគីនៃកិច្ចសន្យា ........ ៦៤
កថាខណ្ឌទី២. អានុភាពចំពោះតតិយជន ........ ៦៥
សេចក្តីសន្និដ្ឋាន ........ ៦៧
អនុសាសន៍ ........ ៧០
ឯកសារយោង ........ ៧១
បញ្ជីឧបសម្ព័ន្ធ ........ ៧៣

# សេចក្ដីផ្ដើម

ប្រទេសមួយ ឬរដ្ឋមួយជាក់ច្បាស់ណាស់ថា នឹងអាចដំណើរការទៅបាន គឺដោយសារតែសមាជិកនៃរដ្ឋ ឬប្រជាពលរដ្ឋនៅក្នុងប្រទេសនោះ។ ជាការតបស្នង រដ្ឋមានតួនាទី ជួយការពារ ផ្ដល់ផលប្រយោជន៍ដល់ពួកគាត់វិញ ក៏ប៉ុន្តែមិនមែនមានន័យថា ដោយសារមូលហេតុនេះធ្វើឲ្យមានការលូកដៃចូលជ្រៀតជ្រែកនៅក្នុងទំនាក់ទំនងនៃបុគ្គលឯកជនហួសហេតុពេកនោះទេ។ ទាក់ទងនឹងទិដ្ឋភាពច្បាប់ដែលបានពាក់ព័ន្ធនឹងវិស័យឯកជននេះ យើងឃើញថា បច្ចុប្បន្ននេះមានការរីកចម្រើនតាមរយៈការប្រែប្រួលផ្នែកសេដ្ឋកិច្ច ក៏ដូចជាការរស់នៅប្រចាំថ្ងៃរបស់សង្គម។ ក្នុងការរីកចម្រើននោះដែរ យើងឃើញថា ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្ដីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨ ដែលត្រូវបានយកមកប្រើប្រាស់ពីមុនមក ត្រូវបានជំនួសមកវិញនូវក្រមរដ្ឋប្បវេណី ដែលជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងរវាងរដ្ឋាភិបាលកម្ពុជាសហការជាមួយប្រទេសជប៉ុនតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ហៅកាត់ថា **JICA** ដោយមានការផ្ដួចផ្ដើមក្នុងការចងក្រងច្បាប់នេះតាំងពីឆ្នាំ១៩៩៨ រហូតបានសម្រេច និងត្រូវបានអនុម័តនាថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ ដោយរដ្ឋសភា និងត្រូវបានព្រឹទ្ធសភាផ្ដល់ការយល់ស្របតាមទម្រង់ និងគតិច្បាប់ទាំងស្រុងនាថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលចែកចេញជា ៩គន្ថី និង ១៣០៥មាត្រា។

ប្រសិនបើយើងក្រឡេកមើលមាត្រា ៥៦ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បានចែងថា ***ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ*** នេះបញ្ជាក់ឲ្យឃើញថា ប្រព័ន្ធគតិយុត្តិខ្មែរដែលពាក់ព័ន្ធនឹងរបបសេដ្ឋកិច្ចទីផ្សារ គួរតែប្បីផលិតនូវសមិទ្ធិផលគតិយុត្តដែលផ្ដល់ឲ្យប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិសេរីភាព ក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនសម្រាប់ការជួញដូរប្រកបរបរក្នុងជីវភាពប្រចាំថ្ងៃ។ ហេតុនេះហើយ ទើបវណ្ណកម្មគតិយុត្តមួយថ្មីបានលេចឡើងជារូបរាងគឺ **ក្រមរដ្ឋប្បវេណី** ដែលបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខៈ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។ ត្រង់មាត្រា ៣ នៃក្រមរដ្ឋប្បវេណីនេះផងដែរ បានបង្កើតឲ្យមាន **គោលការស្វ័យភាពនៃបុគ្គលឯកជន** ដោយបានផ្ដល់សិទ្ធិឲ្យប្រជាពលរដ្ឋមានសេរីភាពនៃលក្ខណៈបុគ្គលឯកជនតាមច្បាប់ សេរីភាពក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យកម្មសិទ្ធិ និងសេរីភាពក្នុងការធ្វើកិច្ចសន្យា។ គោលការណ៍នេះ បានបញ្ជាក់អំពីការមិនលូកដៃចូលក្នុងទំនាក់ទំនងឯកជន និង

ឯកជន ពីសំណាក់អាជ្ញាធររដ្ឋ ប្រសិនបើគ្មានការបំពានសិទ្ធិរបស់ភាគីម្ខាងទៀត ដោយភាគីម្ខាងទៀតមិនអាចសុំឲ្យអាជ្ញាធររដ្ឋលូកដៃចូលក្នុងការដោះស្រាយ ដែលនេះបានបង្ហាញពីការឈរលើប្រព័ន្ធអកម្មនៃការដោះស្រាយចំពោះតុលាការ។ ប៉ុន្តែទោះបីជាមាត្រា ៣ នៃក្រមរដ្ឋប្បវេណីខាងលើបានទទួលស្គាល់នូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនក៏ដោយ ក៏មាត្រា ៥ នៃក្រមរដ្ឋប្បវេណីដដែល តម្រូវឲ្យទំនាក់ទំនងឯកជន និងឯកជន ដែលបានបង្កើតឡើងនោះ ត្រូវតែគោរពនូវ **គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់** ផងដែរ។ ករណីមានភាគីណាមួយបានបំពានគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ នោះក្រមរដ្ឋប្បវេណីគឺនឹងដើរតួរក្នុងការការពារផលប្រយោជន៍ដែលខូចខាតតាមរយៈបញ្ញត្តិដែលបានចែងទុក។

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ យើងសង្កេតឃើញថា ប្រជាពលរដ្ឋនៅក្នុងសង្គមខ្មែរបានបង្កើតនូវទំនាក់ទំនងគតិយុត្តតាមរយៈកិច្ចសន្យាស្ទើរតែជាប្រចាំថ្ងៃ និងគ្រប់ទីកន្លែង មិនថា ទីប្រជុំជន និងទីដាច់ស្រយាលឡើយ។ នៅក្នុងន័យនេះហើយបានជាគេថា ប្រជាពលរដ្ឋបានប្រើប្រាស់នូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនច្រើនបំផុត។ ប៉ុន្តែនៅក្នុងការប្រើប្រាស់នេះ ដោយសារតែកត្តាចំណេះដឹង និងកត្តាបទពិសោធន៍នៅក្នុងការរស់នៅមិនមានភាពស្មើរគ្នាទេនោះ វាអាចបង្កើតនូវស្ថានភាពកេងចំណេញហួសហេតុ មានការសម្រេចចិត្តក្នុងការព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យាអមជាមួយនឹងភាពមិនប្រក្រតី ដែលធ្វើឲ្យកិច្ចសន្យាលេចរូបរាងជាសត្យានុម័តរួចហើយ តាមរយៈសំណើ និងស្វីការត្រូវគ្នា ប៉ុន្តែមានបញ្ហាក្នុងការយកទៅអនុវត្ត។ ប្រសិនបើយើងពិនិត្យមើលអំពីទំនាក់ទំនងទូទៅដែលជាការសន្មត់ចំពោះការខុសគ្នារវាងសំណើ និងស្វីការ យើងប្រហែលជាមើលមិនឃើញថា តើកិច្ចសន្យានោះមានភាពមិនប្រក្រតីយ៉ាងណានោះទេ។ ម្យ៉ាងទៀតក៏មានករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដែលភ្ជាប់នូវលក្ខខណ្ឌត្រឹមត្រូវទាំងអស់ ប៉ុន្តែបែរជាតារកាលិកនៃកិច្ចសន្យាមិនអាចយកទៅអនុវត្តដោយហេតុថា វាត្រូវបានច្បាប់ហាមឃាត់ និងនៅក្នុងករណីដែលភាគីម្ខាងត្រូវបានហាមឃាត់សិទ្ធិក្នុងការបង្កើតកិច្ចសន្យា។

ដោយមើលឃើញអំពីបញ្ហាដែលបានលើកឡើងខាងលើនេះ ទើបជំរុញឲ្យពួកខ្ញុំទាំងពីរនាក់មានបំណងធ្វើការស្រាវជ្រាវប្រធានបទអំពី **មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា**។

នៅក្នុងការសិក្សាលើប្រធានបទនេះ យើងខ្ញុំមានគោលបំណងចម្បងដើម្បីសិក្សា និងកំណត់ឲ្យបានច្បាស់នូវលក្ខណៈ ក៏ដូចជាខ្លឹមសារនៃពាក្យថា មោឃភាព និងការលុបចោល ដែលមានចែងនៅក្នុងច្បាប់ និងថា តើទណ្ឌកម្មនៃកិច្ចសន្យាទាំងពីរនេះមានអត្ថិភាពពេលណាខ្លះនៅក្នុងដំណាក់កាលនៃកិច្ចសន្យា។

តាមរយៈការសិក្សាស្រាវជ្រាវលើសារណានេះ យើងខ្ញុំសង្ឃឹមថា ខ្លឹមសារដែលត្រូវបានរំលេចឡើងក្នុងសារណានេះនឹងអាចធ្វើឲ្យអ្នកអនុវត្ត ក៏ដូចជាអ្នកសិក្សាក្នុងវិស័យច្បាប់អាចយល់បានកាន់តែច្បាស់អំពីប្រភេទនៃទណ្ឌកម្មនៃកិច្ចសន្យាដែលបានលើកឡើង និងអាចយកជាមូលដ្ឋានវិនិច្ឆ័យសម្រាប់ប្រើប្រាស់ឲ្យបានច្បាស់លាស់ ជៀសវាងខូចប្រយោជន៍ដោយសារតែការប្រើប្រាស់ខុសពីអ្វីដែលច្បាប់បានការពារ។

ខ្លឹមសារនៃសារណានេះ យើងខ្ញុំសូមបង្ហាញតែអំពី **មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា** ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីថ្មី ដែលប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខៈ នរស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ តែប៉ុណ្ណោះ។

ក្នុងការស្រាវជ្រាវដើម្បីចងក្រងនូវសារណានេះឡើង យើងខ្ញុំពឹងផ្អែកទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ជាមូលដ្ឋាន បន្ថែមពីនេះយើងខ្ញុំបានប្រមូលពត៌មានទាក់ទងទៅនឹងទណ្ឌកម្មនៃកិច្ចសន្យាពីប្រភពផ្សេងៗដូចជា អត្ថបទច្បាប់ អត្ថបទមេរៀននានា សៀវភៅពាក់ព័ន្ធ សេចក្តីសម្រេចតុលាការឯកសារផ្សេងៗ ការសាកសួរសាស្ត្រាចារ្យ និងគ្រូដឹកនាំសារណាដែលមានបទពិសោធន៍។

មុននឹងឈានចូលទៅដល់ការបកស្រាយប្រធានបទ យើងខ្ញុំសូមបង្វិលអារម្មណ៍មិត្តអ្នកអានមកចាប់អារម្មណ៍បន្តិចសិន អំពីទិដ្ឋភាពនៃច្បាប់ដែលទាក់ទងនឹងកិច្ចសន្យាដែលយើងបានអនុវត្តតាំងពីមុន និងទិដ្ឋភាពនៃច្បាប់ដែលយើងកំពុងតែអនុវត្តសព្វថ្ងៃ។ ក្នុងន័យនេះ ច្បាប់ដែលយើងបានអនុវត្តទាក់ទងនឹងកិច្ចសន្យាពីមុនពោលគឺ ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា រីឯច្បាប់ដែលត្រូវបានកំពុងតែប្រើប្រាស់សព្វថ្ងៃនេះគឺ ក្រមរដ្ឋប្បវេណីកម្ពុជា ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៧។ នៅក្នុងអត្ថបទច្បាប់ទាំងពីរ សុទ្ធសឹងតែបានចែងនូវបញ្ញត្តិដែលទាក់ទងនឹងកិច្ចសន្យា ក្នុងនេះយើងសង្កេតឃើញថា មានខ្លឹមសារមួយចំនួននៅតែត្រូវបានកំពុងតែយកមកអនុវត្តមកទល់សព្វថ្ងៃដូចជា លក្ខខណ្ឌសុពលភាពដែលធ្វើឲ្យកិច្ចសន្យាមួយនឹងអាចយកជាការបាន លុះណាតែកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះ កើតចេញពីការព្រមព្រៀងគ្នាដោយឆន្ទៈពិតប្រាកដ និងដោយសេរី មួយវិញទៀត ក៏ទាមទារឲ្យភាគីដែលបង្កើតកិច្ចសន្យា គឺជាជនដែលមានសមត្ថភាពក្នុងការចុះកិច្ចសន្យាផងដែរ ក្រៅពីនេះ ក៏មានលក្ខខណ្ឌមួយទៀតផងដែរដែលទាមទារឲ្យវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា គឺជាវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ។ ចំពោះលក្ខខណ្ឌនេះ យើងក៏ឃើញក្រមរដ្ឋប្បវេណីកម្ពុជាបានចែង និងមានអត្ថន័យស្រដៀងគ្នានេះផងដែរ គ្រាន់តែខុសពាក្យពេចន៍គ្នាតែប៉ុននោះ។ ទន្ទឹមនឹងនេះ ដោយសារតែពីមួយថ្ងៃទៅមួយថ្ងៃសង្គមខ្មែរមានការរីកចម្រើនឥតឈប់ឈរ ដូចនេះហើយ បានជាធ្វើឲ្យទិដ្ឋភាពនៃការប្រើប្រាស់កិច្ចសន្យាក៏មានភាព

ផ្លាស់ប្តូរដែរ ជាហេតុនាំអោយមានវត្តមាននៃក្រមរដ្ឋប្បវេណីក្នុងការចូលរួមគ្រប់គ្រង និងដោះស្រាយទាក់ទងការផ្លាស់ប្តូរដែលក្រឹត្យច្បាប់លេខ ៣៨ នៅខ្វះចន្លោះ និងទាមទារឲ្យមានការផ្លាស់ប្តូរ។

### ក. ការធ្វើអនុប្បទាន ឬលិទ្ធកម្មលើអចលវត្ថុ

ទាក់ទងនឹងលក្ខខណ្ឌសុពលភាពដែលបានលើកឡើងខាងលើ នៅក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ តាមមាត្រា ៣៣៦ វាក្យខណ្ឌ២ បានបញ្ជាក់ថា ទោះបីជាកិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នាក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងបានទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលវត្ថុនឹងមានអានុភាព លុះត្រាតែបានធ្វើជាលិខិតយថាភូត។ ដែលការណ៍នេះ មិនមានបញ្ញត្តិទេនៅក្នុងក្រឹត្យច្បាប់លេខ ៣៨។

### ខ. ការប្រើប្រាស់ពាក្យ "ការលុបចោល"

ក្រៅពីនេះ បើយើងនិយាយអំពី ការប្រើប្រាស់ពាក្យ "ការលុបចោល" ពោលគឺមិនមានពិនិត្យឃើញទេនៅក្នុងក្រឹត្យច្បាប់លេខ ៣៨ ប៉ុន្តែអត្ថន័យនៅក្នុងមាត្រា ៦ នៃក្រឹត្យច្បាប់លេខ ៣៨ ដដែល បានបញ្ញត្តិទាក់ទងនឹងប្រការដែលអាចចាត់ទុកជាមោឃៈថា **"កិច្ចសន្យាអាចចាត់ទុកជាមោឃៈបាន ចំពោះកិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬដោយសេរី និងកិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីបុគ្គលមានសមត្ថភាពចុះកិច្ចសន្យា"** ដែលត្រង់មាត្រានេះមានខ្លឹមសារដូចគ្នានឹងប្រការនៃក្រមរដ្ឋប្បវេណីដែលចាត់ទុកថា ជាលក្ខខណ្ឌនៃការលុបចោល។ ជាមូលហេតុដែលក្រមរដ្ឋប្បវេណីថ្មីបានផ្លាស់ប្តូរមកជាពាក្យ **"ការលុបចោល"** វិញ ព្រោះក្នុងគោលបំណងកុំឲ្យមានការភាន់ច្រឡំនូវពាក្យថា មោឃភាព ដែលមានចែងនៅក្នុងមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណីថ្មីនេះ។

### គ. ការផ្តល់សច្ចានុមតិ

នៅពេលដែលកិច្ចសន្យាមួយបង្កើតឡើងដោយមានមូលហេតុនៃការលុបចោល នោះអ្នកដែលមានសិទ្ធិនៅក្នុងការលុបចោលអាចលុបចោលកិច្ចសន្យាបាន ប៉ុន្តែយោងតាមមាត្រា ៣៦១ អ្នកដែលមានសិទ្ធិលុបចោលនោះ ក៏អាចមានសិទ្ធិក្នុងការលះបង់ការលុបចោល ដោយផ្តល់សច្ចានុមតិផងដែរ។ ក្នុងនោះអ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិលើកិច្ចសន្យានៅក្នុងករណីវិការៈនៃការបង្ហាញឆន្ទៈ ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោលនោះ ឬអាចផ្តល់សច្ចានុមតិលើកិច្ចសន្យានៅក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាព នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវបាន

រលត់។ មួយវិញទៀត យោងតាមមាត្រា ៣៦៣ នៅក្នុងកំឡុងពេល ៣(បី)ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនបានប្រើប្រាស់សិទ្ធិនេះទេ នោះវានឹងត្រូវរលត់។ ដោយឡែកនៅក្នុងក្រឹត្យច្បាប់លេខ ៣៨ មិនមានកំណត់អំពីពាក្យ **ការផ្តល់សច្ចានុមតិ** ប៉ុន្តែតាមរយៈមាត្រា ១៨ និងមាត្រា ២០ នៃក្រឹត្យច្បាប់លេខ ៣៨ នេះដែរក៏មានបញ្ញត្តិនូវបញ្ហាស្រដៀងគ្នានេះដែរ ក្នុងនោះភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការអះអាងអំពីមោឃភាព(ក្នុងក្រមរដ្ឋប្បវេណីប្រើប្រាស់ពាក្យថា ការលុបចោល) ក្រោយពេលឲ្យដំណឹងទៅភាគីម្ខាងទៀត អាចសុំប្តឹងមោឃភាពនៃកិច្ចសន្យានោះ ក្នុងរយៈពេល ១២(ដប់ពីរ)ខែ យ៉ាងយូរ ដោយផ្ទុយមកវិញ សិទ្ធិប្តឹងមោឃភាពនៃកិច្ចសន្យានេះនឹងត្រូវរលត់ បើក្រោយពីពេលប្តឹងសុំឲ្យមានមោឃភាពនោះមក ជនដែលមានសិទ្ធិប្តឹងនេះយល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬសុំឈប់ប្តឹងវិញដោយលាយល័ក្ខអក្សរអំពីមោឃភាពនៃកិច្ចសន្យានោះ។

### ឃ. កម្មវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ

មាត្រា ៥២៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បញ្ញត្តិថា *“វត្ថុ ឬសិទ្ធិទាំងឡាយណា ទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លើកលែងតែ វត្ថុ ឬសិទ្ធិនោះមានលក្ខខណ្ឌមិនអាចធ្វើអនុប្បទាន ឬច្បាប់ហាមឃាត់មិនឲ្យធ្វើអនុប្បទាន”*។ តាមអត្ថន័យនៃមាត្រានេះមានលក្ខខណ្ឌទូលាយ ដែលគ្របដណ្តប់នូវរាល់វត្ថុ ឬសិទ្ធិទាំងអស់សុទ្ធតែអាចយកមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ លើកលែងតែពីរទេ គឺ (១)វត្ថុ ឬសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ឬ (២)ច្បាប់ហាមឃាត់មិនឲ្យធ្វើអនុប្បទាន។ បញ្ញត្តិនេះមានលក្ខណៈផ្ទុយគ្នានឹងបញ្ញត្តិនៃមាត្រា ៣៥ នៃក្រឹត្យច្បាប់លេខ ៣៨ អំពីរការលក់វត្ថុរបស់អ្នកដទៃត្រូវបានចាត់ទុកជាមោឃៈ ប៉ុន្តែតាមក្រមរដ្ឋប្បវេណីថ្មី ការលក់វត្ថុរបស់អ្នកដទៃក្នុងស្ថានភាពនិងកាលៈទេសៈមួយចំនួនក៏មានសុពលភាពដែរ។

# ជំពូកទី ១

# សញ្ញាណទូទៅអំពី
# មោឃភាព
# និងការលុបចោល

# ជំពូកទី១

# សញ្ញាណទូទៅអំពីមោឃភាព និងការលុបចោល

កិច្ចសន្យា[1] គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច។ កិច្ចសន្យាមានអានុភាពដោយសំណើ និងស្វីការត្រូវគ្នា[2] នោះមានន័យថា កិច្ចសន្យាត្រូវបានបង្កើតឡើងហើយ ក៏ប៉ុន្តែដើម្បីឲ្យកិច្ចសន្យាមានសុពលភាព ការបង្កើតកិច្ចសន្យានោះត្រូវគោរពតាមលក្ខខណ្ឌដែលនាំឲ្យកិច្ចសន្យាមានសុពលភាព។ ដើម្បីឲ្យការបង្កើតកិច្ចសន្យាមួយមានសុពលភាពត្រូវគោរពនូវលក្ខខណ្ឌធំៗចំនួន ០២(ពីរ) គឺ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

លក្ខខណ្ឌគ្រឹះមានដូចជា៖

- ការព្រមព្រៀងដោយមានឆន្ទៈពិតប្រាកដ (គ្មានវិការៈនៃការបង្ហាញឆន្ទៈ)
- សមត្ថភាពភាគី
  - មានសមត្ថភាពទទួលបានសិទ្ធិ
  - មានសមត្ថភាពខាងឆន្ទៈ
  - មានសមត្ថភាពក្នុងការធ្វើសកម្មភាព
- កម្មវត្ថុនៃកិច្ចសន្យា ឬ អត្ថន័យនៃកិច្ចសន្យា
  - មិនផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ
  - មិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងសង្គម។

មូលហេតុដែលវាជាលក្ខខណ្ឌគ្រឹះ ពីព្រោះរាល់កិច្ចសន្យាទាំងអស់ពិតណាស់ទាមទារជាដាច់ខាតក្នុងការគោរពនូវបញ្ញត្តិដែលបានបង្ហាញទាំងនេះ។ បើយើងពិចារណាលើលក្ខខណ្ឌខាងលើ លក្ខខណ្ឌនីមួយៗបើសិនជាមិនគោរព នោះកិច្ចសន្យាដែលបានបង្កើតនឹងប៉ះពាល់ដល់គោលការណ៍គ្រឹះនៃក្រមរដ្ឋប្បវេណី ដែលវាគ្របដណ្ដប់ដល់ជីវភាព និងជីវិតបុគ្គលឯកជន។ ឧទាហរណ៍៖ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយការព្រមព្រៀងដោយមានឆន្ទៈមិនពិត នោះវានឹងផ្ទុយនឹងគោលការណ៍ភាពសុចរិត និងភាពស្មោះត្រង់ ដែលជាគោលការណ៍ចំបងមួយដែលមានចែងនៅក្នុង

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣១១

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៦, កថាខណ្ឌទី១

ក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៥។ ដូចនេះហើយ បានជាលក្ខខណ្ឌខាងលើត្រូវបានគេហៅថា ជាលក្ខខណ្ឌគ្រឹះ។

បើទោះបីជាកិច្ចសន្យាមួយបានបង្កើតឡើង ដោយគោរពនូវលក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យាហើយក៏ដោយ ក៏កិច្ចសន្យានោះមិនទាន់មានអានុភាពដែរ ប្រសិនបើមិនបានបំពេញនូវលក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យា។ ជាទូទៅ កិច្ចសន្យាមួយមានសុពលភាពបានដោយគ្រាន់តែមានការព្រមព្រៀងគ្នាដោយផ្ទាល់មាត់តែប៉ុណ្ណោះ ប៉ុន្តែកិច្ចសន្យាមួយចំនួនទៀត ទាមទារឲ្យគោរពនូវលក្ខខណ្ឌទម្រង់ ដែលតម្រូវឲ្យធ្វើជាលាយល័ក្ខណ៍អក្សរ ឬធ្វើជាលិខិតយថាភូត ឬមានការចុះបញ្ជីជាដើម។ នៅពេលដែលកិច្ចសន្យាមួយបានបង្កើតឡើងដោយមិនគោរពនូវលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ក្រមរដ្ឋប្បវេណីបានបញ្ញត្តិឲ្យមានទណ្ឌកម្មចំនួន ០២(ពីរ) ក្នុងការបដិសេធនូវសុពលភាពនៃកិច្ចសន្យានោះ គឺ **(ផ្នែកទី១.)មោឃភាពកិច្ចសន្យា** និង **(ផ្នែកទី២.)ការលុបចោលកិច្ចសន្យា**។

## ផ្នែកទី១. សញ្ញាណទូទៅអំពីការមោឃភាព

មោឃភាព ត្រូវបានផ្តល់និយមន័យខុសៗគ្នា អាស្រ័យទៅតាមកាលៈទេសៈ និងបរិបទនៃការប្រើប្រាស់ គួបផ្សំជាមួយនឹងស្ថានភាពដែលប្រើភ្ជាប់នឹងពាក្យ «មោឃភាព» នោះ។ បើយោងទៅតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ពាក្យថា «មោឃភាព»[3] មានន័យថា ភាពសាបសូន្យ ភាពឥតប្រយោជន៍ ភាពអសារឥតការ ឬ ភាពឥតអំពើជាដើម។ ប៉ុន្តែចំពោះពាក្យ «មោឃភាព» ដែលប្រើប្រាស់ក្នុងន័យច្បាប់ គឺប្រើប្រាស់ទៅលើតែសកម្មភាពគតិយុត្តិដែលរួមមានកិច្ចសន្យា និងសកម្មភាពឯកតោភាគីប៉ុណ្ណោះ។ ក្នុងន័យច្បាប់ «មោឃភាព»[4] ជាទណ្ឌកម្មដែលប្រកាសដោយចៅក្រម លុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្តិទាំងឡាយណាដែលមិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីច្បាប់។ បើយើងក្រឡេកទៅមើលនៅក្នុងក្រឹត្យច្បាប់លេខ ៣៨ វិញ «មោឃភាព» រួមមាន មោឃភាពដាច់ខាត និងមោឃភាពមិនដាច់ខាត។ «មោឃភាពមិនដាច់ខាត» ដែលមានចែងនៅក្នុងក្រឹត្យច្បាប់លេខ ៣៨ នោះ គឺមានលក្ខណៈស្ទើតែដូចគ្នាជាមួយនឹង «ការលុបចោល» ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ រីឯ «មោឃភាពដាច់ខាត» (ក្រឹត្យច្បាប់លេខ ៣៨) វិញ ក៏មានសញ្ញាណ

---

[3] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

[4] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧

ប្រហាក់ប្រហែលជាមួយនឹង «មោឃភាព» ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីផងដែរ។ មោឃភាពនៃកិច្ចសន្យាមានន័យថា កិច្ចសន្យាមួយមិនមានអានុភាពតាំងពីដំបូង។ បានជាគេបង្កើតឲ្យមានមោឃភាពនៃកិច្ចសន្យា ព្រោះដើម្បីកម្រិតនូវសេរីភាពនៃការបង្កើតកិច្ចសន្យាថាមិនមែនធ្វើអ្វីក៏បាននោះទេ នេះជាអញ្ញត្តិកម្មលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន(សេរីភាពនៃការបង្កើតកិច្ចសន្យា)។

## កថាខណ្ឌទី១. មូលហេតុដែលនាំឲ្យមោឃភាព

ក្នុងការបកស្រាយនេះ យើងនឹងលើកយកមូលហេតុដែលនាំឲ្យរងនូវមោឃភាពតែចំនួន ០៣(បី) ប៉ុណ្ណោះ មកធ្វើការអត្ថាធិបាយ ដើម្បីឲ្យមានលក្ខណៈស៊ីជម្រៅ និងសមស្របទៅតាមពេលវេលា គឺមូលហេតុនៃមោឃភាពទាក់ទងនឹង **(ក.)ខ្លឹមសារកិច្ចសន្យា (ខ.)លក្ខខណ្ឌទម្រង់ដែលទាមទារ និង (គ.)ករណីផ្សេងទៀតដែលបញ្ញត្តិថាមោឃៈ**។

### ក. ខ្លឹមសារនៃកិច្ចសន្យា

ខ្លឹមសារនៃកិច្ចសន្យា សំដៅលើអត្ថន័យ ឬលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាដែលបានបង្កើតឡើងនោះ។ កិច្ចសន្យាមួយនឹងរងនូវមោឃភាព ប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិអនុវត្តបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ[5]។

#### ១.ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ កិច្ចសន្យានោះនឹងទទួលរងនូវមោឃភាព។ បញ្ញត្តិអនុវត្តដោយបង្ខំ សំដៅលើបទបញ្ញត្តិច្បាប់ដែលនៅជាធរមានទាំងឡាយណាដែលបង្ខំឲ្យត្រូវតែអនុវត្តតាម បើមិនដូច្នោះទេ ច្បាប់មិនទទួលស្គាល់អានុភាពគតិយុត្តិនៃកិច្ចសន្យានោះទេ[6]។ មានបញ្ញត្តិមួយចំនួនចែងច្បាស់ថា ជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដូចជាកថាខណ្ឌទី៣ នៃមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី ស្តីពីការកម្រិតការប្រាក់ជាដើម ប៉ុន្តែក៏មានបញ្ញត្តិមួយចំនួនមិនបានកំណត់ឲ្យច្បាស់ថា ជាបញ្ញត្តិដែលអនុវត្តដោយបង្ខំផងដែរ។ ហេតុនេះ ចាំបាច់ត្រូវមានការបកស្រាយដោយពិចារណាអំពីគោលគំនិតនៃមាត្រានោះថា ជាបញ្ញត្តិអនុវត្តដោយបង្ខំ ឬមិនមែន។ ជាធម្មតា បញ្ញត្តិអនុវត្តដោយបង្ខំជាបញ្ញត្តិទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ហើយបញ្ញត្តិដែលមិនទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈហៅថា បញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត។

ឧទាហរណ៍៖ -ការហាមបញ្ជាំផ្តាច់ (មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៤ វាក្យខណ្ឌទី១, និងមាត្រា ៣៥៧

-កិច្ចសន្យាការងារលើសម៉ោងកំណត់។

**២.ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ**

ទោះបីជាកិច្ចសន្យានោះ មិនផ្ទុយនឹងបញ្ញត្តិច្បាប់ណាក៏ដោយ ក៏អាចរងនូវមោឃភាពបានដែរ ប្រសិនបើការវាយតម្លៃអំពីអត្ថន័យនៃកិច្ចសន្យានោះ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អក្នុងសង្គម។ ហើយប្រសិនបើច្បាប់ទទួលស្គាល់អានុភាពកិច្ចសន្យាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ នោះវាហាក់បីដូចជាគាំទ្រឲ្យមានស្ថានភាពដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងគាំទ្រឲ្យមានការប៉ះពាល់ដល់ទំនៀមទម្លាប់ល្អក្នុងសង្គមដូច្នោះដែរ។

ឧទាហរណ៍៖ កិច្ចសន្យាព្រមព្រៀងរួមភេទ។ កិច្ចសន្យាប្រភេទនេះ វាធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ យើងសាកស្រមៃគិតថា ប្រសិនបើច្បាប់ទទួលស្គាល់កិច្ចសន្យាប្រភេទនេះ តើទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូផង់របស់ខ្មែរយើងនឹងទៅជាយ៉ាងណា? ហើយសណ្តាប់ធ្នាប់ក្នុងសង្គមទៅជាយ៉ាងណា? ហេតុនេះហើយ ជាការសមហេតុសមផលណាស់ដែលច្បាប់មិនទទួលស្គាល់កិច្ចសន្យាបែបនេះ។

**ខ.មូលហេតុទាក់ទងនឹងលក្ខខណ្ឌទម្រង់ដែលទាមទារ**

ជាគោលការណ៍ អានុភាពនៃកិច្ចសន្យាត្រូវបានបង្កើតឡើងកាលណាមានសំណើ និងស្វីការត្រូវគ្នា។ ប៉ុន្តែកិច្ចសន្យាមួយចំនួនទៀត តម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរ ឬលិខិតយថាភូតទើបកិច្ចសន្យានោះមានអានុភាពតាមផ្លូវច្បាប់ ដោយសារតែពេលខ្លះដើម្បីឲ្យកិច្ចសន្យានោះមានភាពច្បាស់លាស់ ពេលខ្លះទៀតដោយសារតែកម្មវត្ថុនៃកិច្ចសន្យាមានតម្លៃជួញដូរច្រើន ឬការពារកុំឲ្យមានវិវាទ ឬប៉ះពាល់ផលប្រយោជន៍របស់ជនដែលពាក់ព័ន្ធមួយចំនួនទៀត។

ឧទាហរណ៍៖-ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបង្កើតឡើងជាលាយលក្ខណ៍អក្សរ[6]។

-ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតាមការព្រមព្រៀងមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជី[7]។

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៤៥

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៥

**គ.ករណីផ្សេងទៀតដែលបញ្ញត្តិថាមោឃៈ**

ក្រៅពីមូលហេតុទាំងពីរខាងលើ ដែលច្បាប់បានកំណត់ថា ជាមូលហេតុនៃមោឃភាព ក៏នៅមានសកម្មភាព ឬ ទំនាក់ទំនងគតិយុត្តិមួយចំនួន ដែលច្បាប់បានចែងថា កិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមាន **(១.)ករណីការបង្ហាញឆន្ទៈមិនពិត** និង **(២.)ករណីអលទ្ធភាពតាំងពីដំបូង**។

**១.ករណីការបង្ហាញឆន្ទៈមិនពិត**

កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ដែលត្រូវបានធ្វើឡើងដោយការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ[8]។ ការបង្ហាញឆន្ទៈមិនពិត សំដៅលើការបង្ហាញឆន្ទៈខុសពីការពិត ដែលធ្វើឡើងដោយការឃុបឃិតគ្នាជាមួយភាគីម្ខាងទៀត។ ប្រសិនបើធ្វើការប្រៀបធៀបទៅនឹងការបង្ហាញឆន្ទៈមិនពិតក្នុងករណីបបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិតក្នុងករណីបបនីយផ្លូវចិត្ត គឺមានតែភាគីម្ខាងទេដែលដឹងថា ការបង្ហាញឆន្ទៈនោះវាខុសពីការពិត ហើយភាគីនោះនៅតែបង្ហាញឆន្ទៈនោះទៀត។ ចំណែកឯការបង្ហាញឆន្ទៈមិនពិតដែលជាមូលហេតុដែលនាំឲ្យមោឃភាពនេះ គឺការបង្ហាញឆន្ទៈធ្វើឡើងដោយការឃុបឃិតគ្នា ភាគីនៃកិច្ចសន្យាទាំងសងខាងដឹងច្បាស់ណាស់ថា កិច្ចសន្យាដែលខ្លួនធ្វើឡើងនោះវាគ្រាន់តែជាការបំភាន់ភ្នែកអ្នកដទៃតែប៉ុណ្ណោះ។

**លក្ខខណ្ឌះ**

- អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់ខ្លួនដោយដឹងច្បាស់
- អ្នកបង្ហាញឆន្ទៈ និងភាគីម្ខាងទៀតបានឃុបឃិតគ្នាបង្កើតនូវទិដ្ឋភាពមួយខុសពីការពិត

ឧទាហរណ៍៖ X បានលក់ដីរបស់ខ្លួនមួយកន្លែងទៅឲ្យ Y ដើម្បីឲ្យរួចផុតពីការរឹបអូសពីម្ចាស់បំណុល។ ករណីនេះ X និង Y ដឹងច្បាស់ថា ការលក់ដីនេះ គឺគ្រាន់តែចង់រក្សាទ្រព្យសម្បត្តិរបស់ X ឲ្យរួចផុតពីការរឹបអូសតែប៉ុណ្ណោះ។ ករណីនេះ គឺជាការបង្ហាញឆន្ទៈមិនពិត។

ការបង្ហាញឆន្ទៈមិនពិត ថ្វីត្បិតតែវាជាមូលហេតុដែលនាំឲ្យកិច្ចសន្យារងនូវមោឃភាពដែរ តែចរិតលក្ខណៈនៃមោឃភាពដោយមូលហេតុការបង្ហាញឆន្ទៈមិនពិតនេះ គឺមិនមានលក្ខណៈដាច់ខាតដូចមូលហេតុដែលនាំឲ្យមោឃភាពតាមមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណីទេ។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៣, កថាខណ្ឌទី១

**២.អលទ្ធភាពតាំងពីដំបូង**

អលទ្ធភាពតាំងពីដំបូង គឺមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើតមានភាពច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានោះមិនអាចធ្វើបានទេ។ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់មុនពេលធ្វើវិសោធនកម្មឆ្នាំ២០០២ ចែងថា ក្នុងករណីដែលអលទ្ធភាពតាំងពីដំបូង កិច្ចសន្យានោះត្រូវទុកជាមោឃៈ ប៉ុន្តែបញ្ញត្តិនេះត្រូវបានលុបចោល[9]។ ការលុបចោលបញ្ញត្តិនេះយើងអាចនិយាយបានថា ដោយសារតែការប្រែប្រួលស្ថានភាពសង្គម ដែលមានការវិវត្តពីមួយថ្ងៃទៅមួយថ្ងៃ ដែលនាំឲ្យមានការលុបចោលបញ្ញត្តិនេះដើម្បីឲ្យសមស្របទៅតាមស្ថានភាពសង្គមសព្វថ្ងៃ។ សព្វថ្ងៃប្រទេសកម្ពុជាយើង ក៏ដូចជាប្រទេសដទៃទៀត មាននិន្នាការដែលមិនបានយកអលទ្ធភាពតាំងពីដំបូងធ្វើជាមូលហេតុនៃមោឃភាពនៃកិច្ចសន្យាទេ ហេតុដូចនេះ នៅក្នុងចំណុចនេះយើងមិនមានមូលដ្ឋានអ្វីច្រើនក្នុងការបកស្រាយនោះទេ គឺយើងគ្រាន់តែចង់បញ្ជាក់ថា អលទ្ធភាពតាំងពីដំបូង ធ្លាប់ជាមូលហេតុនៃមោឃភាព ប៉ុន្តែសព្វថ្ងៃ ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យា ដោយយកមូលហេតុនៃការភាន់ច្រលំឡើយ ក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រលំត្រូវបានបំពេញ[10]។

**កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការមោឃភាព**

ជនដែលអាចអះអាង សំដៅលើជនដែលអាចលើកឡើងអំពីកិច្ចសន្យាដែលមោឃៈ។ ជនដែលអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាមានស្ថានភាពខុសគ្នាទៅតាមករណីនីមួយៗ ដែលជាមូលហេតុនៃការមោឃភាព។ ក្នុងនោះមានដូចជា **(ក.)ករណីមោឃភាពទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចសន្យា (ខ.)ករណីមោឃភាពទាក់ទងទៅនឹងលក្ខខណ្ឌទម្រង់ដែលទាមទារ និង (គ.)ករណីការបង្ហាញឆន្ទៈមិនពិត**។

**ក.ករណីមោឃភាពទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចសន្យា**

នៅក្នុងករណីនេះ បើយើងក្រឡេកទៅមើលផលប៉ះពាល់ដែលបានកើតឡើង វាមិនត្រឹមតែធ្វើឲ្យប៉ះពាល់ដល់ភាគី ឬតតិយជនដែលមានប្រយោជន៍នោះទេ គឺវាធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍

---

[9] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ២, គន្ថីទី៤, រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា ៣៥៥

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៥

រួម ក៏ដូចជាសង្គមទាំងមូល ដូចនេះ ករណីមោឃភាពទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចសន្យាត្រូវបាន បើកសិទ្ធិយ៉ាងទូលាយ គឺជនណាក៏អាចអះអាងអំពីការមោឃភាពបានដែរ[11]។

ឧទាហរណ៍៖ កិច្ចសន្យាជួញដូរគ្រឿងញៀន វាធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរណាស់ ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម។ ដូចនេះហើយ ទើបច្បាប់បានបើកសិទ្ធិឲ្យយ៉ាងធំទូលាយ ដែលមិនត្រឹមតែជាភាគីនៃកិច្ចសន្យាប៉ុណ្ណោះទេ ដែលអាចអះអាងអំពីមោឃភាពនេះបាន សូម្បីតែជនផ្សេងទៀតដែលមិនមែនជាភាគី ដែលមិនមានផលប្រយោជន៍ពីកិច្ចសន្យា ក៏អាចអះអាងអំពីមោឃភាពបានផងដែរ។

**ខ.ករណីមោឃភាពទាក់ទងទៅនឹងលក្ខខណ្ឌទម្រង់ដែលទាមទារ**

ករណីនេះក៏មិនខុសគ្នាពីករណីខាងលើនេះដែរ ជនណាក៏អាចអះអាងអំពីការមោឃភាពនៃកិច្ចសន្យាដែលត្រូវបានមោឃភាព ដោយមូលហេតុទាក់ទងទៅនឹងលក្ខខណ្ឌទម្រង់ដែលត្រូវបានទាមទារដោយច្បាប់ដែរ[12]។

**គ.ករណីការបង្ហាញឆន្ទៈមិនពិត**

ប្រសិនបើមោឃភាពនៃកិច្ចសន្យាដោយការបង្ហាញឆន្ទៈមិនពិត មានតែភាគីនៃកិច្ចសន្យា និងតតិយជនដែលមានផលប្រយោជន៍ប៉ុណ្ណោះ ដែលអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យានោះបាន ព្រោះបើយើងក្រឡេកទៅមើលផលប៉ះពាល់របស់កិច្ចសន្យាប្រភេទនេះវិញ គឺផលប៉ះពាល់របស់វាមានត្រឹមតែភាគីដែលពាក់ព័ន្ធនឹងផលប្រយោជន៍តែប៉ុណ្ណោះ។

**កថាខណ្ឌទី៣. វិធីនៃការមោឃភាព**

ក្រមរដ្ឋប្បវេណី ពុំបានបញ្ញត្តិអំពីវិធីនៃការមោឃភាពឡើយ។ ក៏ប៉ុន្តែបើយើងមើលទៅលើកិច្ចសន្យាដែលទទួលរងនូវមោឃភាព គឺត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូងមកម្ល៉េះ។ ដូចនេះ យើងគ្រាន់តែជូនដំណឹងអំពីការមោឃភាពនេះ ទៅភាគីម្ខាងទៀត ហើយបញ្ឈប់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាដែលមោឃភាពនោះ។ ក៏ប៉ុន្តែបើភាគីម្ខាងទៀតនៅតែទាមទារឲ្យអនុវត្តកាតព្វកិច្ច ឬមិនព្រមប្រគល់តាវកាលិកដែលអនុវត្តរួចត្រឡប់មកវិញទេ នោះភាគីម្ខាងអាចដាក់ពាក្យបណ្ដឹងទៅតុលាការបាន។ ដូច្នេះហើយ បើយើងនិយាយអំពីវិធីនៃការមោឃភាពនោះវានឹងលេចឡើងនូវវិធីចំនួន ០២(ពីរ) គឺវិធីតាមក្រៅផ្លូវតុលាការ និងវិធីតាមផ្លូវតុលាការ។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៧

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៧

**ក.វិធីតាមក្រៅផ្លូវតុលាការ**

នៅពេលដែលកិច្ចសន្យាមួយត្រូវបានចាត់ទុកថាមោឃភាព នោះភាគីម្ខាងអាចធ្វើការអះអាងអំពីការមោឃភាពទៅភាគីម្ខាងទៀត តាមរយៈការជូនដំណឹងអំពីការមោឃភាពនេះ រួចបញ្ឈប់រាល់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ច ព្រោះថា កិច្ចសន្យាដែលចាត់ទុកថាមោឃភាព ប្រៀបបានដូចជាគ្មានកិច្ចសន្យានោះដែរ។ ការបញ្ចប់កិច្ចសន្យាដោយរបៀបនេះ គឺជាការបញ្ចប់ដោយការព្រមព្រៀង ក៏ប៉ុន្តែនៅពេលដែលភាគីម្ខាងទៀតមិនព្រមទទួលស្គាល់អំពីការមោឃភាពនេះ ភាគីម្ខាងអាចធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការបាន។

**ខ.វិធីតាមផ្លូវតុលាការ**

នៅពេលដែលភាគីម្ខាងទៀតនៃកិច្ចសន្យាមិនព្រមទទួលស្គាល់អំពីការមោឃភាព ហើយនៅតែទាមទារឲ្យភាគីម្ខាងអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាដែលត្រូវបានចាត់ទុកថាមោឃៈ នោះភាគីម្ខាងអាចធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការបាន។ ការដាក់ពាក្យបណ្តឹងនេះផងដែរ គឺដាក់ពាក្យបណ្តឹងសុំបញ្ជាក់ពីនត្ថិភាពនៃកិច្ចសន្យា ហើយតុលាការនឹងចេញសាលក្រម ឬសាលដីកាស្ថាពរបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យា ដែលនេះគឺជាសេចក្តីសម្រេចដែលបញ្ជាក់អំពីភាពដែលគ្មានករណីយកិច្ចត្រូវបំពេញឲ្យគ្នាទៅវិញទៅមកទៀតទេ។ ប៉ុន្តែបើយើងមើលទៅលើការអនុវត្តជាក់ស្តែង គឺដើមចោទតែងតែសរសេរក្នុងកម្មវត្ថុ ឬខ្លឹមសារនៃការទាមទារថា "សុំឲ្យតុលាការប្រកាសមោឃភាពនៃកិច្ចសន្យា" និងនៅតែមានសាលក្រម និងសាលដីកាមួយចំនួននៅតែសរសេរខ្លឹមសារសម្រេចថា "ប្រកាសមោឃភាពនៃកិច្ចសន្យា" ដដែល ដោយពុំទាន់មានការកែប្រែកម្មវត្ថុ ឬខ្លឹមសារនៃការទាមទារថា "បណ្តឹងសុំបញ្ជាក់នត្ថិភាពនៃកិច្ចសន្យា" នោះទេ។ មូលហេតុនៃការមិនទាន់កែប្រែបែបនេះ គឺដោយសារតែចាប់តាំងពីច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី បានប្រកាសឲ្យប្រើនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១ ដែលបទបញ្ញត្តិនេះហាក់បីដូចជានៅថ្មីនៅឡើយ ដែលអ្នកច្បាប់ភាគច្រើននៅតែជិតជាមនូវច្បាប់ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា នៅឡើយ។ ចាប់តាំងពីក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យអនុវត្តដោយច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី មក ប្រសិនបើដើមចោទសរសេរក្នុងកម្មវត្ថុ ឬខ្លឹមសារនៃការទាមទារថា "សុំឲ្យតុលាការប្រកាសមោឃភាពនៃកិច្ចសន្យា" នោះតុលាការនឹងចេញសាលក្រមលើកចោលពាក្យបណ្តឹងដោយមិន

ចាំបាច់ធ្វើការទាញហេតុផលផ្ទាល់មាត់[13] ដោយសារតែបណ្ដឹងប្រភេទនេះ ជាបណ្ដឹងផ្ទុយច្បាប់ ឬ បណ្ដឹងខុសច្បាប់[14]។

## ផ្នែកទី២. សញ្ញាណទូទៅអំពីការលុបចោល

ប្រសិនបើយើងធ្វើការសង្កេតបញ្ញត្តិមួយចំនួនដែលមានចែងអំពី ការលុបចោលកិច្ចសន្យា នោះយើងនឹងរកឃើញអំពី **(កថាខណ្ឌទី១.)មូលហេតុដែលនាំឲ្យមានការលុបចោលកិច្ចសន្យា** ដែលផ្ទុយពីមោឃភាព។ កិច្ចសន្យាដែលនឹងត្រូវលុបចោល គឺមានលក្ខណៈប៉ះពាល់ត្រឹមតែផលប្រយោជន៍របស់បុគ្គលឯកជនដែលជាភាគីតែប៉ុណ្ណោះ។ ការលុបចោល គឺជាការបង្ហាញឆន្ទៈរបស់ជនដែលមានសិទ្ធិលុបចោល ដោយសារតែការបង្កើតកិច្ចសន្យានោះមិនទាន់បានបំពេញនូវលក្ខខណ្ឌសុពលពេញលេញនៃកិច្ចសន្យា។ កិច្ចសន្យាដែលបានបង្កើតឡើងដោយរងនូវមូលហេតុដែលនាំឲ្យមានការលុបចោល គឺមានសុពលភាពរហូតដល់ពេលដែល **(កថាខណ្ឌទី២.)ជនដែលមានសិទ្ធិលុបចោល** លុបចោលកិច្ចសន្យានោះទៅតាម **(កថាខណ្ឌទី៣.)វិធីនៃការលុបចោល** ដែលច្បាប់បានកំណត់។

### កថាខណ្ឌទី១. មូលហេតុដែលនាំឲ្យមានការលុបចោល

ប្រភពនៃការលុបចោលកិច្ចសន្យា មានមូលហេតុធំៗ ចំនួន ០៣(បី) គឺ ដោយមូលហេតុជនខ្វះសមត្ថភាព ដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ និងការលុបចោលទៅតាមបញ្ញត្តិពិសេស។ ប៉ុន្តែដើម្បីកំណត់វិសាលភាពនៃការបកស្រាយឲ្យមានលក្ខណៈសមល្មមទៅនឹងពេលវេលា និងទំហំនៃការបកស្រាយ ព្រមទាំងមានភាពស៊ីជម្រៅបន្តិចនោះ យើងនឹងលើកយកតែមូលហេតុចំនួន ០២(ពីរ) ប៉ុណ្ណោះ មកធ្វើការបកស្រាយ គឺការលុបចោលដោយមូលហេតុ **(ក.)ជនខ្វះសមត្ថភាព** និង **(ខ.)វិការៈនៃការបង្ហាញឆន្ទៈ**។

#### ក.ជនខ្វះសមត្ថភាព

ជនខ្វះសមត្ថភាព[15] សំដៅដល់បុគ្គលដែលមិនអាចយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន។ ដោយឈរលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន បុគ្គលគ្រប់រូប

---

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥៨៥ និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីលេខ នស/រកម/០៥១១/00៧, ៣១ ឧសភា ២០១១, មាត្រា ៨១

[14] បណ្ដឹងផ្ទុយច្បាប់ ឬបណ្ដឹងខុសច្បាប់ សំដៅលើបណ្ដឹងរបស់ដើមចោទដែលទាមទារឲ្យតុលាការចេញសាលក្រម ដែលច្បាប់សារធាតុមិនបានទទួលស្គាល់នូវសិទ្ធិនោះ។ ឧ. មាត្រា ៤០៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ បានចង្អុលបង្ហាញឲ្យភាគីម្ខាងបង្ហាញឆន្ទៈរំលាយកិច្ចសន្យាចំពោះភាគីម្ខាងទៀតប៉ុណ្ណោះ មានន័យថា គ្មានបញ្ញត្តិណាមួយឲ្យតុលាការជាអ្នកប្រកាសរំលាយកិច្ចសន្យានោះទេ។

មានសិទ្ធិសេរីភាពក្នុងការធ្វើកិច្ចសន្យា បុគ្គលគ្រប់រូបទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចតាមឆន្ទៈរបស់ខ្លួនដោយសេរី។ បុគ្គលម្នាក់ៗមានសេរីភាពក្នុងការបង្ហាញឆន្ទៈ ក៏ប៉ុន្តែដើម្បីឲ្យការបង្ហាញឆន្ទៈនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពនោះ វាមានភាពចាំបាច់ណាស់ដែលអ្នកបង្ហាញឆន្ទៈនោះត្រូវតែមានសមត្ថភាពអាចយល់ដឹងនូវអំពើរបស់ខ្លួន បើបុគ្គលនោះមិនមានសមត្ថភាពក្នុងការយល់ដឹងទៅហើយ តើអាចបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាបានត្រឹមត្រូវដែរឬទេ? តើបុគ្គលនេះត្រូវប្រឈមនឹងការខាតបង់ប្រយោជន៍ឬទេ? ដូចនេះ តើគាត់គួរទទួលបានការការពារដែរឬទេ?

ច្បាស់ណាស់ ជននេះប្រាកដជារងនូវហានិភ័យខ្ពស់ ក្នុងការខាតបង់ប្រយោជន៍កម្រិតអតិបរមា ដូចនេះ ដើម្បីដោះស្រាយនូវស្ថានភាពនេះ ច្បាប់បានបញ្ញត្តិឲ្យមាននូវរបបនៃការការពារទៅលើ (ក.)**ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព** និង (ខ.)**ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ**។

### ១.ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

របបគតិយុត្តិដែលបានកំណត់អំពីសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជារបបការពារកុំឲ្យមានការទទួលរងនូវការខូចខាត ដែលកើតមានឡើងដោយសារកិច្ចការជំនួញរបស់ជនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ដោយការមិនឲ្យជនមួយចំនួនបង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញ។ ជាក់ស្តែង ជនទាំងនោះមាន ០៣(បី)ប្រភេទ គឺ អនីតិជន ជនក្រោមអាណាព្យាបាលទូទៅ និងជនក្រោមហិតូបត្ថម្ភ។ ជនទាំងនេះត្រូវបានហៅជារួមក្នុងពាក្យពេចន៍ច្បាប់ថា ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងន័យថា ជននោះត្រូវបានកម្រិតសមត្ថភាពក្នុងការបង្កើតកិច្ចសន្យា រួមទាំងសកម្មភាពឯកតោភាគីផងដែរ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឲ្យមោឃៈ ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន[16]។ ប៉ុន្តែប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោកដើម្បីឲ្យគេជឿជាក់ថា ខ្លួនជាជនមានសមត្ថភាព នោះកិច្ចសន្យាមិនអាចលុបចោលវិញបានទេ[17]។

---

[15] **ជនខ្វះសមត្ថភាព** ដែលប្រើនៅទីនេះ គឺគ្រាន់តែជាការប្រើប្រាស់ចំណងជើងរួមមួយដែលងាយស្រួលក្នុងការបកស្រាយប៉ុណ្ណោះ ហើយការប្រើនេះ សំដៅទៅលើជនដែលខ្វះសមត្ថភាពខាងឆន្ទៈ និងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] កំណត់មាត្រា ១៦ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ១ គន្ថីទី១-ទី៣

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣

## ១.១.អនីតិជន

អនីតិជន សំដៅលើជនដែលមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ[18]។ ក៏ប៉ុន្តែប្រសិនបើអនីតិជនទទួលបាននូវអត្តាធីនភាព ត្រូវចាត់ទុកថា បានដល់នីតិភាព[19] មានន័យថា សកម្មភាពរបស់អនីតិជនដែលទទួលបានអត្តាធីនភាពបានធ្វើ គឺមានសុពលភាពដូចជានីតិជនដែរ។ ជាគោល-ការណ៍ សកម្មភាពដែលអនីតិជនបានធ្វើដោយមិនទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន សកម្មភាពនោះអាចលុបចោលបាន លើកលែងតែសកម្មភាពទទួលបានសិទ្ធិ ឬសកម្មភាពរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ[20] ឬការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែង[21] និងសកម្មភាពទាក់ទងនឹងអាជីវកម្មដែលអនីតិជនត្រូវបានអនុញ្ញាតឲ្យធ្វើដោយអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ[22] ។

*★អនីតិជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ទោះបីជាមានការយល់ព្រមឲ្យធ្វើសកម្មភាពពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ក៏សកម្មភាពនោះនៅតែអាចលុបចោលដោយអ្នកអាណាព្យាបាលទូទៅដែរ។*

## ១.២.ជនក្រោមអាណាព្យាបាលទូទៅ

ជនក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តន៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយទទួលបានការប្រកាសពីតុលាការ ពីការចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធញាតិក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់ នៃលំនៅដ្ឋានរបស់ជននោះ ឬ តំណាងអយ្យការ[23]។ រាល់កិច្ចសន្យាដែលជននៅក្រោមអាណាព្យាបាលបានធ្វើ អាចលុបចោលបាន លើកលែងតែកិច្ចសន្យាដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ[24]។ មិនតែប៉ុណ្ណោះ ទោះបីជាកិច្ចសន្យាដែលជននៅក្រោមអាណាព្យាបាលបានធ្វើដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏

---

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៧

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២២

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៨

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៩

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៤

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៦

សកម្មភាពនោះអាចលុបចោលបានដែរ ព្រោះជននៅក្រោមអាណាព្យាបាលទូទៅស្ថិតនៅក្នុងស្ថានភាពជានិរន្តន៍ដែលខ្វះសមត្ថភាព ដូច្នេះ ទោះបីជាអ្នកអាណាព្យាបាលបានផ្តល់នូវការយល់ព្រមជាមុនក៏ដោយ ក៏ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពចាំបាច់តាមការរំពឹងទុកដែរ។

## ១.៣.ជនក្រោមហិតូបត្ថម្ភ

ជនដែលនៅក្រោមរបបហិតូបត្ថម្ភ គឺជាអ្នកដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង ឬ វិនិច្ឆ័យ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី មានន័យថា អ្នកដែលគ្រាន់តែអាចទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើកិច្ចសន្យាសំខាន់ៗដែលកំណត់ដោយច្បាប់ទេ។ ហើយចាំបាច់ត្រូវមានជំនួយពីអ្នកផ្សេងជានិច្ច។ ជាគោលការណ៍ ជននៅក្រោមរបបហិតូបត្ថម្ភ អាចធ្វើសកម្មភាពដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ លើកលែងតែសកម្មភាពមួយចំនួនដែលបានកំណត់នៅក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពទាំងអស់នេះបាន លុះត្រាតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយបើសិនជាមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈទេ សកម្មភាពនោះអាចលុបចោលបាន។

## ២.ជនខ្វះសមត្ថភាពខាងឆន្ទៈ

ជនខ្វះសមត្ថភាពខាងឆន្ទៈ សំដៅដល់បុគ្គលដែលធ្វើសកម្មភាពស្ថិតក្នុងស្ថានភាពដែលបុគ្គលនោះមិនអាចយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់បាន[25]។ សម្រាប់សកម្មភាពណាដែលបានធ្វើដោយជនដែលស្ថិតនៅក្នុងស្ថានភាពចុះថយខ្លាំងនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់ សកម្មភាពនោះអាចលុបចោលបាន។ ការផ្តល់សិទ្ធិឲ្យមានការលុបចោលសកម្មភាពដែលធ្វើឡើងដោយជនខ្វះសមត្ថភាពខាងឆន្ទៈ គឺបង្ហាញឲ្យយើងឃើញថា ទោះបីជាជននោះមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏នៅតែអាចលុបចោលសកម្មភាពនោះបានដែរ ប្រសិនបើជននោះបានធ្វើសកម្មភាពស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពខាងឆន្ទៈ។

- ឧទាហរណ៍៖ បុគ្គលដែលបានបង្កើតកិច្ចសន្យានៅពេលដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាននូវសកម្មភាពរបស់ខ្លួនដោយសារជននោះស្រវឹងស្រា ឬប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់សមត្ថភាពខាងឆន្ទៈ នោះកិច្ចសន្យានេះអាចលុបចោលវិញបាន។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៤

**ខ.វិការៈនៃការបង្ហាញឆន្ទៈ**

កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងគូភាគី និងមានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានសុពលភាព។ ប៉ុន្តែក៏មានករណីមួយចំនួន ទោះបីជាកិច្ចសន្យានោះគោរពនូវលក្ខខណ្ឌខាងលើរួចហើយក៏ដោយ ក៏នៅតែអាចត្រូវបានគេលុបចោលបានដែរ ប្រសិនបើដំណើរនៃការបង្កើតកិច្ចសន្យានោះមានវិការៈតាមរូបភាពមួយចំនួនដូចជាការភាន់ច្រលំ ការឆបោក ការគម្រាមកំហែង អំពើកេងចំណេញហួសហេតុជាដើម[26]។

**១.ការភាន់ច្រលំ**

ការភាន់ច្រលំ គឺជាការបង្ហាញនូវឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រលំអំពីខ្លឹមសារនៃកិច្ចសន្យា។ ឧទាហរណ៍ ដូចជាក្នុងការប្រកបរបរលក់ដូរចិញ្ចឹមជីវិតប្រចាំថ្ងៃ នៅពេលដែលអ្នកលក់ធ្វើការគិតលុយដោយខ្វះលេខសូន្យមួយខ្ទង់ យើងឃើញថា អ្នកលក់នឹងត្រូវប្រឈមមុខនឹងការខាតបង់ខ្ពស់។ ដូចនេះហើយ ដើម្បីការពារហានិភ័យដែលអាចកើតឡើងនៅពេលដែលមានការភាន់ច្រលំ ច្បាប់អនុញ្ញាតឲ្យភាគីដែលបង្ហាញឆន្ទៈដោយមានការភាន់ច្រលំ អាចលុបចោលកិច្ចសន្យានោះបាន។ យោងតាមមាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី បានបែងចែកស្ថានភាពនៃការភាន់ច្រលំជា ០៣(បី) ប្រភេទគឺ (១.១.)**ការភាន់ច្រលំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា** ឬ (១.២.)**ការភាន់ច្រលំអំពីចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ឬ ចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា** និង (១.៣.)**ការភាន់ច្រលំដោយភាគីទាំងសងខាង**។

**១.១.ការភាន់ច្រលំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា**

ជាការពិតណាស់ យើងពិតជាមានការលំបាកក្នុងការកំណត់អំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ដែលជាហេតុនាំឲ្យភាគីលុបចោលកិច្ចសន្យាដែលខ្លួនបានបង្កើតដោយមូលហេតុមានការភាន់ច្រលំ ព្រោះពុំមានបញ្ញត្តិណាមួយបានចែងឲ្យបានច្បាស់អំពីចំណុចសំខាន់ៗនោះទេ។ ចំណុចសំខាន់ៗនៃកិច្ចសន្យាត្រូវបានកំណត់ជាក់លាក់តាមរយៈប្រភេទនៃកិច្ចសន្យា និងស្ថានភាពផ្សេងៗគ្នា។ ក្នុងករណីដែលភាគីមានការភាន់ច្រលំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រលំនេះ ភាគីដែលបានភាន់ច្រលំអាចលុបចោលកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[27]។

[26] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ឆ្នាំ២០០៩, ទំព័រ១២០

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៦, កថាខណ្ឌទី១

**លក្ខខណ្ឌ៖**

- ការភាន់ច្រលំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា (អ្នកបង្ហាញឆន្ទៈ)
- ស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រលំ (ភាគីម្ខាងទៀត)

ឧទាហរណ៍៖ A ជាអ្នកលក់ទូរស័ព្ទ ហើយនៅក្នុងហាងមានទូរស័ព្ទ IPHONE X ចំនួន ០២គ្រឿង ដោយមួយគ្រឿងជាទូរស័ព្ទថ្មី និងមួយគ្រឿងទៀតជាទូរស័ព្ទមួយទឹក។ ហើយ B ចង់ទិញទូរស័ព្ទ IPHONE X ថ្មី ហើយក៏បានយល់ព្រមទិញក្នុងតម្លៃ ១.២០០ដុល្លា តែដោយទូរស័ព្ទទាំងពីរមានសភាពប្រហាក់ប្រហែលគ្នា B ក៏បានចង្អុលឲ្យ A វេចខ្ចប់ច្រលំទូរស័ព្ទមួយទឹក។ នៅពេលដែល B យល់ព្រមទិញក្នុងតម្លៃ ១.២០០ដុល្លា នោះ A អាចនឹងដឹងថា B ចង់ទិញទូរស័ព្ទ IPHONE X ថ្មី ដោយពិនិត្យមើលទៅលើតម្លៃដែលបានចចារគ្នា។ ដូចនេះ B អាចលុបចោលកិច្ចសន្យានោះបានដោយសារការភាន់ច្រលំ។

ប៉ុន្តែមិនមែនគ្រប់ករណីភាន់ច្រលំសុទ្ធតែអាចលុបចោលបាននោះទេ ដើម្បីការពារផលប្រយោជន៍ភាគីម្ខាងទៀត និងការពារដល់សុវត្ថិភាពក្នុងការធ្វើជំនួញ ទាល់តែភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រលំ ទើបភាគីដែលភាន់ច្រលំអាចលុបចោលកិច្ចសន្យានោះបាន។

### ១.២.ការភាន់ច្រលំអំពីចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ឬ ចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យាមានការភាន់ច្រលំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចសំខាន់ដែលនាំឲ្យបង្កើតកិច្ចសន្យា នោះវាក៏ជាមូលហេតុដែលនាំឲ្យមានការលុបចោលកិច្ចសន្យានោះដែរ។ ចំពោះចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់នេះ អាចមិនពាក់ព័ន្ធនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ហើយវាមិនមែនសំខាន់សម្រាប់ភាគីទាំងសងខាងនោះទេ គឺវាមានសារៈសំខាន់សម្រាប់តែភាគីម្ខាងតែប៉ុណ្ណោះ។

**លក្ខខណ្ឌ៖**

- ចំពោះភាគីម្ខាងនៃកិច្ចសន្យាមានការភាន់ច្រលំអំពី៖
    - ចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ
    - ចំណុចដែលខ្លួនបានយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា
- ភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រលំរបស់អ្នកបង្ហាញឆន្ទៈ។

ឧទាហរណ៍៖ នៅក្នុងសង្គមយើងជាក់ស្តែង អ្នកធ្វើជំនួញភាគច្រើនគិតអំពីហ៊ុងស៊ុយនៃរបស់ប្រើប្រាស់របស់គេណាស់។ មានអ្នកជំនួញ A ដ៏ល្បីល្បាញម្នាក់ដែលមានមុខស្ទើតែគ្រប់ប្រព័ន្ធផ្សព្វផ្សាយ គាត់ទៅណាមកណាប្រើប្រាស់តែរថយន្តពណ៌ខ្មៅ ព្រោះគាត់គិតថាពណ៌ខ្មៅ ជាពណ៌ដែលនាំហ៊ុងស៊ុយឲ្យគាត់។ A បានទៅទិញរថយន្តនៅក្នុងហាងលក់រថយន្តរបស់ B ដោយសារតែពេលនោះស្ថិតនៅក្នុងស្ថានភាពដែលមេឃស្រទុំ ពុំសូវមានពន្លឺគ្រប់គ្រាន់ នាំឲ្យគាត់មើលឃើញពណ៌ខៀវស្រគាំ ថាជាពណ៌ខ្មៅ។ លុះដល់ថ្ងៃប្រគល់រថយន្តទើបគាត់ដឹងពីបញ្ហានេះ។ ដូចនេះស្ថិតក្នុងស្ថានភាពនេះ B អាចដឹងអំពីរឿងនេះ ដែលនាំឲ្យ A អាចលុបចោលនូវកិច្ចសន្យាបាន។

### ១.៣.ការភាន់ច្រលំដោយភាគីទាំងសងខាង

ប្រសិនបើភាគីនៃកិច្ចសន្យាទាំងសងខាងបានបង្កើតកិច្ចសន្យាដោយមានការភាន់ច្រលំទៅលើចំណុចណាមួយនៃកិច្ចសន្យាដូចគ្នា នោះភាគីទាំងសងខាងមានសិទ្ធិលុបចោលកិច្ចសន្យានោះវិញបាន។

**លក្ខខណ្ឌ៖**

- ភាគីទាំងសងខាងមានការភាន់ច្រលំទៅលើចំណុចណាមួយនៃកិច្ចសន្យាដូចគ្នា
- ចំណុចដែលមានការភាន់ច្រលំ គឺជាចំណុចសំខាន់នៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។

ភាពខុសគ្នានៃការលុបចោលកិច្ចសន្យាក្នុងករណីមានការភាន់ច្រលំដោយភាគីទាំងសងខាងនេះ ខុសពីករណីភាន់ច្រលំទាំងពីរខាងលើត្រង់ថា ការភាន់ច្រលំដោយភាគីទាំងសងខាង ភាគីណាក៏អាចលុបចោលកិច្ចសន្យាបានដែរ ទោះបីភាគីម្ខាងទៀតមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រលំនេះក៏ដោយ។

ឧទាហរណ៍៖ A និង B បានធ្វើកិច្ចសន្យាទិញលក់មួយទៅលើកន្ត្រៃធម្មតាមួយ ដោយយល់ច្រលំដូចគ្នាថា ជាកន្ត្រៃបុរាណ។ ករណីនេះ A អាចលុបចោលកិច្ចសន្យានោះបាន ទោះបីជា B ស្ថិតក្នុងស្ថានភាពមិនអាចដឹងអំពីការភាន់ច្រលំក៏ដោយ។

### ២.ការឆបោក

ការឆបោក ក៏ជាកត្តាដែលនាំឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រលំផងដែរ។ ប៉ុន្តែការភាន់ច្រលំនៅទីនេះ វាកើតឡើងដោយការបោកបញ្ឆោត បន្លំបោកប្រាស់ ប្រើល្បិចកលជាដើមពីសំណាក់ភាគីម្ខាងទៀត ឬ តតិយជន។ វាមានភាពចាំបាច់យ៉ាងខ្លាំងក្នុងការការពារជនរងគ្រោះ

ដែលបានបង្ហាញឆន្ទៈដោយសារការឆបោកនោះ ។ ក៏ប៉ុន្តែមិនមែនរាល់ការឆបោកទាំងអស់សុទ្ធតែជាមូលដ្ឋាននៃការលុបចោលកិច្ចសន្យានោះទេ។ មានការឆបោកមួយចំនួនដែលមានលក្ខណៈតិចតួច មិនប៉ះពាល់ដល់សារធាតុសំខាន់នៃកិច្ចសន្យា ត្រូវបានសង្គមទទួលស្គាល់ថា ទោះបីជាមានការឆបោកក៏ដោយ ក៏មិនអាចលុបចោលកិច្ចសន្យានោះបានដែរ។

ឧទាហរណ៍៖ A បានទៅរកទិញនាឡិកាដៃនៅក្នុងហាងនាឡិការបស់ B។ B បានលក់នាឡិកាដៃម៉ាក C ទៅឲ្យ A ដោយកុហកថា ជានាឡិកាដែលកំពុងពេញនិយម និងលក់ដាច់ជាងគេ។ ដូចនេះ ក្នុងករណីនេះជាការឆបោកដែលសង្គមទទួលស្គាល់។

ការឆបោក ពេលខ្លះធ្វើឡើង **(២.១.)ដោយភាគីម្ខាងទៀត** ពេលខ្លះទៀតធ្វើឡើង **(២.២.) ដោយតតិយជន**។

### ២.១.ករណីឆបោកដោយភាគីម្ខាងទៀត

នៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើង ដោយមានការឆបោកពីសំណាក់ភាគីម្ខាងទៀតក្នុងកិច្ចសន្យានោះ យើងមិនចាំបាច់ពិចារណាច្រើននោះទេ ព្រោះច្បាប់មិនការពារជនដែលមានគំនិតទុច្ចរិតដើរបោកប្រាស់អ្នកដទៃឡើយ។ ហេតុដូចនេះ ភាគីដែលបានបង្ហាញឆន្ទៈដោយមានការឆបោកពីភាគីម្ខាងទៀតនោះ អាចធ្វើការលុបចោលកិច្ចសន្យានោះវិញបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

**លក្ខខណ្ឌ៖**

- ភាគីម្ខាងបានផ្តល់ពត៌មានមិនពិតដោយចេតនា (ឆបោក)
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈខុសពីឆន្ទៈពិត ដោយសារការឆបោកនោះ។

ឧទាហរណ៍៖ A បានទៅរកទិញទឹកអប់ដែលផលិតនៅប្រទេសបារាំង នៅហាងរបស់ B។ ពេលនោះ B បានយកទឹកអប់ដែលផលិតនៅប្រទេសថៃលក់ឲ្យទៅ A ដោយកុហកថាជាផលិតផលរបស់ប្រទេសបារាំង។ ក្នុងករណីនេះ A អាចលុបចោលកិច្ចសន្យាវិញបាន។

### ២.២.ការឆបោកដោយតតិយជន

ការឆបោក ពេលខ្លះធ្វើឡើងដោយតតិយជន មិនមែនធ្វើឡើងដោយភាគីនោះទេ។ នៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយមានការឆបោកពីតតិយជន ហើយភាគីម្ខាងទៀតពុំបានដឹងអំពីការឆបោកនេះឡើយ ដូចនេះ ប្រសិនបើយើងអនុញ្ញាតឲ្យភាគីដែលបង្ហាញឆន្ទៈដោយមានការឆបោកនោះ អាចលុបចោលកិច្ចសន្យានោះបាន វាហាក់បីដូចជាអយុត្តិធម៌ណាស់សម្រាប់ភាគីម្ខាងទៀត។ ហេតុនេះហើយ ដើម្បីឲ្យមានភាពស្មើគ្នារវាងភាគីនៃកិច្ចសន្យា ក្នុងករណី

មានការឆបោកពីសំណាក់តតិយជន ភាគីដែលបានបង្ហាញឆន្ទៈដោយមានការឆបោកនោះ អាចលុបចោលកិច្ចសន្យាបាន លុះត្រាតែភាគីម្ខាងទៀតបានដឹង ឬអាចដឹងអំពីការឆបោកនោះ។

**លក្ខខណ្ឌ៖**

- ភាគីម្ខាងនៃកិច្ចសន្យាត្រូវបានឆបោកដោយតតិយជន
- ភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការឆបោកនោះ

ឧទាហរណ៍៖ A មានចូផ្កាធម្មតាមួយ។ B បានប្រាប់ទៅ C ថា ចូនោះជាចូផ្កាដ៏កម្រ ដែលជាវត្ថុបុរាណ។ ពេលនោះ C បានទិញចូផ្កានោះក្នុងតម្លៃយ៉ាងថ្លៃ។ ក្នុងករណីនេះ បើយើងក្រឡេកមើលទៅ A គឺគេបានដឹងថា ចូផ្ការបស់ខ្លួនគ្រាន់តែជាចូផ្កាធម្មតាមួយតែប៉ុណ្ណោះ ហើយបើ C បានដឹងថា ចូផ្កានោះជាចូផ្កាធម្មតានោះ ក៏ C មិនហ៊ានទិញក្នុងតម្លៃថ្លៃបែបនេះឡើយ ដូចនេះ C គប្បីត្រូវបានការការពារ ដោយ C អាចលុបចោលកិច្ចសន្យានោះវិញបាន។

### ៣.ពត៌មានមិនពិត

ដូចដែលបានធ្វើការបកស្រាយខាងលើ ប្រសិនបើភាគីម្ខាងបានផ្ដល់ពត៌មានមិនពិតដោយចេតនា នោះសកម្មភាពនោះត្រូវបានគេចាត់ទុកថា ជាការឆបោក។ ផ្ទុយទៅវិញ ប្រសិនបើភាគីម្ខាងបានផ្ដល់ពត៌មានមិនពិតដោយពុំមានចេតនាទេនោះ វាត្រូវបានគេចាត់ទុកថាជាការផ្ដល់ពត៌មានមិនពិត។ ពត៌មានមិនពិត សំដៅលើហេតុដែលត្រូវបានលើកឡើងជាមូលដ្ឋានក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបកិច្ចសន្យាបាន[28]។

**លក្ខខណ្ឌ៖**

- ហេតុដែលភាគីម្ខាងបានលើកឡើងសម្រាប់ជាមូលដ្ឋានក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត ទាំងមិនបានដឹងថា វាខុសពីការពិត
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយផ្អែកលើពត៌មានមិនពិតនោះ

ឧទារហណ៍៖ A បានប្រកាសលក់ប៉ាន់តែបុរាណមួយ ប៉ុន្តែធាតុពិតគ្រាន់តែជាប៉ាន់តែធម្មតាដែលមានស្ថានភាពរៀងចាស់បន្តិច។ B ជឿជាក់ថា វាជាវត្ថុបុរាណពិតមែន ហើយគេក៏បានទិញប៉ាន់តែនោះ។ ជាការពិតណាស់ ប្រសិនបើ A បានដឹងថា វាគ្រាន់តែជាប៉ាន់តែធម្មតាមួយនោះ វាគឺជា

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៨៤

ករណីឆបោក ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើ A មិនបានដឹងទេនោះ ហើយ A ជឿជាក់ថា វាជាវត្ថុបុរាណ នោះវាទើបជាករណីផ្ដល់ពត៌មានមិនពិត ។ ករណីនេះ B អាចធ្វើការលុបចោលកិច្ចសន្យានោះបាន ព្រោះបើ B ដឹងថា ប៉ាន់តែនោះជាប៉ាន់តែធម្មតា ក៏ B មិនទិញដែរ ។

### ៤.ការរំលោភលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈរបស់ខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[29]។ ក៏ប៉ុន្តែមិនមែនឲ្យតែភាគីម្ខាងដែលមានឋានៈខ្ពស់ជាង ភាគីម្ខាងទៀតមានឋានៈទាប់ជាងនោះ អាចលុបចោលកិច្ចសន្យាបាននោះទេ លុះត្រាតែការប្រើប្រាស់ឋានៈនោះដោយមិនត្រឹមត្រូវ ហើយអ្នកប្រើឋានៈនោះក៏ដឹង ឬអាចដឹងថា នឹងធ្វើឲ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគីម្ខាងទៀតក្នុងការបង្កើតកិច្ចសន្យាទន្ទឹមនឹងការសម្រេចចិត្តនេះ ភាគីម្ខាងទៀតនោះក៏មិនអាចប្រឆាំងតបវិញបានដែរ។ ការលុបចោលកិច្ចសន្យា ដោយហេតុថា មានការរំលោភលើស្ថានភាពនេះ ត្រូវបានបង្កើតឡើងដើម្បីការពារដល់អ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬ សង្គម។

**លក្ខខណ្ឌៈ**

- ការប្រើដោយមិនត្រឹមត្រូវនូវឋានៈ(សេដ្ឋកិច្ច ឬ សង្គម) ឬ ស្ថានភាព ដោយភាគីម្ខាង
- ខណៈដែលភាគីម្ខាងទៀតមានឋានៈទាបជាង ឬ មិនអាចប្រឆាំងតប។

ឧទាហរណ៍៖ X ជាប្រធានក្រុមហ៊ុន បានសុំឲ្យ Y ដែលជាបុគ្គលិកនៅក្នុងក្រុមហ៊ុនរបស់ខ្លួនទិញរថយន្តរបស់ខ្លួនដែលបានប្រើប្រាស់អស់រយៈពេលជាង ៣ឆ្នាំទៅហើយ ក្នុងតម្លៃ ២០.០០០(ពីរម៉ឺន)ដុល្លាអាមេរិក តែជាក់ស្តែងរថយន្តនេះថ្មីមានតម្លៃប្រហាក់ប្រហែលនឹងគ្នានេះដែរ។ ដោយសារតែ Y ដែលជាបុគ្គលិកមិនហ៊ានប្រកែក ខ្លាចបើប្រកែក ប្រធានក្រុមហ៊ុនបញ្ឈប់ការងារ ទើបគេសម្រេចចិត្តទិញទាំងបង្ខំ។

### ៥.ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈមាន

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៩, កថាខណ្ឌទី១

វិការៈ[30]។ ការគម្រាមកំហែង អាចធ្វើឡើងតាមរូបភាពជាពាក្យសម្តី ឬ ជាកាយវិការ ជាអាទ៍។ យោងទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គឺបុគ្គលម្នាក់ៗអាចបង្ហាញឆន្ទៈដោយសេរី ពិតប្រាកដ និងស្ម័គ្រចិត្តក្នុងការបង្កើតកិច្ចសន្យា។ ដូចនេះ បើការបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យានោះមានការបង្ខិតបង្ខំ គម្រាមកំហែង នោះមិនគួរឲ្យកិច្ចសន្យានោះមានសុពលភាពឡើយ ព្រោះវានឹងធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាគីម្ខាងដែលជាជនរងគ្រោះ។ ដោយសារតែការប៉ះពាល់ដែលកើតចេញពីការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរ ទើបក្រមរដ្ឋប្បវេណីបានការពារជនរងគ្រោះនៃការគម្រាមកំហែងយ៉ាងខ្លាំង ដោយហេតុថា ទោះជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងអំពីការគម្រាមកំហែងនេះក៏ដោយ ក៏ភាគីម្ខាងដែលជាជនរងគ្រោះអាចលុបចោលកិច្ចសន្យានោះវិញបានដែរ។

**លក្ខខណ្ឌ៖**

- ភាគីម្ខាង ឬ តតិយជន ប្រាប់ភាគីម្ខាងទៀតអំពីគំនិតព្យាបាទ
- ធ្វើឲ្យភាគីម្ខាងទៀតភ័យខ្លាច
- ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារភាពភ័យខ្លាចនោះ។

ឧទាហរណ៍៖ A បានយល់ព្រមទិញដីមួយកន្លែងពី B ដោយសារតែ B និយាយថា បើ A មិនទិញដីនោះទេ B នឹងមិនឲ្យក្រុមគ្រួសារ A រស់នៅបានសុខទេ។ ក្នុងករណីនេះ គឺបានបង្ហាញយ៉ាងច្បាស់អំពីភាពដែលគួរឲ្យអាណិតរបស់ B និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបានកើតឡើងចំពោះ B។ ដូចនេះ B អាចធ្វើការលុបចោលកិច្ចសន្យានេះបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ ។

### ៦.អំពើកេងចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ[31]។ ជាគោលគំនិតក្នុងការបង្កើតកិច្ចសន្យា អ្នកច្បាប់ និងសាធារណៈជនទូទៅតែងតែពិចារណាអំពីភាពស្មើគ្នារវាងគូភាគីនៃកិច្ចសន្យា។ ភាពស្មើគ្នាទាំងនោះមានដូចជា ស្ថានភាព ការបង្ហាញឆន្ទៈ ជាពិសេសផលចំណេញនៃកិច្ចសន្យា។ ការកេងចំណេញហួសហេតុមានលក្ខណៈពិសេសខុសពីការគម្រាមកំហែង និងការរំលោភលើស្ថានភាព

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥០

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥១

ដែលពិចារណាអំពីអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈ។ ដោយឡែកការកេងចំណេញហួសហេតុ មិនពិចារណាអំពីអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈឡើយ គឺពិចារណាតែអំពីផលចំណេញដែលភាគីទទួលបានពីកិច្ចសន្យាតែប៉ុណ្ណោះ។ វាជារឿងធម្មតាទេដែលភាគីគ្រប់រូបតែងតែស្វែងរកផលចំណេញរៀងៗខ្លួនពីកិច្ចសន្យា ប៉ុន្តែប្រសិនបើការចំណេញនោះវាហួសហេតុពេក ក៏មិនគួរគប្បីទទួលស្គាល់កិច្ចសន្យានោះឲ្យមានសុពលភាពដែរ។

**លក្ខខណ្ឌះ**

- ភាគីម្ខាងនៃកិច្ចសន្យាបានឆ្លៀតឪកាសដែលភាគីម្ខាងទៀតមានការលំបាកខ្លាំង ឬ មិនដឹង ឬ ខ្វះបទពិសោធន៍ ដើម្បីបង្កើតកិច្ចសន្យា
- ភាគីដែលបានឆ្លៀតឪកាសនោះបានទទួលផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ

*មិនមានអ្វីច្បាស់លាស់ដើម្បីកំណត់ពាក្យថា **ចំណេញយ៉ាងសន្ធឹកសន្ធាប់** នោះទេ គឺវាប្រែប្រួលតាមករណីជាក់ស្តែង។*

ឧទាហរណ៍៖ X មានផ្ទះមួយខ្នងដែលមានតម្លៃ ១០០.០០០(ដប់ម៉ឺន)ដុល្លាអាមេរិក ដែលត្រូវការលក់ជាបន្ទាន់ ដើម្បីយកលុយទៅព្យាបាលឪពុកដែលកំពុងសង្គ្រោះបន្ទាន់នៅមន្ទីពេទ្យ។ Y ឆ្លៀតក្នុងឪកាសនេះក៏បានយល់ព្រមទិញផ្ទះនោះ ក្នុងតម្លៃត្រឹមតែ ៣០.០០០(បីម៉ឺន)ដុល្លាអាមេរិក។ ដោយសារតែ X ត្រូវការលុយជាបន្ទាន់នោះក៏បានបង្ខំចិត្តលក់ទៅ។

យោងតាមឧទាហរណ៍ខាងលើនេះ យើងឃើញថា Y ឆ្លៀតក្នុងឪកាសដែលភាគីម្ខាងទៀតមានការលំបាកខ្លាំង ឬ មិនដឹង ឬ ខ្វះបទពិសោធន៍ ដើម្បីបង្កើតកិច្ចសន្យា បានកេងចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់។ ដូចនេះ យើងមិនគួរណាទទួលស្គាល់កិច្ចសន្យាបែបនេះឡើយ។ ការកេងចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់នេះ មានទស្សនៈមួយបានលើកឡើងថា វាលើសពី ៥០ភាគរយនៃតម្លៃ ដើម។ ដូចនេះភាគីដែលកេងចំណេញពីកិច្ចសន្យាលើសពី ៥០ភាគរយ នៃតម្លៃដើម មិនគួរទទួលស្គាល់កិច្ចសន្យានោះឲ្យមានសុពលភាពឡើយ។

### ៧.បបនីយផ្លូវចិត្ត

បបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈខាងក្រៅដែលមានអត្ថន័យខុសពីឆន្ទៈខាងក្នុង(ឆន្ទៈពិត) ទាំងដឹងថា ឆន្ទៈដែលបានបង្ហាញនោះខុសពីឆន្ទៈខាងក្នុង។ ក្នុងការរស់នៅ មនុស្សយើងម្នាក់ៗតែងតែមានការនិយាយស្តីបែបលក្ខណៈលេងសើច ឬ កុហកភូតភរជាដើម។ នៅក្នុងសកម្មភាពបង្កើតកិច្ចសន្យាក៏ដូចគ្នាអញ្ចឹងដែរ ពេលខ្លះភាគីម្ខាងបានបង្ហាញឆន្ទៈខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន ទាំងដែលខ្លួនឯងដឹងច្បាស់ ប៉ុន្តែពុំមានចេតនាចង់ឲ្យកិច្ចសន្យាកើតមានឡើងនោះ

ទេ។ ក្រមរដ្ឋប្បវេណីបានចាត់ទុកករណីនេះថា បបនីយផ្លូវចិត្ត ដែលអនុញ្ញាតឲ្យកិច្ចសន្យាបែបនេះមានសុពលភាព។ ប៉ុន្តែ ផ្ទុយទៅវិញប្រសិនបើភាគីម្ខាងទៀតដឹងថា ពាក្យសម្ដីទាំងនោះគ្រាន់តែនិយាយលេង នោះអ្នកបង្ហាញឆន្ទៈអាចធ្វើការបដិសេធការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

**លក្ខខណ្ឌ៖**

- ភាគីម្ខាងបង្ហាញឆន្ទៈមិនត្រូវគ្នានឹងឆន្ទៈខាងក្នុង
- ភាគីដែលបានបង្ហាញឆន្ទៈដឹងច្បាស់ថា ឆន្ទៈដែលបានបង្ហាញនោះមិនត្រូវគ្នានឹងឆន្ទៈខាងក្នុង
- ភាគីបង្ហាញឆន្ទៈគ្មានបំណងបង្កើតកិច្ចសន្យាទេ។

ឧទាហរណ៍៖ លោក ក មានកង់បុរាណមួយ ដែលបានបន្សល់ទុកពីដូនតាតាំងពីជំនាន់មុន។ ថ្ងៃមួយលោក ខ ដែលត្រូវជាមិត្តភក្តិរបស់លោក ក បានទៅលេងផ្ទះរបស់លោក ក ហើយឃើញកង់បុរាណនោះ ក៏បានសុំទិញកង់នោះពីលោក ក។ លោក ក ក៏និយាយទៅកាន់លោក ខ ថាលក់ក្នុងតម្លៃ ១លានដុល្លា ដោយគាត់គិតថាមិត្តភក្តិរបស់គាត់ជាជនសាមញ្ញនឹងមិនហ៊ានទិញឡើយ។ តែផ្ទុយទៅវិញ លោក ខ ជាជនសាមញ្ញពិតមែន តែគាត់មានទ្រព្យសម្បត្តិស្តុកស្តម្ភ និងស្រលាញ់វត្ថុបុរាណណាស់ គាត់តែងតែចំណាយលុយលើការទិញវត្ថុទាំងនោះយកមកតាំងនៅគេហដ្ឋានរបស់គាត់។ លោក ខ ក៏សម្រេចចិត្តទិញកង់បុរាណនោះក្នុងតម្លៃ ១លានដុល្លា។ ដូចនេះ បើយើងក្រឡេកទៅមើលកិច្ចសន្យានេះ វានឹងកើតឡើងជាមួយនឹងវិការៈនៃការបង្ហាញឆន្ទៈ ដែលយើងហៅថា បបនីយផ្លូវចិត្ត។

### កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការលុបចោល

ដូចដែលបានបកស្រាយខាងលើអំពី មូលហេតុដែលនាំឲ្យមានការលុបចោលកិច្ចសន្យាដែលមានចំនួន ០២(ពីរ) គឺដោយមូលហេតុជនខ្វះសមត្ថភាព និងដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ។ ជាការសមហេតុសមផលណាស់ដែលជនដែលអាចអះអាងអំពីការលុបចោល ក៏ត្រូវបានបែងចែកចេញជា ០២(ពីរ)ករណីដូចគ្នា គឺ **(ក.)ករណីមូលហេតុជនខ្វះសមត្ថភាព** និង **(ខ.) ករណីវិការៈនៃការបង្ហាញឆន្ទៈ**។

#### ក.ករណីមូលហេតុជនខ្វះសមត្ថភាព

ចំពោះការលុបចោលដោយមូលហេតុជនដែលត្រូវបានកម្រិតសមត្ថភាព ឬ ខ្វះសមត្ថភាពខាងឆន្ទៈ **សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈ** នៃជននោះ អាចលុបចោល

នូវសកម្មភាពនោះបាន។ ក្រៅពីនេះ **សន្តតិជន** ឬ **អច្ច័យលាភីសកល**របស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានផងដែរនៅពេលដែលមានស្ថានភាពនៃសន្តតិកម្មបានកើតឡើង[32]។

**ខ.ករណីវិការៈនៃការបង្ហាញឆន្ទៈ**

ចំពោះការលុបចោលដោយវិការៈនៃការបង្ហាញឆន្ទៈ **អ្នកបង្ហាញឆន្ទៈដោយមានវិការៈ** ឬ **អ្នកតំណាងដែលច្បាប់បានកំណត់** អាចលុបចោលនូវសកម្មភាពនោះបាន។ ក្រៅពីនេះ **សន្តតិជន**របស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបានបង្ហាញឆន្ទៈ ក៏អាចលុបចោលកិច្ចសន្យានោះបានដែរ[33]។

**កថាខណ្ឌទី៣. វិធីនៃការលុបចោល**

ជាទូទៅ ដើម្បីលុបចោលកិច្ចសន្យាមួយបាន ភាគីដែលមានសិទ្ធិលុបចោលគ្រាន់តែជូនដំណឹងអំពីការលុបចោលនោះទៅភាគីម្ខាងទៀតបានហើយ។ ការលុបចោលអាចធ្វើទៅបានតាមរយៈការព្រមព្រៀងគ្នាលុបចោលកិច្ចសន្យានោះ ប៉ុន្តែបើយើងក្រឡេកទៅមើល នៅពេលដែលភាគីដែលមានសិទ្ធិលុបចោល បានអះអាងអំពីការលុបចោលតាមរយៈការជូនដំណឹងហើយ ប៉ុន្តែភាគីម្ខាងទៀតមិនព្រមទទួលស្គាល់ នៅតែទាមទារឲ្យភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ច ឬមិនព្រមប្រគល់តាវកាលិកដែលភាគីម្ខាងទៀតបានអនុវត្តឲ្យទៅភាគីម្ខាងទៀតវិញ នោះភាគីម្ខាងទៀតអាចធ្វើការប្ដឹងទៅតុលាការការដើម្បីបញ្ជាក់ពីនត្ថិភាពនៃកិច្ចសន្យានោះបាន ដើម្បីបញ្ចប់នូវសិទ្ធិ ក៏ដូចជាកាតព្វកិច្ចនៅក្នុងកិច្ចសន្យានោះ។ ដូចនេះ ការបកស្រាយនេះ យើងនឹងលើកយកវិធីនៃការលុបចោលចំនួន ០២(ពីរ) មកធ្វើការបកស្រាយ ដែលយើងនឹងលើកវិធីនៃការលុបចោលតាមរយៈក្រៅផ្លូវតុលាការ និងវិធីលុបចោលតាមផ្លូវតុលាការ។

**ក.វិធីលុបចោលតាមក្រៅផ្លូវតុលាការ**

ភាគីដែលមានសិទ្ធិលុបចោល គ្រាន់តែជូនដំណឹងអំពីការលុបចោលនោះទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ហើយអានុភាពនៃការលុបចោលនឹងត្រូវកើតនៅពេលដែលការជូនដំណឹងនោះបានដល់ភាគីម្ខាងទៀត ទោះបីមិនមានការយល់ព្រមរបស់ភាគីម្ខាងទៀតក៏ដោយ។ វិធីនៃការជូនដំណឹងភាគីអាចជ្រើសរើសយកវិធីណាក៏បានដែរ ដូចជាតាមរយៈការនិយាយចំពោះមុខផ្ទាល់ ឬ និយាយតាមទូរស័ព្ទ ឬ ផ្ញើលិខិតជូនដំណឹងអំពីការបង្ហាញឆន្ទៈលុបចោលទៅភាគីម្ខាងទៀត ជាអាទ៍។ ប៉ុន្តែ

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៩, កថាខណ្ឌទី២

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៩, កថាខណ្ឌទី១

ដើម្បីការពារនៅពេលដែលមានវិវាទ ភាគីគួរតែប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការទទួលបានការជូនដំណឹងរបស់ភាគីម្ខាងទៀត។

**ខ.វិធីនៃការលុបចោលតាមផ្លូវតុលាការ**

នៅពេលមិនអាចលុបចោលតាមការព្រមព្រៀងរបស់គូភាគី នោះភាគីដែលមានសិទ្ធិលុបចោលអាចប្តឹងទាមទារតាមផ្លូវតុលាការ ដើម្បីបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យានោះ ក៏ប៉ុន្តែមិនមែនប្តឹងលុបចោលកិច្ចសន្យានោះទេ។ យោងតាមច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១ នៅពេលដែលមានបណ្តឹងចូលមកតុលាការដែលមានកម្មវត្ថុថា “សុំឲ្យតុលាការប្រកាសលុបចោលកិច្ចសន្យា” នោះតុលាការនឹងចេញសាលក្រមលើកចោលបណ្តឹង ដោយសារតែបណ្តឹងប្រភេទនេះជាបណ្តឹងផ្ទុយច្បាប់ ឬបណ្តឹងខុសច្បាប់។

## ផ្នែកទី៣. ប្រៀបធៀបសញ្ញាណទូទៅនៃការមោឃភាព និងការលុបចោល

ថ្វីត្បិតតែមោឃភាព និងការលុបចោល សុទ្ធតែជាទណ្ឌកម្មសុពលភាពនៃកិច្ចសន្យា ក៏ប៉ុន្តែបើយើងសង្កេតមើលពីលក្ខខណ្ឌផ្លូវច្បាប់ យើងនឹងឃើញពីភាពខុសគ្នារវាងមោឃភាព និងការលុបចោល។ តើមោឃភាព និងការលុបចោល មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ?

នៅក្នុងការបកស្រាយនេះ យើងនឹងលើកយកភាពខុសគ្នារវាងមោឃភាព និងការលុបចោលដែលទាក់ទងទៅនឹង លក្ខណៈវិនិច្ឆ័យនៃការមោឃភាព និងការលុបចោល ក៏ដូចជា ជនដែលអាចអះអាងអំពីការមោឃភាព និងការលុបចោល និងវិធីនៃមោឃភាព និងការលុបចោល។

### កថាខណ្ឌទី១. លក្ខណៈវិនិច្ឆ័យនៃការមោឃភាព និងការលុបចោល

ថ្វីត្បិតតែមោឃភាព និងការលុបចោល សុទ្ធតែជាទណ្ឌកម្មសុពលនៃកិច្ចសន្យា ក៏ប៉ុន្តែទណ្ឌកម្មនីមួយៗសុទ្ធតែមានលក្ខណៈវិនិច្ឆ័យខុសៗគ្នា។

**ក.លក្ខណៈវិនិច្ឆ័យនៃការមោឃភាព**

មោឃភាព ត្រូវបានបង្កើតឡើងដើម្បីធានាការពារទំនៀមទំម្លាប់ល្អរបស់សង្គម និងការពារទំនាក់ទំនងសិទ្ធិ និងផលប្រយោជន៍បុគ្គលឯកជន និងសណ្តាប់ធ្នាប់សាធារណៈដែលត្រូវបានធានាដោយច្បាប់ និងបញ្ញត្តិដែលមានលក្ខណៈជាសេចក្តីបង្គាប់សាធារណៈ។ ក្នុងនោះផងដែរមោឃភាព គឺត្រូវបានអនុវត្តចំពោះសកម្មភាពដែលមានចរិតលក្ខណៈគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ និងទណ្ឌកម្មមានលក្ខណៈស្វ័យប្រវត្តិ និងដាច់ខាត មានន័យថា សកម្មភាពដែលចាត់ទុកថាមោឃៈ គឺចាត់ទុកថា គ្មានអានុភាពតាំងពីដំបូងមកម្ល៉េះ។

### ខ.លក្ខណៈវិនិច្ឆ័យនៃការលុបចោល

លក្ខណៈវិនិច្ឆ័យនៃការលុបចោល មានលក្ខណៈខុសពីលក្ខណៈវិនិច្ឆ័យនៃការមោឃភាព ដែលការលុបចោលធានាការពារសិទ្ធិ និងផលប្រយោជន៍ត្រឹមបុគ្គលឯកជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងកិច្ចសន្យា។ ហើយការអនុវត្តគឺចំពោះតែសកម្មភាពណាដែលមានចរិតលក្ខណៈមិនធ្ងន់ធ្ងរខ្លាំង និងធានាការពារ និងសង្គ្រោះបុគ្គលដែលសុចរិត និងស្មោះត្រង់។ រីឯទណ្ឌកម្មវិញ មានលក្ខណៈមិនស្វ័យប្រវត្តិ និងមិនដាច់ខាតនោះទេ ពោលគឺសកម្មភាពដែលអាចលុបចោលនោះនៅតែមានអានុភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល ធ្វើការលុបចោលសកម្មភាពនោះ។

### កថាខណ្ឌទី២. ជនដែលអាចអះអាងអំពីការមោឃភាព និងការលុបចោល

ជនដែលអាចអះអាង គឺជាជនដែលមានសិទ្ធិក្នុងការលើកឡើងអំពីការមោឃភាព ឬ ការលុបចោល។ នៅក្នុងក្រមរដ្ឋប្បវេណីយើងក៏បានបញ្ញត្តិទុកអំពីជនណាដែលមានសិទ្ធិក្នុងការអះអាងអំពីមោឃភាព ក៏ដូចជាជនណាដែលមានសិទ្ធិក្នុងការលុបចោល។ តើជនដែលអាចអះអាងអំពីការមោឃភាព ខុសគ្នាពីជនដែលអាចអះអាងអំពីការលុបចោលយ៉ាងដូចម្តេចខ្លះ?

ជាទូទៅ ក្នុងករណីមោឃភាព ជនណាក៏មានសិទ្ធិក្នុងការអះអាងអំពីការមោឃភាពបានដែរ ក៏ប៉ុន្តែនៅក្នុងករណីមោឃភាពដោយមូលហេតុការបង្ហាញឆន្ទៈមិនពិត មានតែភាគីនៃកិច្ចសន្យា និងតតិយជនដែលមានផលប្រយោជន៍ប៉ុណ្ណោះ ដែលអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យានោះបាន ព្រោះបើយើងក្រឡេកទៅមើលផលប៉ះពាល់របស់កិច្ចសន្យាប្រភេទនេះវិញ គឺផលប៉ះពាល់របស់វាមានត្រឹមតែភាគីដែលពាក់ព័ន្ធនឹងផលប្រយោជន៍តែប៉ុណ្ណោះ។ ដោយឡែក ក្នុងករណីការលុបចោល ដោយសារតែវាមានផលប៉ះពាល់ត្រឹមតែភាគីនៃកិច្ចសន្យា និងតតិយជនដែលមានផលប្រយោជន៍ ដូចនេះ ច្បាប់ពុំបានបើកសិទ្ធិយ៉ាងទូលំទូលាយដូចករណីមោឃភាព ដែលអនុញ្ញាតឲ្យជនណាក៏មានសិទ្ធិអះអាងបានឡើយ។

ឧទាហរណ៍៖ លោក ក បានទិញទឹកអប់មួយដបពីលោក ខ ដោយនៅពេលទិញនោះ លោក ខ បានប្រាប់លោក ក ថាទឹកអប់នោះជាទឹកអប់ផលិតនៅប្រទេសបារាំង ប៉ុន្តែជាក់ស្តែងទឹកអប់នោះគ្រាន់តែជាទឹកអប់ដែលបានលាយដោយដៃលោក ខ ផ្ទាល់តែប៉ុណ្ណោះ។ ក្នុងករណីនេះយើងឃើញថា លោក ក បានទិញទឹកអប់នោះ ដោយមានការឆបោកពីលោក ខ។ ទោះបីជាមានការឆបោកក៏ពិតមែន ប្រសិនបើយើងអនុញ្ញាតឲ្យមនុស្សគ្រប់រូបសុទ្ធតែអាចអះអាងអំពីការលុបចោលកិច្ចសន្យានោះវាហាក់បីដូចជាមិនយុត្តិធម៌ទេ សម្រាប់លោក ខ ព្រោះវាគឺជាទំនាស់ផលប្រយោជន៍របស់ភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ។ បើយើងក្រឡេកមើលអំពីផលប៉ះពាល់ដែលកើតចេញពីកិច្ចសន្យានេះ វា

មានផលប៉ះពាល់ត្រឹមតែភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ដូចនេះហើយ បានជានៅក្នុងករណីការលុបចោលមានតែភាគីនៃកិច្ចសន្យា និងតតិយជនដែលមានផលប្រយោជន៍តែប៉ុណ្ណោះដែលអាចអះអាងអំពីការលុបចោលបាន។ ចំណែកឯមោឃភាពវិញ គឺដោយសារតែផលប៉ះពាល់វាមានលក្ខណៈធ្ងន់ធ្ងរ មិនត្រឹមតែភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះទេ គឺប៉ះពាល់ដល់ផលប្រយោជន៍សង្គមទាំងមូលទៀតផង ទើបជាហេតុដែលជនគ្រប់រូបសុទ្ធតែអាចអះអាងអំពីមោឃភាពនេះបាន។

**កថាខណ្ឌទី៣. វិធីនៃមោឃភាព និងការលុបចោល**

នៅក្នុងការបកស្រាយខាងលើកន្លងមក យើងបានបកស្រាយអំពីវិធីនៃមោឃភាព និងវិធីនៃការលុបចោល។ បើយើងសង្កេតមើលទៅ វិធីនៃមោឃភាព និងការលុបចោល គឺមានលក្ខណៈដូចគ្នា ទោះបីជាក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តិឲ្យបានច្បាស់អំពីវិធីនៃមោឃភាពក៏ដោយ។ វិធីនៃការមោឃភាព និងវិធីនៃការលុបចោល គឺភាគីដែលមានសិទ្ធិអះអាង គ្រាន់តែជូនដំណឹងអំពីមូលហេតុផ្លូវច្បាប់នៃមោឃភាព ឬការលុបចោលដែលបានបំពេញ ទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ដែលយើងហៅថា វិធីក្រៅផ្លូវតុលាការ។ ហើយបើភាគីម្ខាងទៀតនៅតែទាមទារឲ្យអនុវត្តកាតព្វកិច្ច ឬមិនព្រមប្រគល់តាវកាលិកដែលបានអនុវត្តរួចត្រឡប់មកវិញទេ នោះទើបភាគីដែលមានសិទ្ធិអះអាងអនុវត្តតាមវិធីមួយទៀតដែលយើងហៅថា វិធីតាមផ្លូវតុលាការ ដែលធ្វើឡើងតាមរយៈដាក់ពាក្យបណ្ដឹងទៅតុលាការ។

# ជំពូកទី ២

# អត្ថិភាពនៃមោឃភាព និងការលុបចោល នៅក្នុងដំណាក់កាល នៃកិច្ចសន្យា

# ជំពូកទី២

# អត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលនៃកិច្ចសន្យា

នៅក្នុងដំណើរការនៃការបង្កើតកិច្ចសន្យា ត្រូវបានបែងចែកចេញជា ០៣(បី)ដំណាក់កាល ដែលមានដូចជា ដំណាក់កាលមុនកិច្ចសន្យាបានបង្កើត ដំណាក់កាលបង្កើតកិច្ចសន្យា និងដំណាក់កាលអនុវត្តនៃកិច្ចសន្យា។ នៅក្នុងការបកស្រាយនេះដែរ យើងនឹងសិក្សាអំពីអត្ថិភាពនៃមោឃភាព និងការលុបចោលនៃកិច្ចសន្យា នៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចសន្យា ។

## ផ្នែកទី១. ការសិក្សានៅក្នុងដំណាក់កាលមុនកិច្ចសន្យាបានបង្កើត

ជាទូទៅ កាលបើយើងលើកឡើងពីប្រធានបទទាក់ទងនឹងកិច្ចសន្យា នោះគេតែងតែផ្តោតសំខាន់ទៅលើដំណើរការនៃការបង្កើតកិច្ចសន្យា និងដំណើរការនៃការអនុវត្តរបស់កិច្ចសន្យា។ ប៉ុន្តែយោងតាមទស្សនៈនៃការបកស្រាយមួយចំនួន ដំណាក់កាលមុនកិច្ចសន្យាលេចចេញជារូបរាង ក៏មានចំណោទបញ្ហាគតិយុត្តិដែលទាក់ទង និងជះឥទ្ធិពលទៅដល់ដំណាក់កាលនៃការបង្កើតកិច្ចសន្យាផងដែរ។ នៅក្នុងន័យនេះ ការសិក្សានៅក្នុងដំណាក់កាលមុនការបង្កើតកិច្ចសន្យានេះ ទោះបីជាផលប្រយោជន៍រវាងគូភាគីនៃកិច្ចសន្យាមិនទាន់កើតមានក៏ដោយ ប៉ុន្តែការសិក្សានេះវាពិតជាវិធីមួយដែលអាចជួយទប់ស្កាត់ការក៏កើតឡើងនៃការខូចខាត តាមរយៈការលេចឡើងនូវចំណងអានុភាពគតិយុត្តិ(កាតព្វកិច្ច) ដែលចងគូភាគីនៃកិច្ចសន្យានីមួយៗឲ្យអនុវត្តកាតព្វកិច្ច។ ដោយឈរលើសំអាងនេះ ទើបមានចម្ងល់លើកឡើងថា តើប្រព័ន្ធនៃការដាក់ទណ្ឌកម្មនៃកិច្ចសន្យាដែលរួមមាន មោឃភាព និងការលុបចោលអាចត្រូវបានប្រើប្រាស់ដែររឺទេ នៅក្នុងការសិក្សាអំពីដំណាក់កាលមុនការបង្កើតកិច្ចសន្យា? លក្ខខណ្ឌនៃការបង្កើតអានុភាពនៃកិច្ចសន្យា ជាទូទៅទាមទារឲ្យសំណើ និងស្ទីការត្រូវគ្នា[34] ដែលភាពត្រូវគ្នានេះ គឺត្រូវបានគេសិក្សាថា ជាភាពត្រូវគ្នា ០២(ពីរ) គឺភាពត្រូវគ្នានៃខ្លឹមសារនៃកិច្ចសន្យា និងភាពត្រូវគ្នានៃភាគីនៃកិច្ចសន្យា។ ដូចនេះ យើងនឹងលើកយកមកបកស្រាយនូវចំណោទបញ្ហាដែលមាននៅមុនពេលដែលភាពត្រូវនៃសំណើ និងស្ទីការកើតឡើង។ ក្នុងការបកស្រាយនេះ យើងនឹងសិក្សាអំពី **(កថាខណ្ឌទី១.)អត្ថិភាពនៃមោឃភាព និងដំណាក់កាលមុនកិច្ចសន្យាត្រូវបានបង្កើត** និង**(កថាខណ្ឌទី២.)អត្ថិភាពនៃការលុបចោល និងដំណាក់កាលមុនពេលបង្កើតកិច្ចសន្យា។**

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៦

**កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលមុនកិច្ចសន្យាបានបង្កើត**

ដូចដែលបានលើកឡើងខាងលើ ដំណាក់កាលមុនកិច្ចសន្យាត្រូវបានបង្កើត យើងនឹងលើកយកមកសិក្សាទាក់ទងនឹងមុនពេលដែលសំណើ និងស្ទីការត្រូវគ្នា។ សំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[35] ហើយវានឹងមានអានុភាពនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត[36]។ រីឯស្ទីការវិញ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[37] ហើយស្ទីការដូចនឹងសំណើដែរ នឹងមានអានុភាពនៅពេលដែលស្ទីការនោះបានទៅដល់អ្នកស្នើ[38]។ នៅក្នុងករណីនេះ យើងសាកគិតទៅមើល ប្រសិនបើនៅក្នុងដំណើរការមុនសំណើ និងស្ទីការត្រូវគ្នានេះ កម្មវត្ថុ ឬសិទ្ធិដែលមាននៅក្នុងខ្លឹមសារនៃសំណើនោះ ឬខ្លឹមសារក្នុងសំណើត្រូវបានភាគីម្ខាងទៀត(ភាគីទទួលសំណើ) កែប្រែ ហើយធ្វើឲ្យលក្ខណៈផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ទំនៀមទម្លាប់ដ៏ល្អផូរផង់ ឬសណ្ដាប់ធ្នាប់សាធារណៈ ដែលជាមូលហេតុនៃមោឃភាព ដូចនេះ ដើម្បីរារាំងកុំឲ្យមានការឆ្លើយតបនូវស្ទីការ ដែលជាហេតុធ្វើឲ្យសំណើ និងស្ទីការត្រូវគ្នា ក៏ដូចជាធ្វើឲ្យកិច្ចសន្យាមានអានុភាព តើគេអាចអះអាងនូវមោឃភាពនៅក្នុងករណីនេះបានដែរឬទេ?

- **ឧទាហរណ៍៖** លោក X មានបំណងចង់បានកូន ប៉ុន្តែដោយសារបញ្ហាវេជ្ជសាស្ត្រចំពោះប្រពន្ធរបស់គាត់ Y មិនអាចមានផ្ទៃពោះបានទេ។ តែមកទល់បច្ចុប្បន្នដោយសារវិស័យវិជ្ជសាស្ត្រមានការរីកចម្រើនរហូតដល់មានការដែលអាចពពោះជំនួសបាន លោក X ដោយដឹងបែបនេះ និងដោយសារចង់បានកូនខ្លាំងពេក បានដាក់សំណើស្នើទៅកាន់ស្ត្រី Z ដែលមានស្ថានភាពក្រីក្រ ក្នុងការពពោះជំនួសប្រពន្ធរបស់គាត់។ ក្នុងការស្នើនេះ គាត់បានសន្យាឲ្យស្ត្រី Z នូវចំនួនទឹកប្រាក់ ១០០ (មួយរយ)លានរៀល ចំពោះការពពោះនេះ។ នៅក្នុងដំណាក់ការនេះ Z មិនទាន់ផ្ដល់ការព្រមព្រៀងនៅឡើយទេ(ការធ្វើស្ទីការតប)។ ដូចនេះនៅក្នុងដំណាក់ការនេះ តើកិច្ចសន្យារវាង X និង Z អាចត្រូវបានចាត់ទុកជាមោឃៈដែរឬទេ? នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន មិនមានច្បាប់ណាបានចែងពាក់ព័ន្ធនឹងសកម្មភាពនៃការពពោះជំនួសថា ជាអំពើល្មើសច្បាប់ឲ្យបានច្បាស់លាស់នោះទេ

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៧, កថាខណ្ឌទី១

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៧, កថាខណ្ឌទី២

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៧, កថាខណ្ឌទី៣

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៧, កថាខណ្ឌទី៤

ប៉ុន្តែករណីនេះ ត្រូវបានតុលាការកម្ពុជាធ្លាប់បានចាត់នីតិវិធីចំពោះករណីនេះ ដោយផ្អែកលើហេតុផលអាជីវកម្មលើមនុស្ស[39]។ ប៉ុន្តែទោះបីជាមិនមានច្បាប់បញ្ញត្តិជាក់លាក់យ៉ាងណាក្តី ក៏ការពពោះជំនួសនេះ បើគិតពិចារណានៅក្នុងទស្សនៈសង្គម គេនឹងយល់ថា វាផ្ទុយនឹងទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ខ្មែរតាំងពីបុរាណមក ដែលគេតែងតែចាត់ទុកថា នារីជាសំពត់ក្នុងផ្ទត់ ហើយបើយើងអនុញ្ញាតឲ្យកិច្ចសន្យាប្រភេទនេះកើតឡើងមែន នោះសណ្តាប់ធ្នាប់សាធារណៈនឹងមានភាពច្របូកច្របល់តាមរយៈករណីដដែលៗនេះកើតឡើងជាច្រើននៅក្នុងសង្គម។

តាមរយៈការបកស្រាយខាងលើ វាហាក់ដូចជាមានលក្ខណៈសមហេតុផលក្នុងការអនុញ្ញាតឲ្យមានការប្រើប្រាស់មូលហេតុនៃមោឃភាពក្នុងការរារាំងកុំឲ្យសំណើ និងស្ទីការត្រូវគ្នា។ ក៏ប៉ុន្តែនៅក្នុងបញ្ហានេះមិនមានបញ្ញត្តិណាមួយបានចែងក្នុងការគាំទ្រនោះទេ ហើយយោងតាមអត្ថន័យនៃមាត្រា ៣៥៧ ការអះអាងអំពីមោឃភាពអាចធ្វើបានតែទៅលើកិច្ចសន្យាតែប៉ុណ្ណោះ មានន័យថា កិច្ចសន្យាត្រូវបានបង្កើតរួចហើយ។ មោឃភាព មិនមានវិសាលភាពដល់ស្ថានភាពមុនកិច្ចសន្យាត្រូវបានបង្កើតនោះទេ។ ម្យ៉ាងវិញទៀត ការលើកឡើងថា គួរឲ្យមានវិសាលភាពនៃមោឃភាពលាតសន្ធឹងដល់ស្ថានភាពនេះ ដើម្បីរារាំងកុំឲ្យសំណើ និងស្ទីការត្រូវគ្នាដែលជាហេតុធ្វើឲ្យកិច្ចសន្យាមិនមានអានុភាព និងបានជួយទប់ស្កាត់នូវការខាតបង់ផលប្រយោជន៍ដែលនឹងកើតមានក្នុងការអនុវត្តកាតព្វកិច្ចដោយភាគីម្ខាង[40] គឺជារឿងសមហេតុសមផល ក៏ប៉ុន្តែដោយឈរលើស្មារតីច្បាប់ ហេតុដែលមិនចាំបាច់ឲ្យមានអត្ថិភាពនៃមោឃភាពនៅក្នុងស្ថានភាពនេះ ពីព្រោះបើយើងពិចារណាទៅអានុភាពនៃមោឃភាព អាចនឹងត្រូវបកស្រាយក្នុងករណីដែលមានភាគីម្ខាងនៃកិច្ចសន្យាបានផ្តល់តាវកាលិកទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ដែលចំណុចនេះគ្រាន់តែចង់បញ្ជាក់ថា ក្នុងករណីដែលគ្មានការផ្តល់តាវកាលិកទេ មិនមានភាពចាំបាច់ ឬអត្ថប្រយោជន៍អ្វីក្នុងការបកស្រាយដែរ។ ហើយប្រសិនបើយើងអនុញ្ញាតឲ្យសំណើ និងស្ទីការត្រូវគ្នា ជាហេតុធ្វើឲ្យកិច្ចសន្យាមានអានុភាពនៅក្នុងស្ថានភាពដែលបានលើកឡើងខាងលើ ហើយភាគីបានអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាដែលមានមោឃភាពក៏ដោយ ក៏ភាគីដែលបានផ្តល់តាវកាលិកទៅឲ្យភាគីម្ខាងទៀត មានសិទ្ធិអាចទាមទារឲ្យភាគីម្ខាងទៀតផ្តល់តាវកាលិកមកខ្លួនវិញបានដែរ ដែលការទាមទារនេះ យើងបានបកស្រាយនៅខាងលើក្នុងចំណុច វិធីនៃការមោឃភាព រួចរាល់ហើយ។ ក្រៅពីនេះ មូលហេតុដែលមិនចាំបាច់ចំពោះអត្ថិភាពនៃមោឃភាពនៅក្នុងស្ថានភាពនេះ វាអាចទាក់ទងនឹងសារៈសំខាន់នៃការ

[39] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ, លេខ នស/រកម/០២០៨/០០៥, ឆ្នាំ២០០៨, មាត្រា ១២

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៨៤

ផ្តល់សច្ចានុមតិ។ ជាគោលការណ៍ ការផ្តល់សច្ចានុមតិមិនអាចធ្វើបានឡើយចំពោះកិច្ចសន្យាដែលចាត់ទុកជាមោឃៈ ប៉ុន្តែគេអាចផ្តល់សច្ចានុមតិទៅលើកិច្ចសន្យាដែលចាត់ទុកជាមោឃៈបាន លុះត្រាពេលដែលការផ្តល់សច្ចានុមតិនោះ បញ្ញត្តិដែលអនុវត្តដោយបង្ខំដែលមោឃៈកិច្ចសន្យានោះលែងមានអានុភាព ឬការវាយតម្លៃអំពីកិច្ចសន្យានោះលែងផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ[41] ដូច្នេះ ការមិនអនុញ្ញាតឲ្យមានអត្ថិភាពនៃមោឃភាពនៅក្នុងដំណាក់កាលនេះ និងអនុញ្ញាតឲ្យមានការធ្វើសំណើ និងស្វីការជាធម្មតានៅក្នុងស្ថានភាពខាងលើ ពិតជាការផ្តល់ឪកាសមួយនៅពេលណាដែលការលើកឡើងអំពីមូលហេតុនៃមោឃភាពនោះប្រែជាត្រឹមត្រូវតាមច្បាប់។

ដូចនៅក្នុងឧទាហរណ៍ខាងលើ វាអាចមានករណីដែលអាចទៅរួចថា ច្បាប់នៅក្នុងប្រទេសមួយអាចកែប្រែ និងអនុញ្ញាតឲ្យមានសកម្មភាពនេះប្រព្រឹត្តិទៅដោយស្របច្បាប់ ដោយសារប្រទេសនោះមានស្ត្រីក្នុងចំនួនមួយគួរឲ្យកត់សម្គាល់ដែលមានបញ្ហាមិនអាចមានផ្ទៃពោះបាន និងការអនុញ្ញាតបែបនេះវានឹងជួយទ្រទ្រង់កត្តាប្រជាសាស្ត្រក្នុងប្រទេសមួយនោះ ឲ្យមានតុល្យភាព ដើម្បីជួយទ្រទ្រង់វិស័យផ្សេងៗឲ្យមានការអភិវឌ្ឍន៍ ព្រោះថា ធនធានមនុស្សជាចលករយ៉ាងសំខាន់ក្នុងការទ្រទ្រង់វិស័យទាំងនោះ។

ដូចនេះ តាមរយៈបកស្រាយខាងលើ អត្ថិភាពនៃមោឃភាពពិតជាមិនមានទេ ដោយសារមិនមានសំអាងណាមួយគាំទ្រឲ្យបានពេញលេញ និងការលើកឡើងថា ការបង្ហាញអត្ថិភាពនៃមោឃភាពនៅក្នុងដំណាក់កាលមុនកិច្ចសន្យាត្រូវបានបង្កើតនេះ អាចនឹងជួយទប់ស្កាត់ទៅនឹងការខូចខាតដែលអាចកើតមាននោះ ពិតជាមិនមានអត្ថប្រយោជន៍ទេតាមរយៈការបកស្រាយខាងលើ។

### កថាខណ្ឌទី២. ការលុបចោល និងដំណាក់កាលមុនកិច្ចសន្យា

ដូចជាយើងបានដឹងហើយ កិច្ចសន្យាបង្កើត និងមានអានុភាពនៅពេលសំណើ និងស្វីការត្រូវគ្នា ឬយើងអាចនិយាយបានថា នៅពេលដែលស្វីការបានមកដល់ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ដូចនេះ មុនពេលសំណើ និងស្វីការត្រូវគ្នា យើងឃើញមានដំណើរការទៅវិញទៅមកនៃសំណើ និងស្វីការ។ នៅក្នុងចំណុចនេះ ចុះប្រសិនបើសំណើ និងស្វីការនោះធ្វើឡើងតាមរយៈមូលហេតុវិការៈដែលជាមូលហេតុនៃការលុបចោល សួរថាតើគេអាចយកមូលហេតុនោះមកធ្វើការលុបចោលសំណើ ឬស្វីកាដូចកិច្ចសន្យាបានដែរឬទេ? ជាការពិតណាស់ អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[42] ដូច្នេះ ទោះបីជាសំណើ ឬស្វីការ

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៥៧

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៤៥

ដែលជាលក្ខណៈនៃការបង្ហាញឆន្ទៈ ត្រូវបានធ្វើឡើងដោយមានមូលហេតុនៃវិការៈចូលរួមក៏ដោយ ក៏គេមិនធ្វើការលុបចោលដូចកិច្ចសន្យាបានដែរ តបតាមមាត្រាដែលបានបង្ហាញ និងភាគីអាចត្រឹមតែប្រើប្រាស់មធ្យោបាយនៃការដកសំណើ ឬការដកនូវស្នើកាតែប៉ុណ្ណោះ។ ឧទាហរណ៍៖ A មានបំណងចង់លក់ឡាន Luxus ស៊េរី២០១៦ ពណ៌ស ក្នុងតំលៃ ១២ម៉ឺនដុល្លា ប៉ុន្តែក្នុងសំណើធ្វើទៅកាន់ B ដែលជាអ្នកទិញគាត់បែរជាសរសេរថា ចង់លក់ឡាន Luxus ស៊េរី ២០១៨ ទៅវិញ។ ដូចនេះ តើគាត់អាចលុបចោលនូវសំណើនោះដោយមូលហេតុមានវិការៈនៃការបង្ហាញឆន្ទៈនៃការភាន់ច្រឡំបានដែរឬទេ? ឆ្លងតាមការធ្វើសំណើខាងលើ បើយើងអនុញ្ញាតឲ្យសំណើមានអានុភាព នោះវានឹងក្លាយជាករណីអលទ្ធភាពតាំងពីដំបូង ចំពោះ A កាលបើមានស្នើការរបស់ B ឆ្លើយតបដែលបង្កើតបានជាកិច្ចសន្យា។ មានន័យថា A ត្រង់នេះមិនអាចអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនបានទេ ក្នុងការផ្តល់តាវកាលិកនៃកិច្ចសន្យាទៅឲ្យ B ដោយធាតុពិតខ្លួនមិនមានឡាន Luxus ស៊េរី ២០១៨ នោះទេ ដូចនេះ បើ A មិនអាចលុបចោលសំណើរបស់ខ្លួនបានទេ វាហាក់ដូចជាមានហានិភ័យខ្លាំងមែនទែនចំពោះ A ក្នុងការទទួលរងនូវការខូតខាត។ ប៉ុន្តែដូចបានបកស្រាយអញ្ចឹង នៅក្នុងដំណាក់កាលនេះ ច្បាប់អនុញ្ញាតឲ្យមានត្រឹមតែការដកសំណើ ឬស្នើការប៉ុណ្ណោះ មិនមានបញ្ញត្តិណាមួយគាំទ្រឲ្យមានការលុបចោលនូវសំណើ ឬស្នើការនោះទេ ហើយការប្រើប្រាស់នូវទណ្ឌកម្មនៃកិច្ចសន្យានៃការលុបចោលនេះ ក៏មិនទាន់ហួសពេលដែរ បើយើងបង្ហាញមូលហេតុវិការៈនៃការបង្ហាញឆន្ទៈនៅពេលដែលកិច្ចសន្យាត្រូវបានបង្កើត។ ដូចនៅក្នុងឧទាហរណ៍អញ្ចឹង A មិនចាំបាច់អ្វីក្នុងការលុបចោលសំណើទេ ពោលគឺគាត់អាចបង្ហាញឆន្ទៈក្នុងការលុបចោលកិច្ចសន្យាបានដោយផ្អែកលើមូលហេតុវិការៈនៃភាន់ច្រឡំបាន ដែលអាចធ្វើឲ្យគាត់រួចផុតពីការអនុវត្តកាតព្វកិច្ច កាលបើលក្ខខណ្ឌនៃមូលហេតុវិការៈនៃភាន់ច្រឡំត្រូវបានបំពេញ។ នៅក្នុងករណីនេះ ការអះអាងអំពីការលុបចោលដែលភាគីចង់ធ្វើ និងអាចធ្វើបានរហូតដល់ពេលដំណាក់កាលនៃការបង្កើតនៃកិច្ចសន្យា។ ក៏ប៉ុន្តែការបង្ហាញឆន្ទៈដោយមានវិការៈ ភាគីដែលបានបង្ហាញនោះ ភាគច្រើនមិនបានដឹងថា ខ្លួនបានបង្ហាញខ្លួនឆន្ទៈដោយមានមូលហេតុនៃវិការៈទេ លើកលែងតែមូលហេតុនៃវិការៈនៃការគម្រាមគំហែង និងការរំលោភលើស្ថានភាព។ ដូចនេះ តាមការអនុវត្តជាក់ស្តែង មូលហេតុនៃការបង្ហាញឆន្ទៈនេះ ភាគីដែលបានបង្ហាញឆន្ទៈមានវិការៈ និងភាគីពាក់ព័ន្ធផ្សេងទៀតតែងតែលើកឡើងនៅពេលការអនុវត្តនៃកិច្ចសន្យា ដែលយើងនឹងលើកយកមកសិក្សានៅចំណុចក្រោយនេះ។

### កថាខណ្ឌទី៣. ការប្រៀបធៀបអត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលមុនពេលកិច្ចសន្យា

ឆ្លងតាមការបកស្រាយខាងលើបានបង្ហាញឲ្យឃើញច្បាស់ណាស់ថា ទាំងអត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលនៃមុនកិច្ចសន្យាត្រូវបានបង្កើតឡើង មិនអាចត្រូវបានគេយកមកអះអាងបានឡើយ ដោយសារតែទណ្ឌកម្មនៃកិច្ចសន្យាទាំង ២(ពីរ) នេះ៖

- **មោឃភាព៖** នៅក្នុងចំណុចនេះ យើងឃើញថា មូលហេតុនៃមោឃភាពដែលមានដូចជា ភាពផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ និងសណ្តាប់ធ្នាប់សាធារណៈមានហើយ ប៉ុន្តែដោយសារតែកិច្ចសន្យាមិនទាន់បានបង្កើតឡើងនៅឡើយ ជាហេតុធ្វើឲ្យមិនអាចយកមាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី មកប្រើប្រាស់បានទេ ដោយមាត្រានេះអនុវត្តបានពេលដែលកិច្ចសន្យាត្រូវបានបង្កើតឡើងហើយប៉ុណ្ណោះ។ ដោយសារតែការផ្តល់តាវកាលិកនៃកិច្ចសន្យាមិនទាន់បានអនុវត្ត នោះវាមិនមានផលប្រយោជន៍អ្វីឡើយនៅក្នុងការលើកឡើងអំពីមោឃភាព ហើយបើទោះបីជាអនុញ្ញាតឲ្យកិច្ចសន្យាកើតឡើង និងមានការផ្តល់នូវតាវកាលិកក៏ដោយ ក៏ភាគីដែលបានផ្តល់នៅតែអាចទាមទារមកវិញ តាមរយៈបញ្ញត្តិនៃវិធីនៃការមោឃភាពវិញផងដែរ។ មួយវិញទៀត មូលហេតុនៃការមិនតម្រូវឲ្យមាននូវអត្ថិភាពនៃមោឃភាពកើតឡើង គឺដោយសារតែវាពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងការផ្តល់សច្ចានុមតិ នៅក្នុងករណីដែលមូលហេតុនៃមោឃភាពដែលបានលើកឡើងនោះបានប្រែក្លាយជាស្របច្បាប់ ឬសង្គមទទួលស្គាល់វិញ។
- **ការលុបចោល៖** គេអាចលុបចោលកិច្ចសន្យាបានកាលណាមានការបង្ហាញឆន្ទៈដោយមានមូលហេតុនៃវិការៈ។ ចំណែកនៅក្នុងដំណាក់កាលមុនកិច្ចសន្យាត្រូវបានបង្កើតឡើង មិនមានបញ្ញត្តិណាដែលអនុញ្ញាតឲ្យមានការលុបចោលធ្វើឡើងចំពោះសំណើ និងស្ទីការឡើយ ពោលគឺនៅក្នុងស្ថានភាពនេះភាគីដែលបង្ហាញឆន្ទៈដោយវិការៈ អាចត្រឹមតែប្រើប្រាស់មធ្យោបាយនៃការដកសំណើ ឬស្ទីការមកវិញតែប៉ុណ្ណោះ។

## ផ្នែកទី២. ការសិក្សានៅក្នុងដំណាក់បង្កើតកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលម្នាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច[43]។ កិច្ចសន្យាមានអានុភាព កាលណាសំណើ និងស្វីការត្រូវគ្នា ហើយវាត្រូវបានបង្កើតនៅពេលដែលស្វីការ ដែលជាការយល់ព្រមនឹងសំណើ បានមកដល់ភាគីដែលជាអ្នកស្នើ[44]។ ដូចដែលបានបកស្រាយនៅចំណុចខាងដើម ការត្រូវគ្នានៃសំណើ និងស្វីការ ត្រូវបានគេសិក្សាញែកជា ០២(ពីរ) គឺភាពត្រូវគ្នានៃខ្លឹមសារកិច្ចសន្យា និងភាពត្រូវគ្នានៃភាគីនៃកិច្ចសន្យា។ ក្នុងន័យនេះ យើងសាកពិចារណាមើលថា ប្រសិនបើខ្លឹមសារនៃកិច្ចសន្យានោះមានកម្មវត្ថុដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ដ៏ល្អប្រពៃ តើគួរឲ្យកិច្ចសន្យាបន្ត និងយកទៅអនុវត្តបានដែរឬទេ? ងាយស្រួលណាស់ បញ្ញត្តិអនុវត្តដោយបង្ខំ សំដៅបញ្ញត្តិដែលមាននៅក្នុងច្បាប់ជាធរមាន ហើយច្បាប់បានបង្កើតឡើងមានគោលបំណងដើម្បីគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលនៅក្នុងសង្គម ការពារ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ចំណែកឯទំនៀមទម្លាប់វិញ គឺជាអ្វីៗដែលត្រូវបានអនុវត្តពីមុនរហូតមកទល់បច្ចុប្បន្ន ដែលរូបវន្តបុគ្គលនៅក្នុងសង្គមទទួលស្គាល់ និងគោរពតាម។ ដូច្នេះ ការដែលឲ្យកិច្ចសន្យាប្រឆាំងនឹងវិធានទាំងនេះ គឺមិនអាចទៅរួចឡើយ ពីព្រោះថា កិច្ចសន្យានេះវាបានប្រឆាំងនឹងសន្តិសុខ សណ្តាប់ធ្នាប់ ក៏ដូចជាស្មារតីរបស់រូបវន្តបុគ្គលភាគច្រើននៅក្នុងសង្គម។ មួយវិញទៀត ជួនកាលកិច្ចសន្យាមានសុពលភាពបានដោយគ្រាន់តែមានការព្រមព្រៀងគ្នាដោយផ្ទាល់មាត់ជាការស្រេច ប៉ុន្តែចំពោះកិច្ចសន្យាមួយចំនួនទៀត តម្រូវឲ្យគោរពនូវលក្ខខណ្ឌផ្សេងទៀត ដូចជាត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ឬជាលិខិតយថាភូត ឬមានការចុះបញ្ជីជាដើម ដែលលក្ខខណ្ឌទាំងនេះត្រូវបានគេហៅថា លក្ខខណ្ឌទម្រង់។ ទាក់ទងនឹងភាពត្រូវគ្នានៃកិច្ចសន្យា ពេលខ្លះកិច្ចសន្យាត្រូវបានយល់ព្រមព្រៀងគ្នាហើយ តែដោយឡែកភាគីម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យាមួយឲ្យមានសុពុលភាពនៅឡើយទេ ដូចនេះ តើអាចអនុញ្ញាតឲ្យមានកិច្ចសន្យាមានសុពលភាពយកទៅអនុវត្តយ៉ាងដូចម្តេចទៅ ពីព្រោះថា ជនមិនមានសមត្ថភាព មានន័យថា ជននោះធ្វើសកម្មភាពទាំងដែលបុគ្គលនោះមិនអាចយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់បានទេ វាចាំបាច់ណាស់ដើម្បីឲ្យការបង្ហាញឆន្ទៈនេះប្រព្រឹត្តិទៅដោយមានប្រសិទ្ធិភាព ជនដែលត្រូវបង្ហាញឆន្ទៈត្រូវមានសមត្ថភាពអាចយល់ដឹង ដើម្បីអាចឲ្យមានការការពារពីបញ្ហាប្រឈមក្នុងការបាត់បង់នូវផលប្រយោជន៍។

---

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣១១

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៦

ដូចនេះ ការដែលកិច្ចសន្យាមានអានុភាព ឬកិច្ចសន្យាដែលទើបត្រូវបានបង្កើត មិនទាន់អាចយកទៅអនុវត្តបានទេ ពោលការបង្កើតកិច្ចសន្យាទាមទារជាដាច់ខាត ត្រូវគោរពនូវលក្ខខណ្ឌសុពលភាពដែលជាលក្ខខណ្ឌគ្រឹះ និងកិច្ចសន្យាខ្លះទៀត បន្ថែមពីលើនេះ ទាមទារផងដែរក្នុងការគោរពនូវលក្ខខណ្ឌទម្រង់។ នៅក្នុងចំណុចត្រង់នេះ យើងនឹងសិក្សាអំពី **(កថាខណ្ឌទី១.)អត្ថិភាពនៃមោឃភាព និងដំណាក់កាលបង្កើតកិច្ចសន្យា (កថាខណ្ឌទី២.)អត្ថិភាពនៃការលុបចោល និងដំណាក់កាលបង្កើតកិច្ចសន្យា** និង **(កថាខណ្ឌទី៣.)ការប្រៀបធៀបអត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា។**

### កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលបង្កើតកិច្ចសន្យា

ទាក់ទងនឹងអត្ថិភាពនៃមោឃភាព នៅក្នុងដំណាក់កាលនៃការបង្កើតកិច្ចសន្យា យើងនឹងលើកឡើងនូវមូលហេតុនៃមោឃភាពដែលអាចកើតមាននៅក្នុងដំណាក់កាលនេះដូចជា **(ក.)ខ្លឹមសារផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់** និង **(ខ.)លក្ខខណ្ឌទម្រង់ដែលទាមទារ** ។

#### ក. ខ្លឹមសារផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់

ជាការពិតណាស់ ទោះបីជាដំណើរការនៃការបង្កើតកិច្ចសន្យាដោយមានការព្រមព្រៀងគ្នានៃភាគីតាមរយៈសំណើ និងស្នើការដោយគ្មានមូលហេតុវិការៈនៃការបង្ហាញឆន្ទៈក៏ដោយ កិច្ចសន្យានោះនៅតែមិនមានសុពលភាពទេ ប្រសិនបើកិច្ចសន្យានោះមានមូលហេតុនៃមោឃភាព។ យោងតាមមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ប្រសិនបើអត្ថន័យនៃសកម្មភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ នោះកិច្ចសន្យានឹងត្រូវបានចាត់ទុកថាមោឃៈ។ បន្ថែមពីលើនេះទៀត មាត្រានេះក៏បានបញ្ជាក់ថា ក្នុងការបង្ហាញពីអត្ថិភាពនៃមោឃភាព ជនណាក៏អាចលើកយកមកអះអាងនូវមោឃភាពនៃកិច្ចសន្យានោះផងដែរ ហើយជនដែលអាចអះអាងនេះ សំដៅលើជនដែលអាចលើកឡើងពីកិច្ចសន្យាដែលមានមូលហេតុនៃមោឃភាព និងជនផ្សេងទៀតដែលទទួលការអះអាងពីអ្នកដែលលើកឡើងពីមោឃភាពនោះ។ ជាការពិតណាស់ មូលហេតុដែលក្រមរដ្ឋប្បវេណីកម្ពុជា អនុញ្ញាតឲ្យជនណាក៏ដោយ ដោយមិនគិតពីប្រភេទនៃជនដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងការធ្វើការអះអាងនេះ ពីព្រោះបើយើងពិនិត្យទៅមើលមូលហេតុនៃមោឃភាពនៅក្នុងមាត្រា ៣៥៧ នេះ វាច្បាស់ណាស់បានជះឥទ្ធិពលទៅដល់ដំណើរនៃប្រទេសជាតិមួយ និងផលប្រយោជន៍រួមរបស់មនុស្សគ្រប់ៗគ្នានៅក្នុងសង្គម។

នៅក្នុងមាត្រានេះ យើងឃើញមានចែងនូវមូលហេតុនៃមោឃភាពចំនួន ០២(ពីរ) ដែលទី១ ទាក់ទងនឹងបញ្ញត្តិអនុវត្តដោយបង្ខំ។ បញ្ញត្តិអនុវត្តដោយបង្ខំ សំដៅលើបទបញ្ញត្តិច្បាប់ដែលនៅជាធរមានទាំងឡាយណាដែលបង្ខំឲ្យត្រូវតែអនុវត្តតាម ឬបើមិនដូចច្នោះទេមិនទទួលស្គាល់អានុភាពគតិយុត្តិនៃកិច្ចសន្យានោះទេ[45]។ ជាឧទាហរណ៍ ការកម្រិតការប្រាក់តាមការព្រមព្រៀង[46], ការហាមកិច្ចសន្យាបញ្ចាំផ្តាច់[47] និងកិច្ចសន្យាការងារលើសម៉ោងកំណត់ជាដើម។ មូលហេតុទី២ ដែលទាក់ទងនឹងមាត្រានេះ គឺសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ដ៏ល្អ។ យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ពាក្យថា សណ្តាប់ធ្នាប់ មានន័យថា ចារិត បែបបទ ឬក៏របៀបរបបរីឯពាក្យថា ទំនៀមទម្លាប់ មានន័យថា បវេណី ឬបែបបទ ដែលធ្លាប់មានពីមុនមក។ ដូចនេះ ប្រសិនបើច្បាប់ទទួលស្គាល់អានុភាពកិច្ចសន្យាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ នោះវាហាក់បីដូចជាច្បាប់គាំទ្រឲ្យមានស្ថានភាពដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងគាំទ្រឲ្យមានការប៉ះពាល់ដល់ទំនៀមទម្លាប់ក្នុងសង្គមដូច្នោះដែរ។ ឧទាហរណ៍ កិច្ចសន្យារួមភេទជាដើម ក្នុងកិច្ចសន្យាប្រភេទនេះ វាធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាន់ល្អ។ សាកគិតទៅមើលថា ប្រសិនបើច្បាប់ទទួលស្គាល់កិច្ចសន្យាប្រភេទនេះ ហើយភាគីប្តឹងទាមទារអនុវត្តកិច្ចសន្យាបែបនេះ នោះថាតើទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូរផង់របស់ខ្មែរ និងសណ្តាប់ធ្នាប់ក្នុងសង្គមនឹងទៅជាយ៉ាងណា?

ដូចបានបញ្ជាក់នៅក្នុងអត្ថន័យនៃពាក្យនៅក្នុងមាត្រានេះស្រាប់ វាហាក់ដូចជាមិនអាចទៅរួចដែលភាគីបានព្រមព្រៀងបង្កើតកិច្ចសន្យា និងអ្នកដែលបានដឹងឮ មិនដឹងថា ខ្លឹមសារនៃកិច្ចសន្យានោះផ្ទុយនឹងវិធានដែលបកស្រាយខាងលើ នៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា ក្នុងនាមដែលខ្លួនជារូបវន្តបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពមួយរូប។ ម្យ៉ាងទៀត ទោះបីជាភាគីនៃកិច្ចសន្យានិយាយថា មិនដឹងអត្ថន័យនៃកិច្ចសន្យាដែលផ្ទុយនឹងវិធានខាងលើក៏ដោយ ក៏វាមិនអាចទៅរួចដែរ ពីព្រោះដោយសារតែវិធានមាននៅក្នុងបកស្រាយ ដូចជាបញ្ញត្តិអនុវត្តដោយបង្ខំ វាមានលក្ខណៈដាច់ខាត និងចាប់បង្ខំ មានន័យថា រូបវន្តបុគ្គលមិនអាចបដិសេធថា ខ្លួនមិនដឹងអំពីច្បាប់បានទេ ដែលស៊ីសង្វាក់គ្នានឹងយុត្តិសាស្ត្របារាំងដែលបានចែងថា គ្មានបុគ្គលណាម្នាក់មិនអាច

---

[45] ដកសស្រង់ពី សៀវភៅបកស្រាយក្រមរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារ ដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម, ទំព័រទី០៦ បោះពុម្ពលើកទី១ នៅខែ មីនា ឆ្នាំ ២០១២។

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៥៨៥

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៨២៧

និយាយថា ខ្លួនមិនដឹងមិនឮពីច្បាប់បានឡើយ[48]។ ដូចនេះហើយ វាជាហេតុផលត្រឹមត្រូវដែលកិច្ចសន្យាមួយដែល ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ ត្រូវបានអះអាងក្នុងការមោឃភាព នៅក្នុងដំណាក់កាលនៃការបង្កើតកិច្ចសន្យា។

បានជាច្បាប់បង្កើតឲ្យមានមោឃភាពនៃកិច្ចសន្យា ពីព្រោះដើម្បីកម្រិតនូវសេរីភាពនៃការបង្កើតកិច្ចសន្យាថាមិនមែនធ្វើអ្វីក៏បាននោះទេ ទោះបីជាស្មារតីនៃក្រមរដ្ឋប្បវេណីបានចែងអំពីគោលការណ៍ស្វ័យភាពនៃបុគ្គលភាពឯកជន(សេរីភាពនៃការបង្កើតកិច្ចសន្យា) ក៏ដោយ ដែលយើងអាចចាត់ទុកថា មោឃភាពជាអញ្ញត្តិកម្មមួយនៃគោលការណ៍នេះ។ ពេលខ្លះកិច្ចសន្យាមួយចំនួនទោះបីជាបានគោរពនូវលក្ខខណ្ឌនៃមោឃភាពដូចមានចែងក្នុងមាត្រា ៣៥៧ ក៏កិច្ចសន្យាអាចនឹងត្រូវបានចាត់ទុកជាមោឃៈ អាស្រ័យលើប្រភេទនៃកិច្ចសន្យាផងដែរ។ ជាឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញអចលវត្ថុ នឹងមានអានុភាពអាចយកទៅប្រើប្រាស់បាន លុះត្រាតែមានលិខិតយថាភូត។ លក្ខខណ្ឌដែលតម្រូវនេះ ត្រូវបានគេហៅថា លក្ខខណ្ឌទម្រង់ ដែលយើងនឹងសិក្សានៅចំណុចបន្ទាប់។

### ខ. លក្ខខណ្ឌទម្រង់ដែលទាមទារ

អានុភាពនៃកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយមានសំណើ និងស្នើកាត្រូវគ្នាហើយ ប៉ុន្តែវានៅតែមិនមានសុពលភាព និងមិនអាចយកទៅអនុវត្តបាន កាលបើមិនគោរពនឹងទម្រង់ដែលច្បាប់បានកំណត់ត្រូវតែមានចំពោះកិច្ចសន្យានោះ។ តួយ៉ាង ការបង្កើតកិច្ចសន្យាជួលអចិន្រ្តៃយ៍ពុំមានអានុភាពឡើយ បើសិនជាកិច្ចសន្យាមិនបានបង្កើតក្រោមទម្រង់ជាលាយលក្សណ៍អក្សរទេ នេះពីព្រោះតែសិទ្ធិជួលអចិន្រ្តៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយល័ក្ខណ៍អក្សរ ត្រូវបានចាត់ទុកជាភតិសន្យាដែលពុំមានកំណត់កំឡុងពេលវេលា ដូចនេះហើយ អាចត្រូវបានបញ្ឈប់ដោយភាគីម្ខាងនៅពេលណាក៏បានដែរ[49]។ នៅក្នុងករណីនេះ យើងមើលឃើញគុណវិបត្តិនៃការមិនបានគោរពនូវលក្ខខណ្ឌទម្រង់ច្បាស់ណាស់ ដោយសារតែមិនបានធ្វើកិច្ចសន្យានេះជាលាយល័ក្ខណ៍អក្សរ ភាគីម្ខាងទៀតនៃកិច្ចសន្យានឹងទទួលហានិភ័យខ្ពស់ចំពោះការបញ្ឈប់ភតិសន្យាប្រភេទនេះ។ ជាឧទាហរណ៍ A បានជួលអគារមួយល្វែងឲ្យ B ក្នុងគោលបំណងបើកភោជនីយដ្ឋានជប៉ុន(ជំនួញ) ដោយបានបង្កើតកិច្ចសន្យាជួលអចិន្ត្រៃយ៍ តាមរយៈការព្រមព្រៀងដោយផ្ទាល់មាត់តែប៉ុណ្ណោះ។ ក្នុងរយៈពេលមិនដល់ ០៦ខែផង ភោជនីយដ្ឋាននោះមានអតិថិជនច្រើនមែនទែន

---

[48] en latin nemo consetur ignorare legem a été introduit au Code de Napoléon, aujourd'hui code civil, en 1804.

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ២៤៥

ដោយសារទីតាំងនោះស្ថិតនៅជិតតំបន់ដែលមានជនជាតិជប៉ុនរស់នៅច្រើន។ ដូចនេះ ស្ថានភាពហានិភ័យនោះគឺ ប្រសិនបើភតិសន្យាដែល A បានធ្វើជាមួយ B មិនត្រូវបានធ្វើជាលាយលក្ខណ៍អក្សរទេ ហើយ A ដោយមានចិត្តលោភលន់សម្លឹងឃើញតែផលប្រយោជន៍ បានបញ្ឈប់កិច្ចសន្យាជាមួយ B ដោយមានគំនិតចង់បើកភោជនីយដ្ឋាននោះដោយខ្លួនឯងវិញ នោះភាគីដែលរងគ្រោះនិងគួរឲ្យអាណិតនឹងត្រូវធ្លាក់លើ B។ ដូចនេះ ហើយបានជាក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២៤៥ វាក្យខណ្ឌ១ មិនអនុញ្ញាតឲ្យកិច្ចសន្យាប្រភេទនេះមានអានុភាពទេ។ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ យើងសូមលើកករណីនៃកិច្ចសន្យាដែលមានកម្មវត្ថុជាអចលវត្ថុមកបកស្រាយ។ ជាការពិតណាស់ ការផ្ទេរសិទ្ធិកាន់កាប់អចលវត្ថុតាមការព្រមព្រៀងមិនមានអានុភាពឡើយ បើមិនបានចុះបញ្ជី[50] ទោះបីជាមានការផ្ទេរនូវសិទ្ធិប្រត្យក្សលើអចលវត្ថុនោះដោយការព្រមព្រៀងក៏ដោយ។ ជាឧទាហរណ៍ ចំពោះករណីនៃការផ្ទេរកម្មសិទ្ធិដីតាមរយៈការលក់ទិញ X ជាអ្នកទិញ Z ជាអ្នកលក់ បានបង្កើតកិច្ចសន្យាទិញលក់ដីដោយមានការព្រមព្រៀងគ្នា ក្នុងនោះ X បានឲ្យតម្លៃដីនោះ ១០ម៉ឺនដុល្លា ក្នុងគោលបំណងបើកកសិដ្ឋាន ហើយ Z ក៏បានព្រមព្រៀងក្នុងការលក់ ប៉ុន្តែមិនបានធ្វើការចុះបញ្ជីនោះទេ ដោយភាគី X មិនមានចំណេះដឹងខាងផ្លូវច្បាប់។ នៅមុនពេលផ្ទេរកម្មសិទ្ធិដីនោះ X បានទទួលដំណឹងថា ដីរបស់គាត់ស្ថិតនៅក្នុងគម្រោងអភិវឌ្ឍន៍ ក្រោមការបណ្តាក់ទុនរបស់ក្រុមហ៊ុនជប៉ុន ហើយក៏បានលក់ដីនោះឲ្យទៅក្រុមហ៊ុនជប៉ុននោះវិញ ដោយ X បានប្រែក្រឡាស់ឈប់លក់ដីនោះឲ្យ Z ដោយប្រគល់ប្រាក់ថ្លៃទិញទៅ Z វិញ។ ក្នុងករណីវិវាទខាងលើនេះ Z ប្រាកដណាស់ មិនអាចអះអាងអំពីការធ្វើលទ្ធកម្មកម្មដីនោះចំពោះ X បានទេ ទាល់តែឆ្លងកាត់តាមការចុះបញ្ជីផ្ទេរកម្មសិទ្ធិទើបអ្នកទិញ Z អាចក្លាយទៅជាម្ចាស់កម្មសិទ្ធិលើដីនោះបាន។ នៅក្នុងឧទាហរណ៍នេះ យើងឃើញច្បាស់ហើយអំពីមូលហេតុដែលការផ្ទេរកម្មសិទ្ធិលើអចលវត្ថុ ទាមទារនូវការចុះបញ្ជីជាចាំបាច់ដាច់ខាត ក្នុងន័យនេះ ទោះបីជាមើលឃើញថា Z ទទួលបានប្រាក់ថ្លៃទិញមកវិញក៏ដោយ ក៏ការខូចខាតផលប្រយោជន៍របស់ Z អាចកើតមានដែរ ពីព្រោះវាអាចដែល Z បានចំណាយពេលវេលាក្នុងការសិក្សាគម្រោងបើកកសិដ្ឋាននៅលើទីតាំងនោះថា នឹងមានអំណោយផល ឬជួនកាល Z បានទិញ ឬកក់ នូវសម្ភារៈដែលតម្រូវឲ្យមានក្នុងការបើកកសិដ្ឋាននេះហើយ ដោយជឿជាក់លើកិច្ចសន្យាដែលបានបង្កើតនោះ។ ដូចនេះហើយ បានជាគេតម្រូវឲ្យការផ្ទេរនូវកម្មសិទ្ធិទាមទារនូវការចុះបញ្ជីដីធ្លី ដើម្បីជាលក្ខខណ្ឌតតាំងនៅពេលដែលមានវិវាទកើតឡើង។

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៣៦ កថាខណ្ឌទី២

ជាសរុបមក មូលហេតុដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសំណើ និងស្ទីការ ហើយទាមទារជាដាច់ខាតនូវលក្ខខណ្ឌទម្រង់ ពីព្រោះដោយសារតែពេលខ្លះដើម្បីឲ្យកិច្ចសន្យានោះមានភាពច្បាស់លាស់ ពេលខ្លះដោយសារកម្មវត្ថុនៃកិច្ចសន្យាមានតម្លៃជួញដូរច្រើន ឬការពារកុំឲ្យមានវិវាទ ឬប៉ះពាល់ផលប្រយោជន៍របស់ជនដែលពាក់ព័ន្ធមួយចំនួនទៀត។ ដោយសារតែសារៈសំខាន់នៃលក្ខខណ្ឌទម្រង់ដែលបានលើកឡើង ទើបច្បាប់បានកម្រិតនូវការបង្កើតកិច្ចសន្យាមួយចំនួនតម្រូវឲ្យមានលក្ខខណ្ឌទម្រង់ ទើបទទួលបានអានុភាព និងបើគ្មានលក្ខខណ្ឌនេះ កិច្ចសន្យានឹងមិនអាចបន្តយកទៅអនុវត្តបានទេ ដូចនេះ កាលបើបង្កើតកិច្ចសន្យាតម្រូវឲ្យមានលក្ខខណ្ឌទម្រង់ ហើយបើមិនបានគោរពតាម នោះគេនឹងអះអាងនូវមោឃភាពចំពោះកិច្ចសន្យានោះនៅពេលបង្កើតកិច្ចសន្យា ជាហេតុនាំឲ្យអត្ថិភាពនៃមោឃភាពកើតឡើងនៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា។

## កថាខណ្ឌទី២. អត្ថិភាពនៃការលុបចោល និងដំណាក់ការបង្កើតកិច្ចសន្យា

នៅក្នុងការបកស្រាយទាក់ទងការលុបចោល នៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា យើងនឹងលើកយកមកបកស្រាយនូវ **(ក).ជនខ្វះសមត្ថភាព** ដែលជាមូលហេតុនៃការលុបចោលដែលអាចលេចឡើងនៅក្នុងដំណាក់កាលនេះ។

### ក. ជនខ្វះសមត្ថភាព

កិច្ចសន្យាមានអានុភាពដោយសំណើ និងស្ទីការត្រូវគ្នា។ ហើយក្នុងការបង្កើតកិច្ចសន្យានោះដោយឈរលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការធ្វើកិច្ចសន្យាដោយសេរី។ ក៏ប៉ុន្តែចុះបើការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះ ធ្វើឡើងដោយជនមួយចំនួនដែលច្បាប់កម្រិតថា ជាជនខ្វះសមត្ថភាព តើការបង្ហាញឆន្ទៈអាចមានប្រសិទ្ធិភាពដែរឬទេ? តើការបង្ហាញឆន្ទៈដោយជនប្រភេទនេះក្នុងការបង្កើតកិច្ចសន្យាត្រឹមត្រូវដែរឬទេ? និងថា តើបុគ្គលនេះអាចមានបញ្ហាប្រឈម ក្នុងការបាត់បង់ផលប្រយោជន៍អ្វីខ្លះ បើអនុញ្ញាតឲ្យកិច្ចសន្យាត្រូវបានអនុវត្ត?

ជនខ្វះសមត្ថភាពសំដៅដល់បុគ្គលដែលធ្វើសកម្មភាព ដែលបុគ្គលនោះមិនអាចយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនៃអំពើរបស់ខ្លួនតាមផ្លូវច្បាប់បានទេ[51]។ ជននេះត្រូវបានបែងចែកជា

[51] **ជនខ្វះសមត្ថភាព** ដែលប្រើនៅទីនេះ គឺគ្រាន់តែជាការប្រើប្រាស់ចំណងជើងរួមមួយដែលងាយស្រួលក្នុងការបកស្រាយប៉ុណ្ណោះ ហើយការប្រើនេះ សំដៅទៅលើជនដែលខ្វះសមត្ថភាពខាងឆន្ទៈ និងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

០២(ពីរ) គឺជនដែលត្រូវបានកម្រិតសមត្ថភាព[52] និងជនដែលខ្វះសមត្ថភាពខាងឆន្ទៈ។ ជាមួយគ្នានេះដែរ ប្រភេទនៃជនទាំងពីរនេះ យើងបានធ្វើការបកស្រាយនៅក្នុងជំពូកទី១ រួចរាល់ហើយ។ យើងសាកពិចារណាទៅមើល គូភាគីនៃកិច្ចសន្យាបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះប្រាកដណាស់មានគោលបំណងក្នុងការស្វែងរកនូវផលប្រយោជន៍ចំណេញមកវិញ ឬគិតថាមានប្រយោជន៍សម្រាប់ខ្លួន។ ដូច្នេះ តើពួកគាត់ដែលជាជនខ្វះសមត្ថភាពទាំងនោះ អាចទទួលបាននូវផលប្រយោជន៍បានយ៉ាងដូចម្តេច បើពួកគាត់ជាជនដែលមិនមានសមត្ថភាពយល់ដឹងគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យា និង សូម្បីតែពេលខ្លះគ្មានសមត្ថភាពយល់ដឹងតែម្តងនូវសកម្មភាពដែលខ្លួនបានធ្វើ ឬនិយាយឲ្យចំចំណុចថា ជននោះមិនយល់ដឹងថា ខ្លួនឯងកំពុងធ្វើអ្វីផង ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីធ្ងន់ធ្ងរ។ ដូចនេះហើយ បានជាមានការបង្កើតនូវរបបសមត្ថភាពក្នុងការធ្វើសកម្មភាពដែលជារបបការពារកុំឲ្យមានការទទួលរងនូវការខូចខាតបាត់បង់ប្រយោជន៍ដែលកើតឡើង
ដោយសារកិច្ចការជួញដូររបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ដោយការមិនឲ្យជននៅក្នុងប្រភេទមួយចំនួន បង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញ។ ឧទាហរណ៍៖ A មានអាយុ ១៦ឆ្នាំ បានស្នើសុំបង្កើតកិច្ចសន្យាទិញលក់ប័ណ្ណភាគហ៊ុនដែលមានតម្លៃ ១០លានរៀលពី B ដែលជាអ្នកជំនាញក្នុងវិស័យមូលប័ត្រ ដោយ A គិតថា ការទិញប័ណ្ណភាគហ៊ុនវានឹងនាំមកនូវប្រាក់ចំណេញស្រួលៗ និង A ផ្ទាល់ មិនបានប្រាប់ឪពុកម្តាយរបស់គាត់ទេ។ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយ B យល់ព្រមលក់ប័ណ្ណភាគហ៊ុននោះទៅឲ្យ A ដូចនេះ មានន័យថា មានឆន្ទៈព្រមព្រៀងគ្នារវាង A និង B។ ជាការពិតណាស់ A មានអាយុ ១៦ឆ្នាំ ដែលនេះមានន័យថា ខ្លួនស្ថិតនៅក្នុងស្ថានភាពនៃជនដែលច្បាប់បានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ តាមការលើកឡើងខាងលើ តើវាត្រឹមត្រូវទេ ក្នុងការដែលអនុញ្ញាតឲ្យកិច្ចសន្យានេះមានសុពុលភាពមុននឹងយកទៅអនុវត្ត? ច្បាស់លាស់ណាស់ ឲ្យយកកិច្ចសន្យាទៅអនុវត្តយ៉ាងដូចម្តេច បើខណៈពេលដែល A ជាអនិតិជន ដែលសំដៅជនដែលមិនទាន់គ្រប់អាយុ ១៨ឆ្នាំ ផង។ ជាជនស្ថិតក្រោមអាយុ ១៨ឆ្នាំ មានន័យថា គាត់ស្ថិតនៅក្នុងវ័យមួយដែលមិនទាន់អាចមានសមត្ថភាពថ្លឹងថ្លែងវិនិច្ឆ័យបានច្បាស់លាស់ និងមិនមានចំណេះដឹងគ្រប់គ្រាន់ថា តើកិច្ចសន្យាដែលគាត់បានបង្កើតមានផលប៉ះពាល់ និងផលវិបាកអ្វីចំពោះខ្លួនទេ និងជាវ័យមួយដែលមានចិត្តជ្រួលជ្រើម មិនបានពិចារណាឲ្យបានវែងឆ្ងាយឡើយ។ ដូចនេះ A នៅត្រង់ចំណុចនេះពិតជាមិនអាចទៅរួចទេក្នុងការយល់ដឹងនូវចំណេះដឹងខាងផ្នែកទីផ្សារមូលប័ត្រដែលសូម្បីតែមនុស្សពេញវ័យមួយចំនួនមិនដឹងផងអំពីជំនាញនេះ។ ជាបច្ច័យ

---

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា១៦

នៅក្នុងដំណាក់កាលនេះ កិច្ចសន្យាដែលត្រូវបង្កើតរវាង A និង B នឹងត្រូវបានលុបចោលប្រសិនបើ A ឬជនដែលច្បាប់បានកំណត់ បានប្រើប្រាស់សិទ្ធិលុបចោលនោះ។

ជាសរុបមក យើងឃើញថា កាលណាកិច្ចសន្យាមួយត្រូវបានបង្កើតដោយមានភាគីជាជនខ្វះសមត្ថភាព នោះកិច្ចសន្យាដែលបង្កើតនោះនឹងអាចត្រូវបានលុបចោលវិញ ប្រសិនបើជនដែលមានសិទ្ធិលុបចោលប្រើប្រាស់សិទ្ធិលុបចោល។

### កថាខណ្ឌទី៣. ការប្រៀបធៀបអត្ថិភាពមោឃភាព និងការលុបចោលក្នុងដំណាក់កាលបង្កើតកិច្ចសន្យា

នៅក្នុងដំណាក់កាលនៃការបង្កើតកិច្ចសន្យា តាមការបកស្រាយខាងលើ វាបានបង្ហាញឲ្យឃើញថា ទាំងអត្ថិភាពនៃមោឃភាព និងការលុបចោល សុទ្ធតែអាចកើតមាននៅក្នុងដំណាក់កាលនេះ ពីព្រោះប្រភេទទណ្ឌកម្មនៃកិច្ចសន្យាទាំងពីរនេះ សុទ្ធតែមានមូលដ្ឋានច្បាប់ក្នុងការគាំទ្រដូចគ្នា។ ចំពោះមោឃភាព ដោយយោងទៅតាមមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី វាក្យខណ្ឌ១ បានចែងថា **“ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបានដែរ”** ចំណែកឯ ការលុបចោលវិញយោងតាមមាត្រា ១៤ និងមាត្រា ១៥ នៃក្រមដដែល បានចែងថា **“សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន”** និង **“ពាក្យ សកម្មភាព ដែលប្រើប្រាស់ក្នុងមាត្រានេះសំដៅដល់កិច្ចសន្យា និងសកម្មភាពឯកតោភាគី”**។ នៅក្នុងន័យនេះ កិច្ចសន្យាត្រូវបានបង្កើតហើយ ប៉ុន្តែវានឹងកើតមាននូវអត្ថិភាពនៃការមោឃភាព និងការលុបចោល ប្រសិនបើកិច្ចសន្យារងនូវមូលហេតុនៃទណ្ឌកម្មនៃកិច្ចសន្យាទាំងពីរនេះ។

ប៉ុន្តែបើយើងក្រឡេកមើល គោលបំណងនៃការបង្កើតឲ្យមានអត្ថិភាពនៃមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលនៃការបង្កើតកិច្ចសន្យា វាបានបង្ហាញឲ្យឃើញពីលក្ខណៈខុសគ្នាដូចខាងក្រោម៖

- មោឃភាព៖ កាលបើកិច្ចសន្យាមួយបានបង្កើត ដោយខ្លឹមសារនៃកិច្ចសន្យានោះ វាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ មានន័យថា កិច្ចសន្យានោះធ្វើឲ្យប៉ះពាល់នូវផលប្រយោជន៍ មិនត្រឹមតែភាគីពាក់ព័ន្ធក្នុងកិច្ចសន្យាទេ តែវាបានប៉ះពាល់នូវផលប្រយោជន៍នៃមនុស្សគ្រប់រូបនៅក្នុងសង្គមផងដែរ។ ដូចនេះ គោលបំណងនៃអត្ថិភាពនៃមោឃភាពនៅក្នុងដំណាក់បង្កើត គឺដើម្បីជួយការពារផលប្រយោជន៍រួមនៃសង្គម កុំឲ្យមានការខូតខាត ហេតុនេះហើយ

បានជាក្នុងកិច្ចសន្យាប្រភេទនេះ នរណាក៏អាចអះអាងបានដែរ មិនចាំបាច់តែជនដែលពាក់ព័ន្ធនឹងកិច្ចសន្យាទេ ហើយកាលបើកិច្ចសន្យាដែលបានបង្កើតនោះរងនូវមោឃភាព នោះវាគ្មានអានុភាពតាំងពីដំបូង ឬសុពលភាពមិនត្រូវបានទទួលស្គាល់តាំងពីដំបូងមកម្ល៉េះ ដោយភាគីមិនអាចផ្តល់សច្ចានុមតិបានទេ ទោះបីជាខ្លួនចង់បន្តកិច្ចសន្យាក៏ដោយ។

- ការលុបចោល៖ នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើត ដោយភាគីម្ខាងជាជនខ្វះសមត្ថភាព នោះសាម៉ីខ្លួន និងជនដែលច្បាប់បានកំណត់ អាចលុបចោលកិច្ចសន្យានេះបាន ដោយវាបានប៉ះពាល់ប្រយោជន៍ដល់ភាគី លើកលែងករណីជនដែលត្រូវកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឲ្យគេជឿជាក់ថា ខ្លួនជាសមត្ថជន។ គោលបំណងនៃការបង្កើតបែបនេះ វាបានអនុញ្ញាតឲ្យកិច្ចសន្យាដែលបានបង្កើត និងរងនូវមូលហេតុនៃការលុបចោលអាចបន្តបាន តាមឆន្ទៈរបស់បុគ្គលដែលពាក់ព័ន្ធ[53]។ តាមរយៈនេះចង់សំដៅថា បើគាត់ចង់ឲ្យកិច្ចសន្យាដែលបានបង្កើតនោះបន្តអនុវត្ត គាត់អាចមានជម្រើសក្នុងការផ្តល់សច្ចានុមតិ និងបើមិនចង់ទេ គាត់ក៏មានជម្រើសក្នុងការលុបចោល ដែលធ្វើឲ្យកិច្ចសន្យានោះគ្មានអានុភាពតាំងពីដំបូងមកម្ល៉េះ។

## ផ្នែកទី៣. ការសិក្សានៅក្នុងដំណាក់កាលអនុវត្តនៃកិច្ចសន្យា

នៅពេលដែលកិច្ចសន្យាបានបង្កើតឡើង នោះនឹងធ្វើឲ្យកើតមានទំនាក់ទំនងនៃសិទ្ធិលើបំណុល និងកាតព្វកិច្ចកើតឡើងរវាងគូភាគី ហើយភាគីដែលមានកាតព្វកិច្ចត្រូវតែអនុវត្តកាតព្វកិច្ចនោះ ឬនិយាយម្យ៉ាងទៀតគឺថា ភាគីនៃកិច្ចសន្យាត្រូវបានចងដោយកិច្ចសន្យា ដែលប្រការបែបនេះគឺដូចសុភាសិតច្បាប់ជាភាសាឡាតាំងដែលគេហៅថា Pacta sunt servanda (ត្រូវតែគោរពកិច្ចសន្យាជាដាច់ខាត)។ កិច្ចសន្យាដែលភាគីនៃកិច្ចសន្យាមានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក និងមានទំនាក់ទំនងជាតម្លៃតបចំពោះគ្នាទៅវិញទៅមកនេះត្រូវបានគេហៅថា កិច្ចសន្យាអញ្ញមញ្ញ។ ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់មានករណីយកិច្ចផ្ទេរវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញ(មានន័យថា អ្នកទិញមានសិទ្ធិទាមទារឲ្យអ្នកលក់ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ) ចំណែកឯអ្នកទិញមានករណីយកិច្ចបង់ថ្លៃលក់ទិញទៅឲ្យអ្នកលក់(មានន័យថា អ្នក

[53] បុគ្គលដែលពាក់ព័ន្ធត្រង់នេះ សំដៅអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ ឬសន្តិជនរបស់អ្នកដែលបង្ហាញឆន្ទៈមានវិការៈ ឬអ្នកដែលទទួលឋានៈបន្តក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈដែលមានបកស្រាយនៅក្នុងក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៥៩

លក់មានសិទ្ធិទាមទារឲ្យអ្នកទិញបង់ថ្លៃលក់ទិញ)។ ជាការពិតណាស់ កាតព្វកិច្ចរបស់ភាគីនីមួយៗខុសៗគ្នាអាស្រ័យទៅនឹងប្រភេទនៃកិច្ចសន្យា។ ឧទាហរណ៍៖ កិច្ចសន្យាខ្ចីបរិភោគ បើគ្រាន់តែឆន្ទៈឲ្យខ្ចីរបស់អ្នកឲ្យខ្ចីត្រូវគ្នាជាមួយឆន្ទៈខ្ចីរបស់អ្នកខ្ចីប៉ុណ្ណោះ កិច្ចសន្យាខ្ចីបរិភោគមិនកើតឡើងទេ ហើយអ្នកខ្ចីមិនអាចទាមទារអ្នកឲ្យខ្ចីឲ្យប្រគល់ប្រាក់មកខ្លួនបានទេ។ កិច្ចសន្យាខ្ចីបរិភោគចាប់ផ្ដើមមាននៅពេលដែលប្រាក់ត្រូវបានប្រគល់ពីអ្នកឲ្យខ្ចីទៅអ្នកខ្ចី ទៅតាមការព្រមព្រៀងរបស់អ្នកខ្ចី និងអ្នកឲ្យខ្ចី។ កិច្ចសន្យាបែបនេះ ជាកិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ សំដៅកិច្ចសន្យាដែលមានខ្លឹមសារចាំបាច់ត្រូវមានការប្រគល់ និងទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ។

យើងដឹងហើយថា ហេតុដែលធ្វើឲ្យកាតព្វកិច្ចកើតមាន គឺដោយសារតែចំនងនៃកិច្ចសន្យាដែលចងភាគីទាំងពីរ ហើយកិច្ចសន្យាកើតចេញពីសំណើ និងស្នើការត្រូវគ្នា ឬនិយាយម្យ៉ាងទៀតថា កិច្ចសន្យា គឺជាភាពត្រូវគ្នានៃការបង្ហាញឆន្ទៈ ដែលមានទិសដៅផ្ទុយគ្នា។ នៅក្នុងការបង្ហាញឆន្ទៈនេះ អ្នកក្រៅពីអ្នកបង្ហាញឆន្ទៈ ចំពោះការយល់ដឹងអំពីឆន្ទៈខាងក្នុងរបស់អ្នកបង្ហាញឆន្ទៈ ពិតជាមិនមែនជាការងាយស្រួលឡើយ វាគ្មានមធ្យោបាយផ្សេងដែលអាចស្មានយល់ដឹងអំពីឆន្ទៈខាងក្នុងបានឡើយ លើកលែងតែត្រូវបានបង្ហាញមកខាងក្រៅ។ ប៉ុន្តែក៏មានករណីដែលការបង្ហាញឆន្ទៈមកខាងក្រៅខុសគ្នាពីឆន្ទៈខាងក្នុងផងដែរ ដែលករណីនេះជាបញ្ហានៃការបង្ហាញឆន្ទៈដែលមានវិការៈ[54]។ តាមរយៈនេះទើបមានសំណួរថា នៅក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា តើអាចកើតមានមូលហេតុនៃការបង្ហាញឆន្ទៈដែលមានវិការៈដែរឬទេ? ហើយតើភាគីដែលបានបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលកិច្ចសន្យា ដើម្បីចៀសវាងនូវការអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាដែលមិនឆ្លុះបញ្ចាំងនូវឆន្ទៈពិតរបស់គាត់បានដែរឬទេ? ដូចនេះ ដើម្បីដោះស្រាយចំណោទបញ្ហានេះ នៅចំណុចបន្ទាប់យើងនឹងសិក្សាអំពី **(កថាខណ្ឌទី១.)អត្ថិភាពនៃមោឃភាពនិងដំណាក់កាលអនុវត្តកិច្ចសន្យា (កថាខណ្ឌទី២.)អត្ថិភាពនៃការលុបចោលនិងដំណាក់ការអនុវត្តកិច្ចសន្យា និង (កថាខណ្ឌទី៣.)ការប្រៀបធៀបមោឃភាពនិងការលុបចោលនៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា។**

### កថាខណ្ឌទី១. អត្ថិភាពនៃមោឃភាព និងដំណាក់កាលអនុវត្តកិច្ចសន្យា

នៅក្នុងដំណាក់កាលនេះ មូលហេតុនៃមោឃភាពដែលនឹងលេចឡើងគឺ **(ក.)ការបង្ហាញឆន្ទៈមិនពិត** ដែលយើងនឹងលើកយកមកបកស្រាយ។

[54] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយ លោកសាស្ត្រា ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ បោះពុម្ពនៅរាជធានីភ្នំពេញ ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៤

**ក. ការបង្ហាញឆន្ទៈមិនពិត**

កិច្ចសន្យាដែលមានការបង្ហាញឆន្ទៈមិនពិត សំដៅកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយមានការឃុបឃិតគ្នារវាងភាគីទាំងសងខាងនៃកិច្ចសន្យាដែលខ្លួនបានធ្វើឡើងនោះ គ្រាន់តែជាការបំភាន់ភ្នែកអ្នកដទៃទេ ហើយវាគ្រាន់តែមានលក្ខណៈជារូបភាពខាងក្រៅថា ជាអំពើស្របច្បាប់តែប៉ុណ្ណោះ។ កិច្ចសន្យាប្រភេទនេះត្រូវបានច្បាប់ចាត់ទុកថាជាមោឃៈ។ មិនត្រឹមតែភាគីទាំងពីរនៃកិច្ចសន្យាទេ ប៉ុន្តែថែមទាំងតតិយជនផងដែរ ដែលអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យានេះបាន និងការអះអាងនេះភាគច្រើនតតិយជនជាអ្នកធ្វើ ពីព្រោះថា កិច្ចសន្យាប្រភេទនេះភាគច្រើនធ្វើឡើងក្នុងការគោលបំណងដើម្បីជៀសវាងពីការរឹបអូសទ្រព្យពីសំណាក់ម្ចាស់បំណុលដែលជាតតិយជន។

កិច្ចសន្យាត្រូវបានធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត មានន័យថា គូភាគីទាំងពីរសុទ្ធតែទុច្ចរិត ដូចនេះ វាមានភាពលំបាកចំពោះតតិយជន ដូចជាម្ចាស់បំណុលជាដើម ក្នុងការដឹងអំពីការបង្ហាញឆន្ទៈមិនពិតនេះ នៅពេលដែលភាគីទាំងពីរបង្កើតកិច្ចសន្យាភ្លាមៗ ដោយតតិយជនហាក់ដូចជាមិនអាចទៅរួចទេ ក្នុងការដឹងអំពីឆន្ទៈដែលបានបង្ហាញមកខាងក្រៅដែលភាគីនោះធ្វើគ្រាន់ជាការបំភាន់ភ្នែកក្នុងគោលបំណងគេចវេសការអនុវត្តកាតព្វកិច្ចអ្វីមួយ ដូចជាជៀងវាងការរឹបអូសទ្រព្យសម្បត្តិ ក្នុងករណីមានម្ចាស់បំណុលជាដើម។ ដូចនេះហើយ បានជាការអះអាងអំពីមោឃភាពនៃការបង្ហាញឆន្ទៈមិនពិតនេះ ត្រូវបានតតិយជនភាគច្រើនធ្វើឡើងក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា។ ជាឧទាហរណ៍៖ A បានជំពាក់ប្រាក់ X ជាច្រើន ហើយមានដីដែលជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែដើម្បីជៀសវាងម្ចាស់បំណុលធ្វើការរឹបអូសដីរបស់ខ្លួន គាត់បានទៅពិភាក្សាជាមួយមិត្តភក្តិរបស់គាត់ គឺ B ហើយបានធ្វើលិខិតកិច្ចសន្យាលក់ទិញក្លែងក្លាយដែលមានអត្ថន័យប្រគល់អចលវត្ថុទៅឲ្យ B និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីរបស់ខ្លួនឲ្យទៅឲ្យ B ផងដែរ។ ដោយសារ B ក្លាយជាកម្មសិទ្ធិករនៅក្នុងសៀវភៅចុះបញ្ជី ហេតុនេះ X ដែលជាម្ចាស់បំណុលរបស់ A មិនអាចរឹបអូសដីនោះបានទេ។ ប៉ុន្តែកិច្ចសន្យាលក់ទិញ A រវាង B នេះ គឺជាកិច្ចសន្យាដែលកើតឡើងចេញពីការបង្ហាញឆន្ទៈមិនពិត ដែលត្រូវចាត់ទុកជាមោឃៈ ដូចនេះ X អាចរឹបអូសដីនោះបានក្រោយពីបានលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិពី A ទៅ B រួច[55]។ ជាការពិតណាស់ នៅក្នុងករណីនេះ វាពិតជាលំបាកណាស់ដែលម្ចាស់បំណុល X អាចដឹងថា កិច្ចសន្យាទិញលក់នោះជាកិច្ចសន្យាក្លែងក្លាយដែលកើតចេញពីការពិភាក្សាគ្នារវាង A និង B។ ហើយការដែល X បានដឹងអំពីការបង្ហាញឆន្ទៈមិនពិតនេះ លុះដល់ពេលដែលមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិនោះ ពិតជារឿងសមហេតុផល ពីព្រោះ

55 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា៤២២

រយៈពេលនៃការបង្កើតកិច្ចសន្យារហូតដល់មានការអនុវត្តកិច្ចសន្យា វាអាចធ្វើឲ្យម្ចាស់បំណុល X អាចដឹងអំពីការបង្ហាញឆន្ទៈមិនពិតនេះ។ ដូចនេះ ឆ្លងតាមការបកស្រាយខាងលើ អត្ថិភាពនៃមោឃភាពក្រោមមូលហេតុនៃការបង្ហាញឆន្ទៈមិនពិត ច្បាស់ណាស់ភាគច្រើនកើតឡើងនៅក្នុងដំណាក់កាលនៃការអនុវត្តនៃកិច្ចសន្យា។

### កថាខណ្ឌទី២. អត្ថិភាពនៃការលុបចោល និងដំណាក់កាលអនុវត្តកិច្ចសន្យា

ទាក់ទងនឹងការលុបចោលនៅក្នុងដំណាក់កាលនេះ យើងនឹងសិក្សាអំពីមូលហេតុនៃវិការៈដែលមានដូចជា ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការចំនេញហួសហេតុ ការរំលោភលើស្ថានភាព និងការគម្រាមកំហែង ដែលជនមានសិទ្ធិលុបចោល អាចបានប្រើប្រាស់សិទ្ធិនេះនៅក្នុងដំណាក់នៃការអនុវត្តកិច្ចសន្យា។ ចំពោះមូលហេតុនៃវិការៈទាំងនេះ យើងខ្ញុំសូមបែងចែកជា ២(ពីរ) ក្រុម ដោយសារតែភាពខុសគ្នានៃស្ថានភាពនៃវិការៈ។

#### ក. ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត និងការចំនេញហួសហេតុ

នៅក្នុងចំណុចនេះ យើងនឹងមិនពន្យល់ទ្រឹស្តីទូទៅទាក់ទងនឹងប្រភេទនៃការបង្ហាញឆន្ទៈវិការៈទាំងនេះលំអិតនោះទេ ដោយសារតែមានការបកស្រាយនៅក្នុងជំពូកទី១ ច្បាស់លាស់រួចហើយ។ ចំពោះវិការៈដែលបានលើកឡើងខាងលើនេះ មូលហេតុដែលយកមកបកស្រាយរួមគ្នាពីព្រោះតែភាគីដែលបានបង្ហាញឆន្ទៈដោយវិការៈប្រភេទទាំងនេះ ពិតជាមិនបានដឹងថា ខ្លួនបានបង្ហាញឆន្ទៈនៅពេលបង្កើតកិច្ចសន្យាដោយមានវិការៈនោះទេ។

ចំពោះមូលហេតុនៃការភាន់ច្រឡំមានន័យថា យល់ច្រឡំអំពីខ្លឹមសារនៃកិច្ចសន្យាដោយខ្លួនឯង ដែលវាជាមូលហេតុដែលបង្កើតនូវឆន្ទៈខាងក្នុង ហើយភាគីបានបង្ហាញឆន្ទៈខាងក្នុងនោះមកខាងក្រៅ ដែលនាំឲ្យការបង្ហាញឆន្ទៈនោះខុសពីឆន្ទៈពិត[56]។ ការឆបោកវិញ វាដូចគ្នាទៅនឹងការភាន់ច្រឡំដែរ គ្រាន់តែការឆបោក គឺជាការយល់ច្រឡំក្រោមឥទ្ធិពលដោយសារការបោកប្រាស់ បញ្ឆុះបញ្ចូលដោយភាគីម្ខាងទៀត ឬតតិយជន[57]។ ចំណែកឯពត៌មានមិនពិតមានន័យថា ពេលដែលបង្កើតកិច្ចសន្យា ហេតុដែលបានបង្ហាញដោយភាគីម្ខាងខុសពីការពិត ហើយភាគីនេះបានបង្ហាញ

[56] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី ២២

[57] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី ៣២

ឆន្ទៈដោយជឿជាក់ថា ហេតុទាំងនេះជាការពិត ហើយប្រសិនបើភាគីនោះដឹងថា មិនមែនជាការពិត ខ្លួននឹងមិនបង្ហាញទេ[58]។ ចុងក្រោយទាក់ទងនឹង ការកេងចំណេញហួសហេតុ សំដៅករណីដែលភាគីបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតមិនមានជំនាញ ឬភាពល្ងង់ ឬការខ្វះបទពិសោធន៍ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីសន្យានោះ[59]។

**ឧទាហរណ៍ទី១** (ករណីការភាន់ច្រឡំ) A បានបង្កើតកិច្ចសន្យាលក់ទិញផ្លែប៉ោមជាមួយនឹង B ដោយសារតែ A ភាន់ច្រឡំថា ខ្លួនបានបរិភោគប៉ោមដែលមាននៅផ្ទះរបស់ខ្លួនអស់ហើយ ប៉ុន្តែធាតុពិតនៅផ្ទះរបស់ខ្លួននៅសល់ផ្លែប៉ោម ៣០ផ្លែទៀតឯណោះ។ ការភាន់ច្រឡំនេះ គឺជាការភាន់ច្រឡំបានកើតឡើងនៅក្នុងដំណាក់កាលបង្កើតកិច្ចសន្យា។ ក្នុងករណីនេះ A អាចលុបកិច្ចសន្យាចោលបាន ដោយសារតែការភាន់ច្រឡំនោះជាចំណុចសំខាន់នៃកិច្ចសន្យា ហើយ B ក៏អាចស្ថិតនៅក្នុងស្ថានភាពដែលអាចយល់ដឹងអំពីចំណុចនេះដែរ ពីព្រោះ A ទើបតែបានទិញផ្លែប៉ោមពីខ្លួនកាលពី ២សប្តាហ៍មុននោះទេ។ ដូចនេះ លក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ។

**ឧទាហរណ៍ទី២** (ករណីការឆបោក) បុគ្គលិករបស់ហាងម៉ូតូ X បានបញ្ឆោះបញ្ចូលអតិថិជនឲ្យជឿថា ម៉ូតូនេះផលិតដោយ ក្រុមហ៊ុន A ដែលជាម៉ូតូកំពុងពេញនិយម ទាំងដឹងថា ការពិតម៉ូតូនេះគឺផលិតផលរបស់ ក្រុមហ៊ុន B ហើយអតិថិជនក៏បានជឿ និងបានទិញម៉ូតូនេះ។ នៅក្នុងករណីនេះ អតិថិជនអាចលុបចោលកិច្ចសន្យាដោយផ្អែកលើការឆបោកបាន។

**ឧទាហរណ៍ទី៣** (ករណីពតិមានមិនពិត) ហាងគំនូរ B បានយល់ច្រឡំថា គំនូររូបអង្គរធំ ជាគំនូររូបអង្គរវត្ត ហើយក៏បានបិទអក្សរថា រូបអង្គរវត្ត។ A ដែលជឿជាក់លើអក្សរដែលបិទនោះ ក៏ទិញគំនូរនោះ។ ក្នុងករណីនេះ ប្រសិនបើ A បានដឹងថា គំនូរនោះមិនមែនជាគំនូររូបអង្គរវត្តនោះគាត់មិនទិញទេ នោះ A អាចលុបចោលកិច្ចសន្យានោះបាន ដោយផ្អែកលើពតិមានមិនពិតបាន។

**ឧទាហរណ៍ទី៤** (ករណីអំពើកេងយកចំនេញហួសហេតុ) A ជាអ្នកដឹកអ្នកដំណើរ បានឆ្លៀតឪកាសពេល B ដែលទើបមកដល់ប្រទេសកម្ពុជាជាលើកដំបូង ហើយមិនបានដឹងអ្វី ដោយបាននិយាយតម្លៃចំពោះការផ្លាស់ទីក្នុងចម្ងាយដែលជាធម្មតាមានតម្លៃ ១០ដុល្លា ថា មានតម្លៃ ១០០ដុល្លា។ នៅពេលធ្វើដំណើរតាមផ្លូវ B បានដឹងតម្លៃសមរម្យ ហើយគិតថា ពេលទៅដល់ទិសដៅ

---

[58] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី៣៩

[59] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី៤០

ហើយ មិនចង់បង់ប្រាក់ច្រើនដល់ទៅ ១០០ដុល្លា នេះទេ។ ក្នុងករណីនេះ B អាចលុបចោលកិច្ចសន្យាជាមួយ A ដោយមូលហេតុការកេងយកចំណេញហួសហេតុ ហើយបដិសេធមិនបង់ប្រាក់ ១០០ដុល្លា នោះបាន ដោយបង់ត្រឹមតម្លៃធម្មតា ១០ដុល្លា នោះប៉ុណ្ណោះ។

យើងដឹងហើយថា កាលបើកិច្ចសន្យាមានវិការៈនៃការបង្ហាញឆន្ទៈ ដូចបានលើកឡើងទាំងប៉ុន្មាននេះ នោះភាគីអាចប្រើប្រាស់សិទ្ធិលុបចោលក្នុងការលុបចោលកិច្ចសន្យានោះបាន ដើម្បីបញ្ឈប់នូវសុពលភាពនៃកិច្ចសន្យានោះ មួយវិញទៀតភាគីដែលបានបង្ហាញឆន្ទៈដោយមូលហេតុនៃវិការៈនេះ ពិតណាស់មិនបានដឹងអំពីមូលហេតុនេះទេ បើដឹងគាត់ក៏មិនបង្ហាញឆន្ទៈដែលខុសពីឆន្ទៈពិតរបស់គាត់ក្នុងការបង្កើតកិច្ចសន្យានេះដែរ ដូចនេះ ការប្រើប្រាស់សិទ្ធិក្នុងការលុបចោលកម្រកើតឡើងនៅក្នុងដំណាក់កាលនៃការបង្កើតកិច្ចសន្យាភ្លាមៗនេះណាស់ ពីព្រោះវាពិតជាលំបាកសម្រាប់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈនោះយល់ដឹងភ្លាមៗនូវមូលហេតុនៃវិការៈដែលមាននៅក្នុងការបង្ហាញឆន្ទៈរបស់ខ្លួន ឬអាចនិយាយបានថា ទើបនឹងបង្កើតកិច្ចសន្យា ហើយបានដឹងពីវិការៈកើតមាននៅក្នុងការបង្ហាញឆន្ទៈខ្លួនភ្លាម និងបានលុបចោលកិច្ចសន្យានោះភ្លាមៗ។ ម្យ៉ាងទៀតយើងដឹងហើយថា ការបង្ហាញឆន្ទៈដោយមានវិការៈទាំងនេះលើកលែងតែការភាន់ច្រឡំមួយចេញ សុទ្ធតែរងនូវឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅ ដូចជាការឆបោកជាដើម ពោលគឺភាគីបានបង្ហាញឆន្ទៈខុសពីការពិតដោយសារតែមានការបោកប្រាស់ពីអ្នកពីភាគីម្ខាងទៀត ឬតតិយជន ដូចនេះ ជាការលំបាកក្នុងការយល់ដឹងអំពីការបោកប្រាស់នោះ ហើយវាជាភាពត្រឹមត្រូវដែលភាគីដឹងអំពីមូលហេតុវិការៈភាគច្រើននៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា ហើយប្រើប្រាស់សិទ្ធិលុបចោលនៅក្នុងដំណាក់កាលនេះ ដោយសារតែវាអាចផ្តល់ពេលវេលាគ្រប់គ្រាន់ទៅដល់ភាគីរងគ្រោះក្នុងការស្វែងយល់ថា ការបង្ហាញឆន្ទៈរបស់ខ្លួនមានវិការៈ។ ដូចនៅក្នុងឧទាហរណ៍ទី២ អញ្ចឹង បើសិនជាអតិថិជនបានដឹងថា ការបញ្ចុះបញ្ចូលរបស់ X ជាការបោកប្រាស់នោះ អតិថិជនក៏មិនទិញម៉ូតូនោះដែរ ពោលគឺយើងអាចនិយាយថា អតិថិជននោះនៅក្នុងពេលដែលបង្កើតកិច្ចសន្យាទិញម៉ូតូច្បាស់ណាស់ថា គាត់មិនបានដឹងអំពីមូលហេតុនៃវិការៈទេ ដូច្នេះ គាត់ក៏នឹងមិនប្រើសិទ្ធិលុបចោលកិច្ចសន្យានេះដែរ។ នៅក្នុងករណីនេះ នៅពេលដែលអតិថិជនបានទិញម៉ូតូពីហាង X រួចហើយទើបគាត់បានដឹងថា X បានឆបោកខ្លួន ដោយដឹងថា ម៉ូតូនោះជាម៉ូតូក្រុមហ៊ុន B មិនមែនជាម៉ូតូក្រុមហ៊ុន A នោះទេ ដូចនេះ មានន័យថា អតិថិជនបានអនុវត្តកាតព្វកិច្ចដោយប្រគល់ប្រាក់ក្នុងការទិញម៉ូតូនោះរួចហើយ ជាហេតុដែលយើងអាចទាញបានថា ក្នុងការលុបចោលកិច្ចសន្យានេះ គាត់បានប្រើសិទ្ធិលុបចោលនៅក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា។ គួរបញ្ជាក់ផងដែរថា ចំពោះឧទារហាណ៍ដទៃទៀតមានលំនាំក្នុងការបកស្រាយដូចគ្នានឹងឧទាហរណ៍ទី២ នេះដែរ។

### ខ. ការរំលោភលើស្ថានភាព និងការគម្រាមកំហែង

នៅក្នុងចំណុចនេះ យើងក៏មិនលើកយកមកបកស្រាយឲ្យបានលំអិតទៅនឹងទ្រឹស្តីទូទៅនៃប្រភេទនៃវិការៈទាំងពីរនេះដែរ ដោយសារតែមានបញ្ជាក់នៅក្នុងជំពូកទី១ បានច្បាស់លាស់ហើយ។ មូលហេតុដែលយើងលើកយកប្រភេទនៃវិការៈនេះមកបកស្រាយរួមគ្នា ដោយសារតែភាគីដែលបង្ហាញឆន្ទៈដោយមានវិការៈនេះ បានបង្ហាញឆន្ទៈក្នុងបង្កើតកិច្ចសន្យាដោយដឹងថា ការបង្ហាញឆន្ទៈនេះខុសពីឆន្ទៈពិតរបស់ខ្លួន តែខ្លួននៅតែបន្តបង្កើតកិច្ចសន្យានេះទៀត ដោយសារតែមានការគាបសង្កត់ក្នុងការបង្ហាញឆន្ទៈពីមជ្ឈដ្ឋានខាងក្រៅ។

ការរំលោភលើស្ថានភាព មានន័យថា ភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចតបប្រឆាំងបានទេ[60]។ ឧទាហរណ៍ទី១៖ A បានជួលដី X ពីក្រុមហ៊ុនអចលវត្ថុ B ដើម្បីរៀបចំតូបតូចមួយសម្រាប់ជីវភាពប្រចាំថ្ងៃ។ កន្លងមកកិច្ចសន្យាជួលត្រូវធ្វើជារៀងរាល់ឆ្នាំ ហើយឆ្នាំនេះ A សង្ឃឹមថា ប្រាកដជាធ្វើសារជាថ្មីដូចសព្វដង។ ប៉ុន្តែ B ដឹងថា A នឹងមិនអាចបន្តជីវភាពបានទេ បើមិនធ្វើកិច្ចសន្យាថ្មី ដូចនេះ A នឹងមិនហ៊ានប្រកែកជាមួយនឹងការពឹងពាក់របស់ B ទេ។ ហេតុនេះ B បាននិយាយប្រាប់ A ថាបើ A ឲ្យខ្ចី ១០០០ដុល្លា នោះទើបព្រមធ្វើកិច្ចសន្យាថ្មី។ A នឹងមិនអាចបន្តជីវភាពបានទេ បើ B មិនធ្វើកិច្ចសន្យាថ្មី។ ដូចនេះ A អស់ជម្រើស ក៏បានឲ្យប្រាក់ទៅ B ខ្ចីចំនួន ១០០០ដុល្លា។ ដូចនេះ A អាចលុបចោលកិច្ចសន្យាខ្ចីប្រាក់ ដោយផ្អែកលើការរំលោភលើស្ថានភាពនេះបាន។ ចំណែកឯការគម្រាមកំហែងវិញ សំដៅការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជន[61]។ ជាឧទាហរណ៍៖ A បាននិយាយទៅកាន់ B ថា "បើមិនចង់ស្លាប់ទេ ឆាប់ទិញថូបុរាណនេះក្នុងតម្លៃ ១០០០០ដុល្លា ទៅ" ដូចនេះ បើ B ទិញថូបុរាណនេះក្នុងតម្លៃ ១០០០០ដុល្លា ដោយសារមានការភ័យខ្លាចនេះមែន នោះ B អាចលុបចោលកិច្ចសន្យាដោយផ្អែកលើការគម្រាមកំហែងបាន។

ដូចទ្រឹស្តីខាងលើបានលើកយកមកបញ្ជាក់ហើយថា នៅពេលដែលភាគីបានបង្ហាញឆន្ទៈដោយមានវិការៈដូចជា ការរំលោភលើស្ថានភាព ការគម្រាមកំហែង គឺភាគីនោះបានដឹងថា មាន

---

[60] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី៣៦

[61] ដកស្រង់ចេញពី សៀវភៅមេរៀនពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគី១ ដែលរៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥, ទំព័រទី៣៨

វិការៈតាំងពីនៅក្នុងដំណាក់បង្កើតកិច្ចសន្យាមកម្ល៉េះ តែភាគីនោះនៅតែបន្តបង្ហាញឆន្ទៈដែលខុសពីឆន្ទៈពិតរបស់ខ្លួនទៀត ដោយមានឥទ្ធិពលក្រោមការបង្ខិតបង្ខំ គាបសង្កត់ពីសំណាក់មជ្ឈដ្ឋានខាងក្រៅ។ នៅក្នុងន័យនេះ យើងអាចទាញបានថា ពេលដែលបង្កើតកិច្ចសន្យានោះ ភាគីប្រាកដណាស់នឹងមិនបង្ហាញឆន្ទៈថាមានវិការៈ ហើយលុបចោលកិច្ចសន្យាភ្លាមៗនោះទេ ដោយសារភាគីខ្លាចមានផលប៉ះពាល់ផលប្រយោជន៍ ឬសន្តិសុខខ្លួនផ្ទាល់ ដោយសារការគាបសង្កត់ ឬការបង្ខិតបង្ខំ ឬគម្រាមកំហែង។ ដូចនេះ យើងអាចសន្និដ្ឋានបានថា នៅក្នុងករណីនៃវិការៈខាងលើ ភាគីភាគច្រើនបានបង្ហាញឆន្ទៈក្នុងការលុបចោលកិច្ចសន្យារបស់ខ្លួននៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា។ ដូចនៅក្នុងឧទាហរណ៍ទី១ A យល់ព្រមបង្កើតកិច្ចសន្យាខ្ចីជាមួយ B ដោយសារតែខ្លួនគ្មានជម្រើសដើម្បីឲ្យ X បន្តកិច្ចសន្យាជួល ដូចនេះ ក៏បានយល់ព្រមឲ្យ X ខ្ចីប្រាក់ ១០០០ដុល្លានោះ ទាំងដែលខ្លួនមិនចង់។ នៅក្នុងករណីនេះ A នៅពេលបង្កើតកិច្ចសន្យាច្បាស់ណាស់នឹងមិនបង្ហាញឆន្ទៈវិការៈ ហើយលុបចោលកិច្ចសន្យានោះភ្លាមៗនោះទេ បើខ្លួនធ្វើដូច្នេះខ្លួននឹងបាត់បង់ការធ្វើបន្តកិច្ចសន្យាជួលពី X ដែលនាំឲ្យខ្លួនខូចប្រយោជន៍ ប៉ុន្តែគាត់អាចនឹងបង្ហាញឆន្ទៈលុបចោលកិច្ចសន្យានោះ នៅពេលដែលការគាបសង្កត់ក្រោមរូបភាពនេះលែងមានតទៅទៀត។ ដូចនេះហើយ បានជាការលុបចោលកិច្ចសន្យាក្នុងករណីវិការៈដែលបានលើកឡើងខាងលើ ភាគច្រើនកើតនៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា ដែលជាហេតុធ្វើឲ្យអត្ថិភាពនៃការលុបចោលមាននៅក្នុងដំណាក់ការនេះ។

**កថាខណ្ឌទី៣. ការប្រៀបធៀបមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា**

តាមរយៈការបកស្រាយខាងលើ ពិតណាស់អត្ថិភាពនៃមោឃភាព និងការលុបចោលអាចកើតមានក្រោមរូបភាពមូលហេតុនៃវិការៈដែលបានលើកឡើង។ នៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា អត្ថិភាពនៃមោឃភាព និងអត្ថិភាពនៃការលុបចោល សុទ្ធតែកើតចេញពីវិការៈនៃការបង្ហាញឆន្ទៈដែលមានចែងនៅក្នុងមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា។ អ្វីដែលយើងជាឃើញចំណុចរួមនៃអត្ថិភាពមោឃភាព និងការលុបចោលនៅក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា គឺថាមូលហេតុនៃវិការៈនៃអត្ថិភាពទាំងពីរនេះ សុទ្ធតែបានកើតតាំងពីដំណាក់កាលបង្កើតកិច្ចសន្យាមកម្ល៉េះ ប៉ុន្តែភាគីមិនបានប្រើសិទ្ធិលុបចោលកិច្ចសន្យានៅក្នុងដំណាក់កាលនេះទេ ដោយសារតែវាមិនមែនជាភាពងាយស្រួលទេ សម្រាប់ភាគី និងតតិយជន(ករណីការបង្ហាញឆន្ទៈមិនពិត) អាចស្វែងយល់ថា មានវិការៈក្នុងការបង្ហាញឆន្ទៈនៅពេលដែលបង្កើតកិច្ចសន្យានោះភ្លាមៗ ដែលក្នុងស្ថានភាពនេះវាទាមទារនូវពេលវេលាក្នុងការយល់ដឹងនូវវិការៈទាំងនោះ និងករណីខ្លះទៀត(ការរំលោភលើស្ថានភាព និងការគម្រាមកំហែង) ភាគីដឹងថា ការបង្ហាញឆន្ទៈនោះខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួនដែរ

ប៉ុន្តែដោយសារក្រោមឥទ្ធិពលនៃការគាបសង្កត់ បង្ខិតបង្ខំ ដែលនាំឲ្យខូចខាតនូវផលប្រយោជន៍ និងសន្តិសុខរបស់ភាគី ទើបខ្លួននៅតែបន្តព្រមបង្កើតកិច្ចសន្យាទាំងខ្លួនមិនចង់ ដែលនៅក្នុងស្ថានភាពនេះវាទាមទាររយៈពេលដើម្បីឲ្យឥទ្ធិពលនោះលែងមានតទៅទៀត។

ទាក់ទងនឹងអត្ថិភាពទាំងពីរនេះដែរ យើងឃើញថា មានភាពខុសគ្នាចំពោះសមាសភាពអ្នកដែលបានអះអាង។ ចំពោះការបង្ហាញឆន្ទៈមិនពិត ដែលកើតឡើងក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា តតិយជនភាគច្រើនគឺជាអ្នកដែលអះអាងអំពីមោឃភាព ពីព្រោះថា គាត់ភាគច្រើនមានផលប្រយោជន៍ក្នុងកិច្ចសន្យាដែលបង្ហាញឆន្ទៈមិនពិតនោះ ដោយសារកិច្ចសន្យាបង្ហាញឆន្ទៈមិនពិត គឺគូភាគីមានការឃុបឃិតគ្នា ជាហេតុដែលថាគាត់នឹងអះអាងអំពីមោឃភាពនោះដោយខ្លួនឯងវាហាក់ដូចជាមិនអាចទៅរួចទេ និងមួយទៀតផងដែរ កិច្ចសន្យាមានលក្ខណៈបែបនេះវាមានភាពអាក្រក់ខ្លាំង ដែលធ្វើឲ្យប៉ះពាល់ដល់សីលធម៌របស់សង្គម។ ចំណែកឯមូលហេតុវិការៈដទៃទៀតលើកលែងការបង្ហាញឆន្ទៈមិនពិតមួយចេញ ដែលបានកើតឡើងនៅក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា អ្នកដែលអះអាងអំពីវិការៈទាំងនេះសុទ្ធសឹងតែជាភាគីដែលបង្ហាញឆន្ទៈមានវិការៈផ្ទាល់ និងជនដែលមានចែងនៅក្នុងមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី តែប៉ុណ្ណោះ។ នេះក៏ព្រោះតែកិច្ចសន្យាបែបនេះវាប៉ះពាល់តែផលប្រយោជន៍របស់គូភាគីតែប៉ុណ្ណោះ ដូចនេះហើយ បានជាទុកភារៈនេះឲ្យភាគី និងជនដែលបានចែងនៅក្នុងមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី អះអាង។

# ជំពូកទី ៣

# អនុភាពនៃមោឃភាព និងការលុបចោល

# ជំពូកទី៣

# អានុភាពនៃមោឃភាព និងការលុបចោល

នៅពេលដែលកិច្ចសន្យាមួយ បានបង្កើតឡើងដោយមិនគោរពនូវលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យានោះយើងឃើញថា ទណ្ឌកម្មនៃលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចំនួន ០២(ពីរ) នឹងកើតឡើង ដែលមានអានុភាពទៅតាមប្រភេទនៃទណ្ឌកម្មនីមួយៗ។

## ផ្នែកទី១. អានុភាពនៃការមោឃភាព

នៅពេលដែលកិច្ចសន្យាមួយត្រូវបានទទួលស្គាល់ថា មោឃភាព នោះមោឃភាពនឹងកើតឡើងទៅលើកិច្ចសន្យានោះ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីមិនបានបញ្ញត្តិអំពីអានុភាពនៃមោឃភាពនៃកិច្ចសន្យានោះទេ គឺគ្រាន់តែបានបញ្ញត្តិថា សកម្មភាពនោះត្រូវបានចាត់ទុកជាមោឃៈតែប៉ុណ្ណោះ។ អានុភាពនៃមោឃភាពនៃកិច្ចសន្យា នឹងត្រូវបកស្រាយនៅក្នុងករណីដែលមានភាគីម្ខាងនៃកិច្ចសន្យាបានផ្តល់តាវកាលិកទៅឲ្យភាគីម្ខាងទៀតនៃកិច្ចសន្យា។ ដូចនេះ ក្នុងករណីដែលគ្មានការផ្តល់តាវកាលិកទេ នោះមិនចាំបាច់បកស្រាយពីអានុភាពនៃមោឃភាពឡើយ ហើយវាក៏មិនមានផលប្រយោជន៍អ្វីក្នុងការបកស្រាយដែរ។ ប៉ុន្តែប្រសិនបើភាគីបានអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាដែលមោឃៈ នោះអានុភាពនៃមោឃភាពនឹងត្រូវកើតមានឡើង។ ហើយបើយើងនិយាយអំពីអានុភាពគតិយុត្ត ប្រាកដណាស់វានឹងលេចចេញនូវអានុភាពចំពោះភាគីដែលពាក់ព័ន្ធ។

### កថាខណ្ឌទី១.អានុភាពចំពោះភាគីនៃកិច្ចសន្យា

ស្ថិតក្នុងការបកស្រាយអំពីមោឃភាពនៃកិច្ចសន្យានោះ ភាគីដែលបានផ្តល់តាវកាលិកទៅឲ្យភាគីម្ខាងទៀតនោះដែលផ្អែកលើកិច្ចសន្យាដែលមោឃភាព ភាគីដែលបានផ្តល់តាវកាលិកមានសិទ្ធិអាចទាមទារឲ្យភាគីម្ខាងទៀតផ្តល់តាវកាលិកមកឲ្យខ្លួនវិញបាន។ ក៏ប៉ុន្តែនៅក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឲ្យសងនោះពុំត្រូវបានអនុញ្ញាតឡើយ[62]។ ក្នុងករណីដែលភាគីអាចទាមទារកម្មវត្ថុនៃកាតព្វកិច្ច(តាវកាលិក) ដែលភាគីបានអនុវត្តរួចមកវិញ ក៏ត្រូវតែមានមូលហេតុគតិយុត្តិក្នុងការទាមទារត្រលប់មកវិញផងដែរ។ ការទាមទារនេះដែរ អាចធ្វើទៅបានដោយ

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៧៤១

ផ្អែកតាមបញ្ញត្តិស្តីពី សេចក្តីចម្រើនដោយឥតហេតុ ឬ តាមបញ្ញត្តិស្តីពី សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិក៏បានដែរ អាស្រ័យលើភាពងាយស្រួល និងស្ថានភាពជាក់ស្តែងក្នុងការទាមទារនោះ។

**កថាខណ្ឌទី២. អានុភាពចំពោះតតិយជន**

អានុភាពនៃមោឃភាពចំពោះតតិយជនក្នុងករណីខ្លះមានចរិតលក្ខណៈដាច់ខាត ក្នុងករណីខ្លះទៀតមិនមានលក្ខណៈដាច់ខាតនោះទេ ព្រោះកិច្ចសន្យាដែលចាត់ទុកថា មោឃៈនោះ អាចមានអានុភាពវិញ ដោយផ្អែកទៅលើមូលហេតុដែលនាំឲ្យមោឃភាពនោះ។

**ក.ក្នុងករណីមោឃភាពដោយមូលហេតុទាក់ទងនឹងអត្ថន័យ និងលក្ខខណ្ឌទម្រង់នៃកិច្ចសន្យា**

ក្នុងករណីដែលកិច្ចសន្យាមួយត្រូវចាត់ទុកថាជាមោឃៈដោយមូលហេតុទាក់ទងនឹងអត្ថន័យ ឬ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាដែលទាមទារ វាជាមូលហេតុនៃមោឃភាពដែលមានចរិតលក្ខណៈដាច់ខាតដែលនាំឲ្យកិច្ចសន្យានោះដាច់ខាតត្រូវចាត់ទុកថាមោឃៈ មិនអាចមានសុពលភាពបានឡើយ។ ហេតុនេះហើយ កិច្ចសន្យានេះក៏អាចអះអាងជាមួយតតិយជនបានដែរ ហើយជាការបកស្រាយ ទោះបីជាតតិយជននោះសុចរិត និងគ្មានកំហុសក៏ដោយ ក៏មិនមានការការពារដែរ[63]។

**ខ.ក្នុងករណីការបង្ហាញឆន្ទៈមិនពិត**

នៅក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត កិច្ចសន្យានេះគឺមិនបានផ្ទុយច្បាប់នោះទេ ក៏ប៉ុន្តែវាមិនត្រូវបានគេទទួលស្គាល់ថាមានអានុភាពនោះទេ ព្រោះភាគីដែលបានបង្ហាញឆន្ទៈនោះដឹងច្បាស់ខ្លួនឯងថា ឆន្ទៈដែលបានបង្ហាញនោះមិនពិតឡើយ។ ក៏ប៉ុន្តែគេចាំបាច់ត្រូវការពារតតិយជនដែលបានជឿទៅលើទិដ្ឋភាពដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈមិនពិតនោះ។ ដូចនេះ អ្នកបង្ហាញឆន្ទៈមិនពិតមិនអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាចំពោះតតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរបានទេ។ ឧទាហរណ៍៖ A បានធ្វើកិច្ចសន្យាប្រទានកម្មនូវទ្រព្យសម្បត្តិដែលខ្លួនមានទៅឲ្យ B ដើម្បីគេចវេសពីការរឹបអូសទ្រព្យសម្បត្តិពីម្ចាស់បំណុល។ ក្នុងករណីនេះ A និង B ដឹងច្បាស់ណាស់ថា ការធ្វើប្រទានកម្មនេះ គឺគ្រាន់តែចង់រក្សាទ្រព្យសម្បត្តិរបស់ A ឲ្យរួចផុតពីការរឹបអូសតែប៉ុណ្ណោះ នេះហើយជាការបង្ហាញឆន្ទៈមិនពិត។ ប្រសិនបើ B ឆ្លៀតឱកាសនេះ ក្នុងពេលដែលខ្លួនមានសិទ្ធិលើទ្រព្យសម្បត្តិរបស់ A ហើយបានលក់ទ្រព្យសម្បត្តិនោះទៅឲ្យ C ។ ករណីនេះ

---

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៥៧, កថាខណ្ឌទី២

បើយើងក្រឡេកទៅមើលកិច្ចសន្យារវាង A និង B វាត្រូវបានចាត់ទុកជាមោឃៈរួចបាត់ទៅហើយ។ តើ B ធ្វើម្តេចនឹងមានសិទ្ធិលើទ្រព្យសម្បត្តិរបស់ A ទៅ ហើយរឹតតែមិនអាចលក់ទៅឲ្យ C បានថែមទៀត។ ក៏ប៉ុន្តែបើយើងពិចារណាវិញថា A និង B បានបង្កើតទិដ្ឋភាពពិតមួយតាមរយៈកិច្ចសន្យាប្រទានកម្ម ដែលបានបង្ហាញថា B គឺពិតជាមានសិទ្ធិលើទ្រព្យសម្បត្តិនោះ ហើយ C ក៏បានជឿជាក់ដែរថា B គឺពិតជាមានសិទ្ធិលើទ្រព្យសម្បត្តិនោះពិតប្រាកដមែន ព្រោះ C ដឹងថា B គឺពិតជាបានទទួលទ្រព្យទាំងនោះពី A តាមរយៈកិច្ចសន្យាប្រទានកម្មត្រឹមត្រូវ។ ក្នុងករណីនេះ C ជាជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរទេ ដូចនេះ A មិនអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B បានទេ។ ជាលទ្ធផល C អាចទទួលបានកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលបានទិញពី B។ មានន័យថា កិច្ចសន្យារវាង A និង B ត្រូវបានគេទទួលស្គាល់ថា មានអានុភាពឡើងវិញ ដែលគេអាចហៅបានថា **មោឃភាពមិនដាច់ខាត** ចរិតលក្ខណៈបែបនេះគឺដើម្បីការពារតតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ ហើយនេះជាការទទួលខុសត្រូវរបស់ជនដែលបានបង្កើតទិដ្ឋភាពមិនពិត ដែលត្រូវទទួលបន្ទុកកាតព្វកិច្ចដោយផ្អែកលើទិដ្ឋភាពមិនពិតនោះ។ ក៏ប៉ុន្តែក្នុងករណីដដែលនេះ ប្រសិនបើ C ជាជនទុច្ចរិត ឬ ជាជនសុចរិតតែមានកំហុសធ្ងន់ធ្ងរ នោះគេមិនចាំបាច់ការពារតតិយជនបែបនេះទេ ដូចនេះ A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យារវាង A និង B ហើយក៏អាចអះអាងជាមួយ C បានដែរ។

## ផ្នែកទី២. អានុភាពនៃការលុបចោល

កិច្ចសន្យាដែលអាចលុបចោលបានមានសុពលភាពរហូតដល់ពេលដែលអ្នកដែលមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យានោះ[64]។ កិច្ចសន្យាដែលនឹងត្រូវលុបចោល វាមានផលប៉ះពាល់ត្រឹមតែបុគ្គលឯកជន ដូចនេះ ប្រសិនបើអ្នកដែលមានសិទ្ធិលុបចោល មិនបានធ្វើការលុបចោលកិច្ចសន្យានោះទេ យើងគួរទទួលស្គាល់ឲ្យកិច្ចសន្យានោះបន្តមានអានុភាពទៀត។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលកិច្ចសន្យាដែលអាចលុបចោលបាន កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង[65]។ បើសិនជាអ្នកមានសិទ្ធិលុបចោល មិនទាន់អនុវត្តកាតព្វកិច្ចរបស់ខ្លួននៅឡើយទេ នោះមិនចាំបាច់អនុវត្តទៀតទេ ហើយបើសិនជាអនុវត្តហើយ អាចទាមទារត្រឡប់មកវិញបាន ព្រោះកិច្ចសន្យាដែលត្រូវបានលុបចោលមានអានុភាពប្រតិសកម្ម។ ប៉ុន្តែពេលខ្លះការលុបចោលពុំមានអានុភាពប្រតិសកម្មទេ គឺមានអានុភាពឆ្ពោះទៅរកអនាគត ដូចជាកិច្ចសន្យាដែល

[64] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៥៨, កថាខណ្ឌទី១

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣៥៨, កថាខណ្ឌទី២

អនុវត្តជាបន្តបន្ទាប់ ឧទាហរណ៍ ភតិសន្យា។ ហើយការទាមទារឲ្យផ្តល់តាវកាលិកនេះ យើងនឹងបកស្រាយនៅក្នុងចំណុច **(កថាខណ្ឌទី៣.)ការធ្វើបដិទានឡើងវិញ** នៅខាងក្រោម។ ហើយបើយើងនិយាយអំពីអានុភាពគតិយុត្ត ប្រាកដណាស់វានឹងលេចចេញនូវអានុភាពចំពោះភាគីដែលពាក់ព័ន្ធ។

### កថាខណ្ឌទី១. អានុភាពចំពោះភាគីនៃកិច្ចសន្យា

នៅពេលដែលកិច្ចសន្យាមួយត្រូវបានលុបចោលហើយ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីផ្អែកតាមកិច្ចសន្យាមិនត្រូវបានទទួលស្គាល់ទៀតឡើយ។ ការលុបចោលកិច្ចសន្យាមិនមែនមានអានុភាពត្រឹមតែភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះទេ វាក៏អាចមានអានុភាពចំពោះតតិយជនដែលមានពាក់ព័ន្ធផលប្រយោជន៍ក្នុងកិច្ចសន្យាដែលត្រូវបានលុបចោលផងដែរ។

### កថាខណ្ឌទី២. អានុភាពចំពោះតតិយជន

ជាការពិតណាស់ ការលុបចោលកិច្ចសន្យាដោយសារមូលហេតុដោយវិការៈក្នុងការបង្ហាញឆន្ទៈដូចជា ការភាន់ច្រឡំ, ការឆបោក, ការបង្ហាញពត៌មានមិនពិត, ការរំលោភបំពានលើស្ថានភាព, ការគម្រាមកំហែង(ករណីតតិយក្រោយការលុបចោល), ការកេងយកចំនេញហួសហេតុ(ករណីតតិយក្រោយការលុបចោល) ក្រៅពីភាគីម្ខាងទៀត ក៏អាចអះអាងចំពោះតតិយជនបានដែរ។ ប៉ុន្តែវាហាក់ដូចជាអយុត្តិធម៌ចំពោះតតិយជននៅក្នុងករណីដែលជននោះជាជនសុចរិត ហើយគ្មានកំហុសអំពីមូលហេតុដោយវិការៈក្នុងការបង្ហាញឆន្ទៈ ដូច្នេះហើយបានជាមានការចែងអំពីការការពារតតិយជន នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ពីព្រោះថា ការការពារតតិយជនគឺមានភាពចាំបាច់ណាស់ ដើម្បីការពារផលប្រយោជន៍ផលរបស់តតិយជន ដែលកើតចេញពីកិច្ចសន្យាដោយមានវិការៈនេះ។ ប្រសិនបើកិច្ចសន្យាអាចត្រូវបានលុបចោល ដោយផ្អែកលើការមូលហេតុវិការៈក្នុងការបង្ហាញឆន្ទៈ នោះតតិយជនដែលបានបង្កើតទំនាក់ទំនងកិច្ចសន្យា ដោយផ្អែកលើកិច្ចសន្យាដែលអាចលុបចោលបានទទួលរងនូវការខូចខាតដែលមិនអាចរំពឹងទុកជាមុនបាន។

ឧទាហរណ៍៖ **ក** បានលក់រថយន្តរបស់ខ្លួនទៅអោយ **ខ** ដោយមានការភាន់ច្រឡំ ហើយ **ខ** បានលក់រថយន្តនេះទៅ **គ**។ ប្រសិនបើ **ក** លុបចោលកិច្ចសន្យា នោះអានុភាពនៃកិច្ចសន្យានឹងត្រូវបានចាត់ទុកថា មោឃៈតាំងពីដំបូង (មាត្រា ៣៨៦ កថាខណ្ឌទី៤)។ នៅក្នុងករណីនេះ គេអាចចាត់ទុកថា **គ** ត្រូវស្ថិតនៅក្រោមឥទ្ធិពលពីរប្រភេទ។ វាមានការពិចារណាទ្រឹស្តីមួយចំនួន។

### ក. ការបែងចែកតតិយជននៅពេលមានការលុបចោលកិច្ចសន្យា

ដើម្បីការពារតតិយជនដែលបានលើកឡើងខាងលើ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការបែងចែកតតិយជនទៅតាមភាពមុន រឺក្រោយនៃការលុបចោលកិច្ចសន្យា ពីព្រោះតែវាទាក់ទងទៅនឹងវិធីនៃការការពារតតិយជន ចំពោះ**តតិយជនមុនពេលលុបចោល** និង**តតិយជនក្រោយពេលលុបចោលកិច្ចសន្យា**។ ក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា ៣៩៦ មិនមានបែងចែកតតិយជនមុន ឬក្រោយការលុបចោលកិច្ចសន្យានោះទេ ហេតុនេះហើយ អាចធ្វើការបកស្រាយថា គឺសំដៅទៅលើតតិយជនទាំងមុន និងក្រោយការលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែបើយោងតាមទ្រឹស្តីច្បាប់ ស្ថានភាពរបស់តតិយជនមុនពេលលុបចោលកិច្ចសន្យា និងតតិយជនក្រោយពេលលុបចោលកិច្ចសន្យាមានភាពខុសគ្នា ហេតុនេះហើយ គួរធ្វើការបែងចែកអោយដាច់ពីគ្នា។

### ខ. ភាពខុសគ្នារវាងតតិយជនមុនការលុបចោល និងក្រោយការលុបចោល

តាមគោលជំហរនៃទ្រឹស្តីភាពខុសគ្នាត្រូវបានលាតត្រដាងតាមរយៈខាងក្រោម៖

- តតិយជនមុនពេលលុបចោលកិច្ចសន្យា៖ ទទួលរងការខូចខាតដោយសារតែមានអានុភាពនប្រតិសកម្មនៃការលុបចោល។ ការលុបចោល គឺជាបញ្ហាដាច់ដោយឡែក ដូច្នេះការលុបចោល គួរការពារតាមរយៈបញ្ញត្តិដាច់ដោយឡែកដែលចែងក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា ៣៩៦ នៃក្រមរដ្ឋប្បវេណី។
- តតិយជនក្រោយពេលលុបចោលកិច្ចសន្យា៖ ទទួលរងការខូចខាតដោយសារតែចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ មិនមែនដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោលនោះទេ។ ដូច្នេះ អាចពិចារណាថាត្រូវបានការពារតាមប្រព័ន្ធដែលការពារបុគ្គលដែលចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ ឬជនដែលមិនមានសិទ្ធិពេញលេញតាមរយៈមាត្រា ១៣៤ មាត្រា ១៩៣ និងមាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីជាដើម។

ឧទាហរណ៍៖ **ក** បានធ្វើកិច្ចសន្យាលក់ទិញដីជាមួយនឹង **ខ** ក្រោមមូលហេតុនៃការឆបោកដោយតតិយជន។ ហើយ **ខ** បានលក់ដីនោះបន្តទៅអោយ **គ** បន្ទាប់មក **ក** ក្រោយបានដឹងថា ខ្លួនត្រូវបានគេឆបោក ក៏បានលុបចោលកិច្ចសន្យាជាមួយនឹង **ខ**។ ក្នុងករណីនេះ **គ** ត្រូវបានគេហៅថា **តតិយជនមុនការលុបចោលកិច្ចសន្យា** ប៉ុន្តែបើសិនជា **ក** បានអះអាងអំពីការលុបចោលនៅមុនពេល

ដែល ខ បានធ្វើកិច្ចសន្យាលក់ដីអោយទៅ គ នោះ គ នឹងក្លាយជា**តតិយជនក្រោយការលុបចោលនៃកិច្ចសន្យា**។

**គ. វិធីនៃការការពារតតិយជន**

**តតិយជនមុនពេលលុបចោលកិច្ចសន្យា៖** នៅក្នុងករណីនេះ ប្រសិនបើជននេះជាជនសុចរិត និងគ្មានកំហុស នោះនឹងត្រូវបានទទួលការការពារតាមរយៈ វាក្យខណ្ឌ៤ នៃមាត្រា ៣៦៧។ នៅក្នុងន័យនេះ ពាក្យថា **សុចរិត** និង **គ្មានកំហុស** មានន័យថា តតិយជនដែលបានធ្វើកិច្ចសន្យាជាមួយភាគីដែលទទួលផលប្រយោជន៍ពីកិច្ចសន្យាដែលមានវិការៈ មិនបានដឹងអំពីការបង្ហាញឆន្ទៈដែលមានវិការៈទាល់តែសោះឡើយ។ គួរបញ្ជាក់ផងដែរថា ការការពារតតិយជនពេលមានការលុបចោលដោយសារវិការៈក្នុងការបង្ហាញឆន្ទៈដូចជា ការភាន់ច្រឡំ, ការឆបោក, ការរំលោភបំពានលើស្ថានភាព, ការបង្ហាញពត៌មានមិនពិត ទាក់ទងការការពារក្នុងមូលហេតុទាំងនេះ មានបញ្ញត្តិច្បាប់ និងទ្រឹស្ដីធ្វើការបកស្រាយក្នុងការការពារតតិយទាំងក្នុងស្ថានភាពមុន និងក្រោយការលុបចោល ចំណែកមូលហេតុវិការៈផ្សេងទៀតដូចជា ការកេងយកចំនេញហួសហេតុ និងការគម្រាមកំហែង មិនមានឡើយការការពារតតិយជនក្នុងស្ថានភាពមុនការលុបចោល មានតែស្ថានភាពតតិយជនក្រោយការលុបចោល ដែលត្រូវបានការពារតាមការបកស្រាយទ្រឹស្ដីដូចករណីដែលនឹងបកស្រាយនៅខាងក្រោម។

**ការការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យា៖** ជាក់ស្ដែង នៅក្នុងវាក្យខណ្ឌ២ កថាខណ្ឌ៤ នៃមាត្រា ៣៤៦ មិនបានបដិសេធច្បាស់លាស់អំពីតតិយជនក្រោយកិច្ចសន្យាត្រូវបានលុបចោលនោះទេ ដូច្នេះជាការសន្មត់ មាត្រានេះក៏ការការពារចំពោះតតិយជនក្រោយកិច្ចសន្យាត្រូវបានលុបចោលផងដែរ។ ប៉ុន្តែតាមរយៈហេតុផលដែលបានពន្យល់ខាងលើ ការការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យា មានទ្រឹស្ដីដែលយកតាមប្រព័ន្ធការការពារជនដែលបានចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ ឬក៏ជនដែលមិនមានសិទ្ធិពេញលេញ ហើយប្រព័ន្ធទាំងនោះជាទ្រឹស្ដីដែលបានធ្វើការបកស្រាយក្នុងការអនុវត្តនៅប្រទេសជប៉ុន និងមានខ្លឹមសារដូចខាងក្រោម៖

- **ករណីជនដែលបានទទួលចលនវត្ថុពីបុគ្គលដែលគ្មានសិទ្ធិ៖** បើយោងតាមមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា បានចែងថា **"អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ"**។ តាមរយៈអត្ថន័យនៃមាត្រានេះ វាបានបញ្ជាក់ច្បាស់លាស់

ហើយថា ទោះបីជាតតិយជនក្រោយពេលលុបចោល បានទទួលចលនវត្ថុពីបុគ្គលដែលគ្មានសិទ្ធិ ក៏ត្រូវមានការការពារផងដែរ។ ប៉ុន្តែមាត្រានេះការពារតែតតិយជនដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុសប៉ុណ្ណោះ។

- **ករណីតតិយជនក្រោយការលុបចោលដោយផ្អែកលើភាពមុន រឺក្រោយនៃការចុះបញ្ជី៖**




នៅពេលកិច្ចសន្យាត្រូវបានលុបចោល នោះនាំឲ្យទំនាក់ទំនងរវាង A និង B មិនបានកើតឡើងតាំងពីដំបូង ប៉ុន្តែតាមរូបភាពជាក់ស្តែង ទំនាក់ទំនងកិច្ចសន្យាមានអត្ថិភាពមុនពេលមានការលុបចោល ដូចនេះ B ត្រូវផ្ទេរបង្វិលកម្មសិទ្ធិទៅ A វិញ ប៉ុន្តែ B ក្រោយពេលផ្ទេរកម្មសិទ្ធិបានលក់ដីនោះទៅឲ្យ C។ នៅក្នុងស្ថានភាពបែបនេះ វាដូចគ្នាទៅនឹងការលក់ជាន់គ្នាដែរ នាំឲ្យប្រសិនបើ C បានបំពេញលក្ខខណ្ឌតតាំង (ប្រសិនបើកម្មវត្ថុជាចលនវត្ថុគឺសិទ្ធិកាន់កាប់, ប្រសិនបើកម្មវត្ថុជាអចលវត្ថុគឺ ការចុះបញ្ជី) មុន A នោះ C អាចធ្វើលទ្ធកម្មបាន។ ក្នុងករណីនេះ ប្រសិនបើ C ជាជនទុច្ចរិតក៏ត្រូវបានការពារដែរ ព្រោះមាត្រា១៣៤ និងមាត្រា១៣៥នៃក្រមរដ្ឋប្បវេណីកម្ពុជា មិនបានកំណត់តតិយជនជាជនសុចរិត រឺជនទុច្ចរិតឡើយ។ ប៉ុន្តែបើបកស្រាយស្របទៅតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ដែលបញ្ញត្តិនៅក្នុងមាត្រា ៥ នៃក្រមរដ្ឋប្បវេណីកម្ពុជានោះ តតិយជនដែលបានកំណត់នៅក្នុងមាត្រា ១៣៤ គឺសំដៅតែតតិយជនដែលសុចរិត និងគ្មានកំហុស រឺតតិយជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរប៉ុណ្ណោះ ដូច្នេះ នៅ

ក្នុងករណីនេះ C មិនត្រូវបានការពារទេ ហើយការបកស្រាយនេះ វាបានជួយដល់ B ដែលជាជនសុចរិតផងដែរ។ ក្រៅពីនេះ ការការពារ B ដែលជាជនសុចរិតក៏អាចធ្វើតាមរយៈការទាមទារសំណងការខូចខាត ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចដែល B មានចំពោះ A ផងដែរ។ ជាការពិត ការបកស្រាយខាងលើជាគោលការណ៍នៃការលក់ជាន់គ្នាចំពោះអចលវត្ថុ ដោយផ្អែកលើក្រមរដ្ឋប្បវេណីកម្ពុជា ក៏ប៉ុន្តែការបកស្រាយនេះមិនត្រូវបានយកមកអនុវត្តឡើយ នៅក្នុងករណីដែល A រឺ C មានភាពអាក្រក់ខ្លាំងដែលជាករណីលើកលែង ដែល B អាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន។ ដោយយោងតាមមាត្រា ៤២២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ចង់សំដៅមានន័យថា យកសិទ្ធិទាមទារឲ្យចុះបញ្ជីផ្ទេរសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ ដែល B មានចំពោះ A ធ្វើជាសិទ្ធិលើបំណុលដែលត្រូវបានធានា ហើយយក សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីការលុបការចុះបញ្ជី ដោយផ្អែកលើកម្មសិទ្ធិដែល A មានចំពោះ C ធ្វើជាសិទ្ធិលើបំណុលដែលត្រូវធ្វើឧបាទេសកម្ម ហើយ B ធ្វើឧបាទេសកម្មលើ A ដោយដាក់ពាក្យបណ្តឹងទៅ C ទាមទារឲ្យចុះបញ្ជីអំពីការលុបចោលការចុះបញ្ជី។ ដូចនេះ សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីដោយផ្អែកលើកម្មសិទ្ធិ ដែល A មានចំពោះ C កើតឡើងក្នុងករណីដែលកិច្ចសន្យាលក់ទិញរវាង A និង C បំពានគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ និងបំពានសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ដែលជាមូលហេតុនៃមោឃភាព។ ដូចនេះ ដើម្បីបកស្រាយថា កិច្ចសន្យាលក់ទិញរវាង A និង C មោឃៈ កិច្ចសន្យាលក់ទិញនោះចាំបាច់ត្រូវតែមានភាពអាក្រក់ខ្លាំង ហើយដែលសង្គមមិនអាចទទួលយកបាន។ ឧទាហរណ៍ B កំពុងរៀបចំនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ស្រាប់តែ A និង C ឃុបឃិតគ្នា ហើយឆបោកB ដើម្បីរារាំងការដាក់ពាក្យសុំបញ្ជីរបស់ B។

- **ករណីតតិយជនក្រោយពេលលុបចោលកិច្ចសន្យាផ្អែកលើការបង្ហាញឆន្ទៈមិនពិត៖** សំដៅគោលគំនិតការពារតតិយជនក្រោយពេលលុបចោលកិច្ចសន្យា ដែលជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ តាមរយៈការអនុវត្តដោយស្រដៀងនឹងមាត្រា ៣៥៣ កថាខណ្ឌទី២ ដែរ គឺជាបញ្ញត្តិដែលការពារ

តតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ក្នុងកិច្ចសន្យាដែលធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត ដែលមានលក្ខខណ្ឌដូចជា ទី១ មានអត្ថិភាពនៃរូបភាពខាងក្រៅមិនពិត ទី២ ម្ចាស់សិទ្ធិមានកំហុសចំពោះការបង្កើតរូបភាពខាងក្រៅមិនពិត និងទី៣ ចាំបាច់ត្រូវការពារតតិយជនដែលបានធ្វើពាណិជ្ជកម្មដោយជឿជាក់លើរូបភាពខាងក្រៅមិនពិត (មានន័យថាតតិយជនជាជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ)។ ឧទាហរណ៍ A (អ្នកលក់) B (អ្នកទិញ) បានបង្កើតកិច្ចសន្យា។ ប៉ុន្តែ A បានលុបចោលកិច្ចសន្យានោះ។ បន្ទាប់ពីការលុបចោលកិច្ចសន្យានោះ B បានផ្ទេរកម្មវត្ថុនៃការលក់ទិញទៅឲ្យ C តាមកិច្ចសន្យា ដូច្នេះ C ជាតតិយជនក្រោយការលុបចោលកិច្ចសន្យា។ នៅក្នុងករណីនេះ មានន័យថា ដោយសារតែភាគីម្ខាងដែលបានលុបចោលកិច្ចសន្យាមានការធ្វេសប្រហែស ដែលការធ្វេសប្រហែសនេះវាបានបង្កើតជារូបភាពមួយធ្វើឲ្យតតិយជនជឿជាក់ថា កិច្ចសន្យាដែលបានលុបចោលនោះមានអានុភាព ដូច្នេះហើយ បានជាតតិយជននោះបានបង្កើតកិច្ចសន្យាជាមួយភាគីដែលលែងជាម្ចាស់សិទ្ធិ។ ឧទាហរណ៍ A (អ្នកលក់) B (អ្នកទិញ) បានបង្កើតកិច្ចសន្យា។ ប៉ុន្តែ A បានលុបចោលកិច្ចសន្យានោះ។ បន្ទាប់ពីការលុបចោលកិច្ចសន្យានោះ B បានផ្ទេរកម្មវត្ថុនៃការលក់ទិញទៅឲ្យ C តាមកិច្ចសន្យា ដូច្នេះ C ជាតតិយជនក្រោយការលុបចោលកិច្ចសន្យា និងនៅក្នុងករណីនេះដោយយោងតាមការបកស្រាយខាងលើ C នឹងត្រូវបានទទួលការការពារកាលណា ក្រោយពេលលុបចោលកិច្ចសន្យាមាននៅសល់រូបភាពខាងក្រៅមិនពិតថា B ជាម្ចាស់សិទ្ធិដដែល (ការកាន់កាប់, ឈ្មោះក្នុងប័ណ្ណកម្មសិទ្ធិជាដើម) ដោយរូបភាពខាងក្រៅមិនពិតនេះជាកំហុសរបស់ A ដែលមិនបានចាត់វិធានការភ្លាមៗ បន្ទាប់ពីមានការលុបចោលកិច្ចសន្យា និងលក្ខខណ្ឌមួយទៀត គឺ C ដែលជាតតិយជនជាជនសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ ដែលចង់សំដៅថា C ពិតជាបានជឿជាក់ដោយគ្មានកំហុសថា B ជាម្ចាស់កម្មសិទ្ធិ។

**កថាខណ្ឌទី៣. ការធ្វើបដិទានឡើងវិញ**

ការធ្វើបដិទានឡើងវិញ មានន័យថា ធ្វើឲ្យស្ថានភាពវិលទៅរកភាពដើមវិញ ឬការប្រគល់ត្រលប់មកវិញ ក្នុងន័យនេះ គឺធ្វើឲ្យស្ថានភាពវិលទៅរកស្ថានភាពដូចមុនពេលបង្កើតកិច្ចសន្យា។

នៅពេលដែលកិច្ចសន្យាមួយត្រូវបានលុបចោល កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូងដែលនាំឲ្យសិទ្ធិ និងកាតព្វកិច្ចទាំងឡាយដែលបានបង្កើតតាមរយៈកិច្ចសន្យានោះមិនត្រូវបានទទួលស្គាល់ដោយច្បាប់ទៀតឡើយ។ ក្នុងករណីដែលភាគីម្ខាង បានផ្តល់តាវកាលិកឲ្យភាគីម្ខាងទៀត ដោយផ្អែកលើកិច្ចសន្យាដែលបានលុបចោល នោះភាគីដែលបានផ្តល់តាវកាលិករួច មានសិទ្ធិទាមទារតាវកាលិកត្រឡប់មកវិញបាន។ ហើយការទាមទារនេះដែរ គឺអាចធ្វើទៅបានដោយផ្អែកលើបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ឬផ្អែកលើកម្មសិទ្ធិ ដែលជាជម្រើសឲ្យភាគីអាចជ្រើសយកជម្រើសណាមួយដែលខ្លួនគិតថាមានភាពងាយស្រួលក្នុងការបង្ហាញភស្តុតាង ដើម្បីទាមទារ។

ឧទាហរណ៍៖ លោក **ក** បានទិញចូផ្កាមួយពីលោក **ខ** ក្នុងតម្លៃ ១០ម៉ឺនដុល្លា។ ដោយសារតែមានការភាន់ច្រលំទាំងសងខាងថា ចូផ្កានោះជាចូបុរាណ តែធាតុពិត ចូផ្កានោះគ្រាន់តែជាចូចាស់ធម្មតាមួយតែប៉ុណ្ណោះ ដែលជាហេតុនាំឲ្យកិច្ចសន្យានោះត្រូវបានលុបចោលវិញ។ ក្នុងករណីដែលមានការលុបចោលនេះ គឺកិច្ចសន្យាមានអានុភាពប្រតិសកម្មវិលទៅរកពេលមុនពេលបង្កើតកិច្ចសន្យា ដូចនេះ នៅពេលដែលមានការលុបចោលកិច្ចសន្យាបែបនេះ អ្នកលក់ត្រូវមានកាតព្វកិច្ចប្រគល់ត្រឡប់មកវិញនូវប្រាក់ដែលបានទទួលពីអ្នកទិញ ហើយអ្នកទិញក៏មានកាតព្វកិច្ចប្រគល់ត្រឡប់ទៅវិញនូវចូផ្កាទៅឲ្យអ្នកលក់វិញដូចគ្នា។ ប្រសិនបើមានភាគីណាមិនយល់ព្រមប្រគល់តាវកាលិកត្រឡប់ទៅវិញ នៅក្រោយពេលដែលកិច្ចសន្យាត្រូវបានលុបចោលនោះ ភាគីអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការដោយផ្អែកលើបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ឬផ្អែកលើកម្មសិទ្ធិ ដែលជាជម្រើសឲ្យភាគីអាចជ្រើសយកជម្រើសណាមួយ ដែលខ្លួនគិតថាមានភាពងាយស្រួលក្នុងការបង្ហាញភស្តុតាងដើម្បីទាមទារ។

ក្នុងករណីដែលតាវកាលិកដែលបានផ្តល់នោះ មិនអាចទាមទារត្រលប់មកវិញបានដោយសារមានការខូចខាត ឬការបាត់បង់ ភាគីដែលបានផ្តល់តាវកាលិក អាចទាមទារសំណងការខូចខាតតាមបញ្ញត្តិដែលមានចែងអំពីសំណងនៃការខូចខាត នៅក្នុងសេចក្តីចម្រើនដោយឥតហេតុ ឬសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិបាន។

ឧទាហរណ៍៖ **ក** និង **ខ** ដែលជាអនីតិជន បានបង្កើតកិច្ចសន្យាទិញលក់ទូរស័ព្ទ IPHONE X ក្នុងតម្លៃ ១.២០០ដុល្លា។ ក្រោយមក **ខ** ក៏បានប្រគល់ប្រាក់ឲ្យទៅ **ក** តែមិនទាន់បានយកទូរស័ព្ទនោះទេ ស្របពេលនោះដែរអាណាព្យាបាលរបស់ **ខ** បានដឹង ហើយក៏បានលុបចោលកិច្ចសន្យានោះ ដែលជាហេតុនាំឲ្យ **ក** ត្រូវប្រគល់ប្រាក់ទៅឲ្យអាណាព្យាបាលរបស់ **ខ** វិញ។ នៅពេលដែលកិច្ចសន្យានោះត្រូវបានលុបចោលរួចរាល់ហើយនោះ **ក** ត្រូវប្រគល់ប្រាក់ត្រឡប់ទៅឲ្យអាណា-

ព្យាបាលរបស់ ខ វិញ បើមិនដូច្នោះទេ អាណាព្យាបាលរបស់ ខ អាចធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីទាមទារប្រាក់នោះត្រឡប់មកវិញបាន ដោយហេតុថា កិច្ចសន្យានោះត្រូវបានលុបចោល ហើយសិទ្ធិ និងកាតព្វកិច្ចក៏ត្រូវបានរលត់ដែរ ដូចនេះ អ្នកលក់មានកាតព្វកិច្ចប្រគល់ត្រឡប់ទៅវិញនូវប្រាក់ដែលទទួលពីអ្នកទិញ ហើយអ្នកទិញត្រូវប្រគល់ត្រឡប់ទៅវិញ នូវតារកាលិកដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រឡប់ទៅអ្នកលក់វិញដូចគ្នា បើមានភាគីណាមិនប្រគល់ទេនោះ ភាគីម្ខាងទៀតអាចប្ដឹងទាមទារទៅតុលាការ ដោយផ្អែកលើបញ្ញត្តិស្ដីពីសេចក្ដីចម្រើនដោយឥតហេតុ ឬផ្អែកលើកម្មសិទ្ធិ ដែលជាជម្រើសឲ្យភាគីអាចជ្រើសយកជម្រើសណាមួយ ដែលខ្លួនគិតថាមានភាពងាយស្រួលក្នុងការបង្ហាញភស្តុតាងដើម្បីទាមទារ។

## ផ្នែកទី៣. ការប្រៀបធៀបអានុភាពនៃការមោឃភាព និងការលុបចោល

នៅក្នុងចំណុចនេះយើងនឹងធ្វើការប្រៀបធៀបអានុភាពនៃការមោឃភាព និងការលុបចោលថាតើអានុភាពនៃការមោឃភាព និងការលុបចោលមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេច?

ហើយបើយើងនិយាយអំពីអានុភាព វានឹងលេចចេញនូវអានុភាពចំពោះភាគីដែលពាក់ព័ន្ធដែលមានដូចជា អានុភាពចំពោះភាគីនៃកិច្ចសន្យា និងអានុភាពចំពោះតតិយជន។ ដូចនេះ យើងនឹងធ្វើការបកស្រាយជា ០២(ពីរ)ករណី ផងដែរ។

### កថាខណ្ឌទី១. អានុភាពចំពោះភាគីនៃកិច្ចសន្យា

នៅក្នុងក្រមរដ្ឋប្បវេណីពុំបានបញ្ញត្តិអំពីអានុភាពនៃមោឃភាពឲ្យបានច្បាស់នោះទេ គឺគ្រាន់តែបានបញ្ញត្តិថា សកម្មភាពនោះត្រូវបានចាត់ទុកជាមោឃៈតែប៉ុណ្ណោះ។ បើយើងក្រឡេកទៅមើលផលប៉ះពាល់នៃមោឃភាព គឺមានផលប៉ះពាល់មិនត្រឹមតែភាគី ឬតតិយជនដែលមានប្រយោជន៍នៅក្នុងកិច្ចសន្យាតែប៉ុណ្ណោះទេ គឺវាមានផលប៉ះពាល់ដល់សង្គមទាំងមូល ដូចនេះ សកម្មភាពណាដែលរងនូវការមោឃភាព គឺចាត់ទុកថាគ្មានអានុភាពតាំងពីដំបូង។ តែបើយើងនិយាយអំពីការលុបចោលវិញ គឺកិច្ចសន្យានោះនៅតែមានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល ធ្វើការលុបចោលកិច្ចសន្យានោះ ហើយកិច្ចសន្យានោះនឹងមានអានុភាពប្រតិសកម្មវិលទៅរកពេលបង្កើតកិច្ចសន្យានោះវិញ។

សរុបមកនៅពេលដែលកិច្ចសន្យាមួយទទួលរងនូវការមោឃភាព ឬការលុបចោល ហើយជនដែលមានសិទ្ធិអះអាងបានធ្វើការអះអាងអំពីមោឃភាព ឬការលុបចោល នោះសិទ្ធិ និងកាតព្វកិច្ចនៅក្នុងកិច្ចសន្យានោះនឹងលែងត្រូវបានទទួលស្គាល់ទៀតហើយ។ បើសិនជាភាគីនៃកិច្ចសន្យាមិនទាន់ អនុវត្តកាតព្វកិច្ចរបស់ខ្លួននៅឡើយទេ នោះមិនចាំបាច់អនុវត្តទៀតទេ ហើយ

បើសិនជាអនុវត្តហើយ អាចទាមទារត្រឡប់មកវិញបាន។ ក៏ប៉ុន្តែ នៅក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឲ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ។

**កថាខណ្ឌទី២. អានុភាពចំពោះតតិយជន**

បើយើងពិនិត្យមើលអំពីអានុភាពនៃមោឃភាពចំពោះតតិយជន គឺក្នុងករណីខ្លះមានចរិតលក្ខណៈដាច់ខាត ក្នុងករណីខ្លះទៀតមិនមានលក្ខណៈដាច់ខាតនោះទេ ព្រោះកិច្ចសន្យាដែលចាត់ទុកថា មោឃៈនោះ អាចមានអានុភាពវិញ ដោយផ្អែកទៅលើមូលហេតុដែលនាំឲ្យមោឃភាពនោះ។ ក្នុងករណីដែលកិច្ចសន្យាមួយត្រូវចាត់ទុកថាជាមោឃៈ ដោយមូលហេតុទាក់ទងនឹងអត្ថន័យ ឬ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាដែលទាមទារ វាជាមូលហេតុនៃមោឃភាពដែលមានចរិតលក្ខណៈដាច់ខាត ដែលនាំឲ្យកិច្ចសន្យានោះដាច់ខាតត្រូវចាត់ទុកថាមោឃៈ មិនអាចមានសុពលភាពបានឡើយ។ ក្នុងករណីនេះ កិច្ចសន្យានោះអាចអះអាងជាមួយតតិយជនបាន ទោះបីជាតតិយជននោះសុចរិត និងគ្មានកំហុសក៏ដោយ ក៏មិនមានការការពារដែរ។ ចំពោះករណីនៃការបង្ហាញឆន្ទៈមិនពិត កិច្ចសន្យានេះគឺមិនបានផ្ទុយច្បាប់នោះទេ ក៏ប៉ុន្តែវាមិនត្រូវបានគេទទួលស្គាល់ថាមានអានុភាពនោះទេ ព្រោះភាគីដែលបានបង្ហាញឆន្ទៈនោះដឹងច្បាស់ខ្លួនឯងថា ឆន្ទៈដែលបានបង្ហាញនោះមិនពិតឡើយ។ គេចាំបាច់ត្រូវការពារតតិយជនដែលបានជឿទៅលើទិដ្ឋភាពដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈមិនពិតនោះ។ ដូចនេះ អ្នកបង្ហាញឆន្ទៈមិនពិតមិនអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាចំពោះតតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរបានទេ។ បើយើងក្រឡេកទៅមើលអានុភាពនៃការលុបចោលចំពោះតតិយជនវិញ ជាគោលការណ៍ការលុបចោលកិច្ចសន្យា អាចអះអាងចំពោះតតិយជនបាន ប៉ុន្តែមិនអាចអះអាងជាមួយតតិយជនដែលសុចរិតនិងគ្មានកំហុសឡើយ។ លើកលែងតែវិការៈនៃការបង្ហាញឆន្ទៈដោយការគម្រាមកំហែង គឺអាចអះអាងចំពោះតតិយជនបាន ទោះបីជាតតិយជននោះសុចរិត និងគ្មានកំហុសក៏ដោយ។ ចំណែកឯអំពើកេងចំណេញហួសហេតុវិញ ក្រមរដ្ឋប្បវេណីក៏មិនបានបញ្ញត្តិអំពីការការពារតតិយជនដែរ ដូចនេះយើងមិនមានអ្វីច្រើនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការបកស្រាយឲ្យបានច្បាស់ជាងនេះទេ។ នៅក្នុងករណីអ្នកបង្ហាញឆន្ទៈដោយមានវិការៈតាមរយៈការគម្រាមកំហែង ឬអំពើកេងចំណេញហួសហេតុ បើប្រៀបទៅនឹងការការពារតតិយជនដែលធ្វើលទ្ធកម្មដោយសុច្ចរិតចំពោះវត្ថុ ទំនងជាអ្នកបង្ហាញឆន្ទៈដែលមានវិការៈក្នុងករណីទាំងពីរនេះទទួលបានការការពារខ្លាំងជាង ព្រោះករណីទាំង

ពីរនេះ ក្រមរដ្ឋប្បវេណីពុំមានចែងអំពីការការពារតតិយជនឡើយ ចំណែកឯការបង្ហាញឆន្ទៈដែលមានវិការៈផ្សេងៗទៀតគឺសុទ្ធតែចែងអំពីការការពារតតិយជនដែលសុចរិតទាំងអស់។

សរុបមកយើងអាចនិយាយបានថា ជាទូទៅក្នុងករណីមោឃភាពគឺសុទ្ធតែអាចអះអាងចំពោះតតិយជនបាន ទោះបីជាតតិយជននោះសុចរិត និងគ្មានកំហុសក៏ដោយ លើកលែងតែក្នុងករណីមោឃភាពដោយមូលហេតុការបង្ហាញឆន្ទៈមិនពិតតែប៉ុណ្ណោះ ដែលច្បាប់បានការពារតតិយជនដែលសុចរិត និងគ្មានកំហុស ដែលបានជឿទៅលើស្ថានភាពដែលភាគីបានប្រឌិតឡើងនោះថាជាការពិត។ ចំណែកឯក្នុងករណីការលុបចោលវិញគឺនៅក្នុងក្រមរដ្ឋប្បវេណីបានចែងអំពីការការពារតតិយជនដែលសុចរិត និងគ្មានកំហុស លើកលែងតែករណីការគម្រាមកំហែងទេ ដែលផលប៉ះពាល់ដែលកើតចេញពីវិការៈប្រភេទនេះវាមានលក្ខណៈធ្ងន់ធ្ងរដល់ភាគីដែលរងគ្រោះ និងករណីវិការៈដោយការកេងចំណេញហួសហេតុផងដែរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវ យើងខ្ញុំយល់ឃើញថា ប្រធានបទមួយនេះពិតជាបានផ្តល់នូវប្រយោជន៍ និងចំណេះដឹងជាច្រើនសម្រាប់យើងដែលជាអ្នកស្រាវជ្រាវ ឲ្យបានយល់ច្បាស់អំពី "**មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា**" ។ ប្រធានបទនេះ គឺពិតជាសារៈសំខាន់ណាស់សម្រាប់សង្គមខ្មែរយើងសព្វថ្ងៃ ពីព្រោះថាចំណុចជាច្រើនដែលបាន សរសេរនៅក្នុងសារណានេះ សុទ្ធសឹងជាចំណុល្អៗ និងបន្ថែមពីលើបញ្ញត្តិដែលមានស្រាប់ ជាឧទាហរណ៍ចំណុចដែលបកស្រាយអំពីអត្ថិភាពនៃមោឃភាព និងការលុបចោលនៅកិច្ចសន្យា ដែលចំណុចនេះមិនធ្លាប់មានការពន្យល់បកស្រាយពីមុនមកឡើយ ហើយចំណុចនេះវាជួយឲ្យយើងអាចដឹងថាទណ្ឌកម្មនៃកិច្ចសន្យាណាខ្លះភាគច្រើនកើតនៅក្នុងដំណាក់ណាមួយ ដែលជាវាបច្ច័យបង្កឲ្យមានភាពងាយស្រួល ក្នុងការកំណត់សម្គាល់។ មួយវិញទៀត ចំណុចខ្លះនៅក្នុងសារណានេះក៏វាអាចផ្តល់ជាគំនិត ជាពិសេសសម្រាប់ប្រជាពលរដ្ឋ មេធាវី និងអ្នកអនុវត្តច្បាប់គ្រប់មជ្ឈដ្ឋាន ដែលតែងតែប្រើប្រាស់កិច្ចសន្យាជាប្រចាំថ្ងៃ ទោះបីក្រោមទម្រង់ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី។

ចំពោះគោលបំណងដែលក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បង្កើតឲ្យមានមោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា ដើម្បីជួយការពារយ៉ាងពេញទំហឹងទៅនឹងការរំលោភបំពានគ្រប់រូបភាពដែលកើតនៅក្នុងកិច្ចសន្យា ហើយធ្វើឲ្យមានការខូចខាតទៅដល់ភាគីនៃកិច្ចសន្យាដែលមានភាពសុចរិត និងស្មោះត្រង់ ក៏ដូចជាដើម្បីធ្វើឲ្យកិច្ចសន្យាធានាបាននូវសមភាពរវាងគ្នា និងគ្នាផងដែរ។ មួយវិញទៀត ក៏ក្រមនេះមានគោលបំណងនៅក្នុងការទប់ស្កាត់នូវកិច្ចសន្យាមួយដែលមានភាពមិនប្រក្រតី ដែលនាំឲ្យកិច្ចសន្យានេះមិនមានសុពលភាព និងចងគូភាគីនៃកិច្ចសន្យាឲ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនឲ្យបានពេញលេញ ដោយគោរពនូវគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ បើមិនដូច្នេះទេ នឹងទទួលរងផលវិបាកដែលកើតមានចេញពីទណ្ឌកម្មនៃកិច្ចសន្យាដែលមានដូចជា ការលុបចោល និងមោឃភាពជាក់ជាពុំខាន។ ក្រៅពីនេះការបង្ហាញថា ទណ្ឌកម្មនៃកិច្ចសន្យាទាំង ២(ពីរ) នេះ ស្ថិតនៅក្នុងដំណាក់កាលណាមួយ វានឹងជួយឲ្យមានការកត់សម្គាល់បានកាន់តែឆាប់រហ័ស និងដឹងកាន់តែច្បាស់នូវលក្ខខណ្ឌចំពោះមូលហេតុនៃបង្កើតឲ្យមានទណ្ឌកម្មនៃកិច្ចសន្យាទាំងពីរនេះ។ លើសពីនេះទៅទៀត ការបង្កើតនូវការលុបចោល និងមោឃភាពនេះផងដែរ និតិករមានបំណងចង់ឲ្យមានសាមគ្គីភាពនៅក្នុងសង្គម និងមានការសហការគ្នានៅក្នុងការប្រកបមុខរបរជំនួញជួញដូរ ដែលជាមូលហេតុដែលធ្វើឲ្យមនុស្សនៅក្នុងសង្គមមានជីវភាពធូរធារ និងសង្គមផ្ទាល់មានការរីកចម្រើន ដោយប្រជាពលរដ្ឋបានបង់ពន្ធស្របទៅនឹងរបបសេដ្ឋកិច្ចទីផ្សារ

សេរី។ ដូចនេះ វាមានសារៈសំខាន់សម្រាប់គូភាគីនៃកិច្ចសន្យា ក្នុងការជៀសវាងឲ្យបាននូវអត្ថិភាពនៃការលុបចោល និងមោឃភាពដែលអាចកើតឡើងនៅក្នុងកិច្ចសន្យា ដើម្បីសម្រេចនូវគោលបំណងនៃការបង្កើតរបបគតិយុត្តិនៃកិច្ចសន្យា។

ដោយផ្ទុយនឹងគោលគំនិតខាងលើ ប្រសិនបើគូភាគីនៃកិច្ចសន្យាមិនបានគោរពតាម ដោយបានអនុវត្តប្រាស់ចាកនឹងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ឬបានធ្វើសកម្មភាពណាមួយ ដែលនាំឲ្យភាគីបានបង្ហាញឆន្ទៈដែលមិនគោរពនូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនប្រាកដណាស់នឹងនាំឲ្យជួបនឹងផលវិបាកនៃការលុបចោល និងមោឃភាពដែលច្បាប់បានបញ្ញត្តិ។ ផលវិបាកដែលអាចបង្កឡើងដោយ ការលុបចោល និងមោឃភាពនោះ យើងអាចពិចារណាមើលឃើញថា៖

- **ការខាតបង់ពេលវេលា៖** ប្រសិនបើភាគីនៃកិច្ចសន្យាបានអនុវត្តសិទ្ធិរបស់ខ្លួនដោយមានសមភាព និងសមធម៌ នោះភាគីនឹងមិនអាចទទួលរងនូវផលវិបាកបានឡើយ ដូចនេះ គាត់នឹងអាចចំណេញពេលវេលាដែលជាមាសប្រាក់របស់គាត់។
- **ការចំណាយថវិកា៖** សំដៅដល់ការចំណាយទៅលើសំណាងជម្ងឺចិត្តក្នុងករណីដែលតុលាការសម្រេចឲ្យសងភាគីម្ខាងទៀត និងការចំណាយប្រាក់សម្រាប់បង់ប្រាក់ប្រដាប់ក្តីនានាប្រសិនបើមានបណ្តឹងតាមផ្លូវតុលាការ ជាអាទិ៍។
- **ការបាត់បង់ផលប្រយោជន៍ដែលកើតចេញពីកិច្ចសន្យា៖** គូភាគីបង្កើតកិច្ចសន្យាប្រាកដជាចង់បាននូវផលចំណេញ ឬដើម្បីបំណងអ្វីមួយដែលខ្លួនចង់បានហើយ ដូចនេះបើមានការបំពាននូវលក្ខខណ្ឌនៃការលុបចោល និងមោឃភាព នោះកិច្ចសន្យាមិនអាចសម្រេចគោលដៅរបស់ខ្លួនបានទេ ដែលវាជាប្រការដែលគូភាគីមិនអាចទទួលបាននូវផលប្រយោជន៍ដែលកើតមានដូចគ្នា។
- **ធ្វើឲ្យសាមគ្គីភាពបាក់បែក៖** ជាការពិត នៅពេលដែលភាគីណាម្ខាងទទួលនូវទណ្ឌកម្មនៃកិច្ចសន្យាទាំងពីរនេះហើយ ប្រាកដជាភាគីម្ខាងទៀតនៃកិច្ចសន្យានឹងឈប់សហការលែងពាក់ព័ន្ធជាមួយ ដែលជាហេតុធ្វើឲ្យសាមគ្គីបែកបាក់។ សាមគ្គីបែកបាក់នឹងក្លាយជាគុណវិបត្តិនៃសេដ្ឋកិច្ចទីផ្សារសេរី ពីព្រោះវាបានពឹងពាក់ជាខ្លាំងនូវរូបវន្តបុគ្គលម្នាក់ៗមានទំនាក់ទំនងល្អនឹងគ្នាក្នុងកាបង្កើតកិច្ចសន្យា។

សរុបមក គូភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តឲ្យបានដាច់ខាតនូវលក្ខខណ្ឌនៃការបង្កើតរបបគតិយុត្តិ ដែលកិច្ចសន្យាមួយទាមទារ និងយល់ឲ្យបានច្បាស់លាស់នូវមូលហេតុបង្កមាន **"មោឃភាព និងការលុបចោលនៅក្នុងកិច្ចសន្យា"** ៕

# អនុសាសន៍

# អនុសាសន៍

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរអ្នកសុំស្នើសុំនូវអនុសាសន៍ចំនួន ០២(ពីរ)ចំណុច ដោយមានបំណងបង្ហាញឲ្យកាន់តែច្បាស់លាស់ និងជួយដោះស្រាយនូវគំនិតដែលបានស្វែងយល់ផ្សេងគ្នាមួយចំនួន ដែលធ្វើឲ្យមានការប្រឡមគ្នានៅក្នុងចំណោទបញ្ហាពាក់ព័ន្ធនឹងមោឃភាព និងការលុបចោលក្នុងកិច្ចសន្យា ដែលមានដូចតទៅ៖

១. ជាការកត់សម្គាល់ មោឃភាពត្រូវបានច្បាប់បញ្ញត្តិថា មានលក្ខណៈដាច់ខាត និងមិនមានអានុភាពតាំងពីដំបូងមកម្ល៉េះ ចុះហេតុអ្វីបានជាតម្រូវឲ្យការអះអាងអំពីមោឃភាពដាច់ខាតនេះត្រូវតែធ្វើបណ្ដឹងបញ្ជាក់អំពីអត្ថិភាពនៃមោឃភាពនោះ តើវាមានសារៈសំខាន់ដែរឬទេក្នុងការបញ្ជាក់បន្ថែមនេះ? សំណួរនេះបានក្លាយជាចំណោទគតិយុត្តិមួយដែលមានការយល់ឃើញខុសៗគ្នា និងមិនទាន់បានសម្រេចជាឯកច្ឆ័ននៅឡើយទេ។ អាស្រ័យហេតុនេះ វាគប្បីណាស់ដែលស្ថាប័នមានសមត្ថកិច្ចនៅក្នុងបញ្ហានេះ ដូចជាស្ថាប័នតុលាការ ក្រសួងយុត្តិធម៌ជាដើម គួរតែមានជាយុត្តិសាស្ត្រ ឬសេចក្ដីណែនាំណាមួយ សម្រាប់ណែនាំ និងជាអំណះអំណាងទៅដល់អ្នកអនុវត្តច្បាប់គ្រប់មជ្ឈដ្ឋានឲ្យបានជ្រាបច្បាស់អំពីខ្លឹមសារ និងគោលគំណិតនៃបទបញ្ញត្តិទាំងនេះកុំឲ្យមានការបកស្រាយរៀងៗខ្លួនដែលធ្វើឲ្យមានការយល់ឃើញខុសៗគ្នាបែបនេះ។

២. នៅក្នុងចំណុចនេះទាក់ទងទៅនឹងវិធីនៃការអះអាងអំពីការលុបចោល និងមោឃភាព។ វាគួរឲ្យឆ្ងល់ដែរចំពោះបញ្ហានេះ ដែលយើងឃើញមានសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីមួយចំនួននៅតែសម្រេចសេចក្ដីថា "ប្រកាសលុបចោល ឬប្រកាសមោឃភាព" នៃកិច្ចសន្យាដដែល។ នៅក្នុងករណីនេះ គប្បីតែមានការណែនាំជាលក្ខណៈផ្ទៃប្រទេសនៅក្នុងការណែនាំទៅដល់ចៅក្រមឲ្យសម្រេចជាឯកច្ឆ័នអំពីការកំណែទម្រង់នូវខ្លឹមសារនៃសេចក្ដីសម្រេចពី "ប្រកាស" មកជា "បញ្ជាក់អត្ថិភាព ឬនត្ថិភាពនៃ សិទ្ធិ ឬកាតព្វកិច្ចនៃកិច្ចសន្យាវិញ"។

# ឯកសារយោង

# ឯកសារយោង


I. **បទដ្ឋានគតិយុត្តិ៖**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ៖ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- ព្រះរាជក្រមលេខ៖ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តី ការអនុវត្តក្រមរដ្ឋប្បវេណី
- ក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីអំពី "កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា"
- ព្រះរាជក្រមលេខ៖ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

II. **ឯកសារផ្សេងៗ**

- សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, រៀបចំឡើងដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី៥, ឆ្នាំ២០១០
- មេរៀនភាគទី២ ក្រមរដ្ឋប្បវេណី, រៀបរៀងដោយសមាជិកក្រុមការងារអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម, បោះពុម្ពលើកទី១ ខែមិនា ឆ្នាំ២០១២
- មេរៀនភាគទី៣ ក្រមរដ្ឋប្បវេណី, រៀបរៀងដោយសមាជិកក្រុមការងារអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម, បោះពុម្ពលើកទី១ ខែមិនា ឆ្នាំ២០១២
- មេរៀនភាគទី១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, បោះពុម្ពលើកទី១ ភ្នំពេញ ខែធ្នូ ឆ្នាំ២០១៥
- មេរៀនភាគទី២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, បោះពុម្ពលើកទី១ ភ្នំពេញ ខែធ្នូ ឆ្នាំ២០១៥
- លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ, សៀវភៅ នីតិកាតព្វកិច្ច, ឆ្នាំ២០១៧
- លោកសាស្ត្រាចារ្យ ញឹក វុធ្វី, សៀវភៅ នីតិកាតព្វកិច្ច ភាគទី១, ឆ្នាំ២០១៥
- វិភាគទានច្បាប់, កម្រងមេរៀន, ឆ្នាំ២០១៥

- ឯកសារស្តីពី "បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី", រៀបរៀងដោយក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | អង្គហេតុ |
| ០២ | កិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៤ |
| ០៣ | លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៤ |
| ០៤ | លិខិតជូនដំណឹងស្តីពីមោឃភាព ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៤ |
| ០៥ | ពាក្យបណ្តឹង ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៤ |
| ០៦ | សាលក្រមរដ្ឋប្បវេណីលេខ ២២ “X” ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១៤ |
| ០៧ | ក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីអំពី "កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា" |

# ឧបសម្ព័ន្ធលេខ
# ០៧

# ក្រឹត្យ-ច្បាប់

## ស្ដីពី

## កិច្ចសន្យា និងការទទួល
## ខុសត្រូវក្រៅកិច្ចសន្យា

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**

**ឯករាជ សន្តិភាព សេរីភាព សុភមង្គល**

********

ក្រុមប្រឹក្សារដ្ឋ

---------

លេខ ៣៨ ក្រ.ច

ក្រឹត្យ-ច្បាប់

ស្តីអំពី

កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា

ក្រុមប្រឹក្សារដ្ឋ

នៃ

សាធារណៈរដ្ឋមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់នៃការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់នៃអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់ស្តីពីការចាត់តាំងតុលាការ និងអយ្យការ ដលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០២ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ២៨ ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៨៥
- បានឃើញក្រិត្យ-ច្បាប់ លេខ ៣៤ ក្រ ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល
- បានឃើញក្រិត្យ-ច្បាប់ លេខ ០៧ ក្រ ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**សំរេច**

.......

# **<u>ជំពូកទី១</u>**

## **ស្តីអំពីកិច្ចសន្យា**

### **<u>ផ្នែកទី១ បទបញ្ញត្តិទូទៅ</u>**

**<u>មាត្រា១-</u>** កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទិននិងខ្លួន ។

ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ជានីតិបុគ្គល ។

នីតិបុគ្គល អាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន ។

**<u>មាត្រា២-</u>** កិច្ចសន្យាទាំងឡាយ ត្រូវរួមចំណែកក្នុងការផ្សារភ្ជាប់ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ។

ភាគីនៃកិច្ចសន្យា ត្រូវសហការនិងគ្នាក្នុងបរិយាកាសទុកចិត្ត ស្មោះត្រង់និងគ្នា អនុវត្តសមស្របនិងគោលការណ៍សីលធម៌សង្គម ហើយជាពិសេស កំចាត់នូវគំនិត មនុស្សជិះជាន់មនុស្ស ។

### **<u>ផ្នែកទី២ សុពលភាព និងទំរង់នៃកិច្ចសន្យា</u>**

**<u>មាត្រា៣-</u>** កិច្ចសន្យាទាំងឡាយនិងយកជាការបាន លុះណាតែការតព្វកិច្ចដែលកើតពិកិច្ចសន្យានោះ :

១. កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និង ដោយសេរី

២. កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា

៣. មានវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងដែលស្របច្បាប់របៀបរៀបរយសាធារណៈ ឬ ទំនៀមទំលាប់ដ៏ល្អប្រពៃ ។

**<u>មាត្រា៤-</u>** កិច្ចសន្យាអាចធ្វើដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរ ។ ច្បាប់អាចកំណត់ឱ្យមានទំរង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា ។ កិច្ចសន្យាទាំងឡាយណា ដែលមិនបានធ្វើតាមទំរង់ដែលច្បាប់បានកំណត់ត្រូវទុកជាមោឃៈ លើកលែងតែមានបទបញ្ញត្តិនៃវិធានច្បាប់ណាមួយកំនត់ផ្ទុយពីនេះ ។

កិច្ចសន្យាគ្រប់ប្រភេទ ស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតំលៃលើសពីប្រាំពាន់រៀល ត្រូវធ្វើជាលាយលក្ខអក្សរ ។

### **<u>ផ្នែកទី៣ មោឃៈភាពនៃកិច្ចសន្យា</u>**

**<u>មាត្រា៥-</u>** ត្រូវទុកជាមោឃៈដាច់ខាត :

- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនិងច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ។

- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនិងផលប្រយោជន៍សង្គម ឬមិនស្របនិងគោលការណ៍សីលធម៌សង្គម ។

- កិច្ចសន្យាទាំងឡាយណាដែលមានតាវកាលិក កម្មវត្ថុនៃកិច្ចសន្យា មិនអាចធ្វើកើត ។

**មាត្រា៦-** អាចទុកជាមោឃៈបាន :

- កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬដោយសេរី ។

- កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីបុគ្គលគ្មានសមត្ថភាព ចុះកិច្ចសន្យា ។

**មាត្រា៧-**មិនអាចចាត់ទុកថា មានការព្រមព្រៀងត្រឹមត្រូវទេ កាលណាការព្រមព្រៀងនោះមិនធ្វើដោយការភ័ន្តច្រឡំ ដោយមានហឹង្សា ឬដោយការបន្លំបោកប្រាស់ ។

**មាត្រា៨**-ការភ័ន្តច្រឡំនិងជាមូលហេតុមោឃៈភាពនៃកិច្ចសន្យាបាន បើមានការភ័ន្តច្រឡំទៅលើសារជាតិនៃរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា ។

ការភ័ន្តច្រឡំទៅលើបុគ្គល មិនអាចចាត់ទុកជាមូលហេតុមោឃៈភាពនៃកិច្ចសន្យាបានឡើយ លើកលែងតែបុគ្គលនោះ ជាមូលហេតុនៃកិច្ចចំបងនៃកិច្ចសន្យា ។

**មាត្រា៩-** ហឹង្សានិងទៅជាមូលហេតុនិងទៅជាមោឃៈភាពនៃកិច្ចសន្យាបាន កាលណាហឹង្សានោះជាការគំរាមកំហែង បង្ខិតបង្ខំតាមផ្លូវកាយ ឬផ្លូវចិត្ត ប្រព្រឹត្តទៅលើភាគីណាមួយ ឬទៅលើប្តី ប្រពន្ធ បុព្វញាតិ ឬបច្ឆាញាតិណាមួយរបស់ភាគីនោះ ។

**មាត្រា១០-** ការបន្លំបោកប្រាស់ ជាមោឃៈភាពនៃកិច្ចសន្យា កាលណាមានឧបាយកល អំពើបញ្ឆោត អំពើបន្លំក្លែងបន្លំភូតភរប្រព្រឹត្តដោយភាគីណាមួយ ដែលជាហេតុបញ្ជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេ ភាគីម្ខាងទៀតប្រាកដជាមិនធ្វើកិច្ចសន្យានោះឡើយ ។

**មាត្រា១១-** កាលណានៅពេលចុះកិច្ចសន្យា ភាគីណាមួយឆ្លៀតទាញយកប្រយោជន៍ពីស្ថានភាពភាគីម្ខាងទៀត ធ្វើកិច្ចសន្យាដោយមានចំណេញច្រើនមិនសមស្របមកលើខ្លួន ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យានោះបានជានិច្ច ។

**មាត្រា១២-** នៅពេលធ្វើកិច្ចសន្យា កាលណាមានភាពខុសគ្នាមិនសមស្របរវាងតំលៃនៃតាវកាលិក និងតំលៃតាវកាលិកតបវិញ ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យាបាន ក្នុងលក្ខណៈដែលខ្លួនពុំដែលមានបំណងធ្វើអំណោយទេនោះ ។

**មាត្រា១៣-** ភាគីដែលដោះសាស់អាងថា ខ្លួនបានចុះកិច្ចសន្យាដោយមានការភ័ន្តច្រឡំ ដោយមានហឹង្សា ឬដោយមានការបន្លំបោកប្រាស់ ដើម្បីមិនអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះ ត្រូវជូនភស្តុតាងអំពីរឿងនោះ ។

**មាត្រា១៤-** ជនទាំងឡាយដែលមានអាយុគ្រប់ ១៨ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលា លើកលែងតែជនតំហាត់ដែលមានចែងក្នុងច្បាប់ ។

**មាត្រា១៥-** អនីតិជនអាយុតិចជាង ១៨ឆ្នាំ មិនអាចធ្វើឱ្យកើតសិទ្ធិ ឬករណីកិច្ចនានា ជាពិសេសមិនអាចចុះកិច្ចសន្យាដោយគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួនបានឡើយ ។

កិច្ចសន្យាដែលធ្វើឱ្យអនីតិជន គ្មានការយល់ព្រមជាបឋមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួន និងអាចយកទៅអនុវត្តបាន លុះត្រាតែអ្នកអាណាព្យាបាលស្របច្បាប់ឯកភាពលើកិច្ចសន្យានោះ ក្រោយពេលដែលអនីតិជនបានចុះកិច្ចសន្យានោះរួច ។

ប៉ុន្តែចំពោះកិច្ចសន្យាទាំងឡាយណា ធ្វើដោយអនីតិជនសំរាប់បំពេញការរស់នៅប្រចាំថ្ងៃនោះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់នៃអនីតិជននោះឡើយ ។

**មាត្រា១៦-** គូសន្យានៃអសមត្ថជន មិនអាចដោះសាដើម្បីគេចកែពីកាតព្វកិច្ចនៃកិច្ចសន្យា ដោយសំអាងថារូបជនដែលចុះកិច្ចសន្យាជាមួយនិងខ្លួននោះ ជាអសមត្ថជនបានឡើយ ។

**មាត្រា១៧-** កិច្ចសន្យាទាំងឡាយត្រូវមានវត្ថុស្ថិតក្នុងពាណិជ្ជកម្ម ។ វត្ថុទាំងនេះត្រូវចែងឱ្យប្រាកដដោយឡែកពីគ្នា តាមប្រភេទ តាមបរិមាណ និងតាមគុណភាព ។

វត្ថុដែលនឹងមានក្នុងអនាគតកាល ក៏អាចជាវត្ថុនៃកិច្ចសន្យាបានដែល ។ ប៉ុន្តែកិច្ចសន្យាលក់មរតក ដែលមានម្ចាស់នៅរស់ពុំអាចធ្វើបានឡើយ ទោះបីម្ចាស់មរតកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា១៨-** ជនគ្រប់រូបអាចនឹងសុំមោឃភាពដាច់ខាតនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រា ៥ បានគ្រប់ពេលវេលា ។

**មាត្រា១៩-** ក្នុងករណីមោឃភាពនៃកិច្ចសន្យា បណ្តាលមកពីមូលហេតុអសមត្ថភាព ការភ័ន្តច្រឡំ ហិង្សា ឬការការបន្លំបោកប្រាស់ ការសុំមោឃភាពនៃកិច្ចសន្យានេះអាចនឹងធ្វើឡើងបានដោយភាគីរងគ្រោះ ឬដោយជនទាំងឡាយណាដែលមានប្រយោជន៍ស្របច្បាប់ ក្នុងការសុំមោឃភាពនោះ ។

ភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព ត្រូវឱ្យដំណឹងទៅភាគីម្ខាងទៀត ។ ភាគីដែលទទួលដំណឹងត្រូវឆ្លើយតបជាបន្ទាន់ ។ ក្រោយពេលឱ្យដំណឹងភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព អាចសុំប្តឹងមោឃភាពនៃកិច្ចសន្យានោះ ក្នុងរយៈពេល ១២ ខែ យ៉ាងយូរ ។

**មាត្រា២០-** សិទ្ធិប្តឹងមោឃភាពនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រាទី ១៩ ត្រូវរលត់ប្រសិនបើក្រោយពីពេលប្តឹងសុំឱ្យមានមោឃភាពនោះមក ជនដែលមានសិទ្ធិប្តឹងនេះយល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬសុំឈប់ប្តឹងវិញដោយលាយល័ក្ខអក្សរ អំពីមោឃភាពនៃកិច្ចសន្យានោះ ។

**មាត្រា២១-** ក្នុងករណីមានមោឃភាពនៃកិច្ចសន្យា ស្ថានភាពដែលមាននៅពេលមុនចុះកិច្ចសន្យា ត្រូវមានឡើងវិញ ។

## ផ្នែកទី ៤. អានុភាព និង ការបកស្រាយនៃកិច្ចសន្យា

**មាត្រា២២-** កិច្ចសន្យាទុកជាច្បាប់របស់គូភាគី ។

កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមពីគូភាគី ។ កិច្ចសន្យាត្រូវយកទៅអនុវត្តដោយសុច្ចរិត និងតាមបំណងនៃគូភាគី ។

កិច្ចសន្យាមានអនុភាពតែទៅលើភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ។

**មាត្រា២៣-** កាលបើកិច្ចសន្យាធ្វើឡើងដោយមានន័យមិនច្បាស់ កិច្ចសន្យានោះត្រូវបកស្រាយតាមទំលាប់ប្រើ ឬតាមទំនៀមទំលាប់នៃកន្លែងដែលកិច្ចសន្យានោះបានធ្វើ កុំឱ្យតែការបកស្រាយនោះផ្ទុយនឹងបទបញ្ញត្តិនៃក្រិត្យច្បាប់នោះ ។

ក្នុងករណីសង្ស័យ កិច្ចសន្យាត្រូវបានបកស្រាយជាប្រយោជន៍នៃភាគីកូនបំណុល ។

**មាត្រា២៤-** ភាគីកូនបំណុលនៃកិច្ចសន្យា មានកាតព្វកិច្ចសងដោយទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ បច្ចុប្បន្ន និង អនាគត ។

## ផ្នែកទី ៥. អាជ្ញាយុកាលនៃកិច្ចសន្យា

**មាត្រា២៥-** លើកលែងតែច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យាត្រូវផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្តឹងទាមទារឱ្យអនុវត្តក្នុងអំឡុង ៥ ឆ្នាំ គិតពីថ្ងៃកំណត់កិច្ចសន្យា ឬបើគ្មានកំណត់ថ្ងៃទេ ត្រូវគិតពីថ្ងៃចុះកិច្ចសន្យា ។

**មាត្រា២៦ -** អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅស្ថាន ហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវបានច្បាប់ ។

បណ្តឹងរបស់ភាគីកូនបំណុល ក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ ។

**មាត្រា២៧ -** កូនបំណុល ឬអ្នកធានា អាចនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបាន ។ បើកូនបំណុល ឬអ្នកធានាមិនបានលើកយកអាជ្ញាយុកាលមកតវ៉ាទេ តុលាការប្រជាជនត្រូវលើកជូសសាម៉ីខ្លួន ។

**មាត្រា២៨ -** ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញកាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតំលៃនោះមកវិញបានឡើយ ។

## ផ្នែកទី៦. ការអនុវត្តកិច្ចសន្យា

**មាត្រា២៩ -** កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវជាពិសេសអំពីបរិមាណ គុណភាព ទីកន្លែង និងរយៈពេលកំណត់ ។

**មាត្រា៣០ -** ភាគីនីមួយនៃកិច្ចសន្យាគឺ :

- កូនបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវធ្វើ
- ដើមបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវទារ

**មាត្រា៣១ -** ភាគីដើមបំណុលមិនអាចត្រូវបានបង្ខំ :

- ឱ្យទទួលយកវត្ថុផ្សេងពីវត្ថុដែលខ្លួនត្រូវបាននោះឡើយ ថ្វីត្បិតតែតំលៃនៃវត្ថុដែលបង្ខំឱ្យយកនោះស្មើ ឬលើសពីតំលៃនៃវត្ថុដែលខ្លួនត្រូវបាន ។
- ឱ្យព្រមទទួលយកការអនុវត្តមួយផ្នែកនៃកិច្ចសន្យា ។ ប៉ុន្តែដោយយោលទៅលើស្មារតីសុច្ឆរិត និងស្ថានភាពក្រលំបាករបស់ភាគីកូនបំណុល តុលាការប្រជាជនអាចឱ្យបន្ថយរយៈពេលអនុវត្ត និងបង្គាប់ឱ្យបង្គង់សិន ។ ក្នុងករណីពិសេសនេះ សេចក្តីសំរេចត្រូវតែដាក់មូលហេតុឱ្យបានច្បាស់លាស់ ហើយតុលាការប្រជាជនត្រូវប្រើអំណាចនេះដោយប្រុងប្រយ័ត្នបំផុត ។

**មាត្រា៣២ -** ការអនុវត្តកិច្ចសន្យា ត្រូវប្រព្រឹត្តិទៅនៅលំនៅស្ថានរបស់កូនបំណុលក្នុងករណីដែលកិច្ចសន្យាពុំបានកំណត់កន្លែងផ្សេងទៀត ។

**មាត្រា៣៣ -** ក្នុងករណីគ្មានកំណត់រយៈពេលដើម្បីអនុវត្តកិច្ចសន្យា កូនបំណុលអាចតង ឬផ្តល់នៅពេលណាក៏បាន ។

# ជំពូកទី ២

## អំពីកិច្ចសន្យាមួយចំនួន ដែលប្រើញឹកញាប់

### ផ្នែកទី ១_ការលក់ដូរ

**មាត្រា៣៤-** ការលក់ ជាកិច្ចសន្យាមួយដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយ ឬសិទ្ធិណាមួយឱ្យទៅបុគ្គលម្នាក់ទៀតដែលមានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ថ្លៃវត្ថុ ឬសិទ្ធិនោះមកវិញ ។

**មាត្រា៣៥-** ត្រូវទុកជាមោឃៈ

- ការលក់វត្ថុរបស់អ្នកដទៃ
- ការលក់វត្ថុពីប្ដីទៅឱ្យប្រពន្ធ ឬពីប្រពន្ធទៅឱ្យប្ដី
- ការលក់វត្ថុអវិភាគ " ដែលបំបែកពីគ្នាមិនបាន " ដោយសហកម្មសិទ្ធិករម្នាក់ដោយគ្មានបានទទួលការព្រមព្រៀងពីសហកម្មសិទ្ធិករឯទៀត ។

### ១_ កាតព្វកិច្ចរបស់អ្នកលក់

**មាត្រា៣៦-** អ្នកលក់ត្រូវរក្សាវត្ថុឱ្យបានល្អរហូតដល់ថ្ងៃកំណត់ ដើម្បីអាចបានអនុវត្តកាតព្វកិច្ចបេស់ខ្លួនដែលត្រូវប្រគល់វត្ថុនោះ ។

**មាត្រា៣៧-** អ្នកលក់ត្រូវជៀសវាងកុំផ្លាស់ប្ដូរ កែប្រែវត្ថុតាមរបៀបណាក៏ដោយ ចាប់តាំងពីថ្ងៃលក់រហូតដល់ថ្ងៃប្រគល់វត្ថុ ។

**មាត្រា៣៨-** អ្នកលក់ត្រូវទទួលខុសត្រូវអំពីការអន្តរាយដែលបណ្ដាលឡើងដល់វត្ថុនោះ រហូតដល់ថ្ងៃដែលត្រូវប្រគល់ ។ ការលក់អាចរំលាយចោលបាន ប្រសិនបើវត្ថុដែលលក់នោះបាត់ ឬខូចខាតច្រើនមុនពេលប្រគល់ ឬក្នុងករណីដែលអ្នកលក់រកវត្ថុដូចគ្នាមកជំនួសពុំបាន ។ ប្រសិនបើការលក់ត្រូវរំលាយចោល អ្នកលក់ត្រូវបង់ជំងឺចិត្តឱ្យអ្នកទិញចំពោះការបាត់វត្ថុ ឬការខូចខាតវត្ថុបណ្ដាលមកពីកំហុសរបស់អ្នកលក់ ។

**មាត្រា៣៩-** អ្នកលក់ត្រូវប្រាប់អ្នកទិញនូវគុណភាពជាសារវ័ន្តនៃវត្ថុ ព្រមទាំងស្ថានភាពទាំងឡាយសំខាន់ៗទាក់ទងទៅនឹងវត្ថុនោះ ជាពិសេសប្រាប់អំពីសិទ្ធិនោះឬអំពីបន្ទុកដែលមានលើវត្ថុនោះ។ ម្យ៉ាងទៀតអ្នកលក់ក៏ត្រូវប្រគល់ដល់ដៃអ្នកទិញនូវឯកសារទាំងឡាយដែលទាក់ទងនឹងស្ថានភាពទាំងនោះ ។

**មាត្រា៤០-** អ្នកលក់ត្រូវប្រគល់ពុំមែនតែវត្ថុដើមប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រគល់ផល ឬវត្ថុរាយរងទាក់ទងទៅនឹងវត្ថុដើមទៀតផង ។

ក្នុងរឿងលក់ចលនវត្ថុ ការប្រគល់ប័ណ្ណនៃចលនវត្ថុ ទុកជាការប្រគល់ចលនវត្ថុដោយត្រឹមត្រូវ ។ ប្រាក់ចំណាយក្នុងការប្រគល់ត្រូវធ្លាក់មកលើអ្នកលក់ ប្រសិនបើគ្មានចែងផ្សេងពីនេះ នៅក្នុងកិច្ចសន្យាលក់ទេនោះ ។

__មាត្រា៩១-__ ចំពោះចលនវត្ថុ ការផ្ទេរសិទ្ធិរបស់អ្នកលក់ឱ្យទៅអ្នកទិញទុកជាត្រឹមត្រូវបាន លុះត្រាតែសំបុត្រលក់នោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា ។ ចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា តតិយជនជំទាស់លែងបាន ។

ចំពោះចលនវត្ថុ ការផ្ទេរកម្មសិទ្ធិទុកជាត្រឹមត្រូវបាន ហើយតតិយជនក៏ជំទាស់លែងបាន ចាប់តាំងពីពេលដែលប្រគល់វត្ថុនោះដល់អ្នកទិញ លើកលែងតែការលក់ត្រូវធ្វើសំបុត្រមានសេចក្តីបញ្ជាក់ ។ ក្នុងករណីខាងក្រោយនេះ តតិយជនជំទាស់លែងបានចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ ។

__មាត្រា៩២-__ អ្នកលក់ពុំទទួលខុសត្រូវចំពោះវិការៈដែលមើលឃើញពីក្រៅទេ ប៉ុន្តែត្រូវទទួលខុសត្រូវចំពោះវិការៈដ៏កំបាំងដែលមានមុខពេលលក់ ។

បើអ្នកទិញមានភស្តុតាងថា វិការៈនោះមានមុខពេលលក់ អ្នកទិញអាចទាមទារឱ្យរំលាយការលក់នោះចោល ឬក៏បន្ថយថ្លៃបាន ។ ទោះនិងលែងទិញក្តី ទោះនិងទាមទារឱ្យបន្ថយថ្លៃក្តី អ្នកទិញត្រូវតវ៉ាក្នុងរយះពេលមួយឆ្នាំចាប់ពីថ្ងៃប្រគល់វត្ថុ ។ បើមិនតវ៉ាក្នុងរយះមួយឆ្នាំនោះទេ ការនៅស្ងៀមរបស់ខ្លួនទុកដូចជាការយល់ព្រម ។

__មាត្រា៩៣-__ អ្នកលក់ត្រូវធានាដល់អ្នកទិញ ចំពោះការរំខានណាដែលតតិយជន គំរាមថានិងប្តឹងឱ្យដកហូតវត្ថុពីអ្នកទិញ ។ សេចក្តីគំរាមថា ប្តឹងឱ្យដកហូតនោះកើតឡើងក្នុងគ្រាដែលតតិយជនទាមទារឱ្យអ្នកទិញទទួលស្គាល់សិទ្ធិរបស់ខ្លួនលើវត្ថុនោះ ។

__មាត្រា៩៤-__ ខណៈណាដែលមានតតិយជនគំរាមថា និងប្តឹងឱ្យដកហូត អ្នកទិញអាចទៅហៅអ្នកលក់ឱ្យមកធានារ៉ាប់រងភ្លាមបាន ។ ខណៈអ្នកលក់ត្រូវបញ្ចេញប័ណ្ណរបស់ខ្លួន ប្រើគ្រប់មធ្យោបាយដើម្បីឱ្យតតិយជនលែងប្តឹងទៅ ឬក៏ឱ្យបានឈ្នះតតិយជននោះតាមអំណាចសាលក្រមរបស់តុលាការ ។

__មាត្រា៩៥-__ បើអ្នកលក់ដែលអ្នកទិញបានហៅឱ្យធានារ៉ាប់រងជួសខ្លួនរំងាប់សេចក្តី ដែលតតិយជនប្រកាន់នោះបាន អ្នកទិញមិនត្រូវបានជំងឺចិត្តអ្វីឡើយ ។

បើអ្នកលក់រំងាប់សេចក្តីរំខាននោះមិនបានទេ ការប្តឹងផ្តល់ក៏ត្រូវប្រព្រឹត្តទៅតាមតំណើរ ។

__មាត្រា៩៦-__ បើតុលាការកាត់សេចក្តីឱ្យដកហូតវត្ថុ អ្នកលក់ត្រូវបង្វិលថ្លៃទាំងអស់ដែលខ្លួនបានទទួលឱ្យអ្នកទិញវិញ ម្យ៉ាងទៀតអ្នកលក់ត្រូវចេញជំងឺចិត្តផង នៅក្នុងជំងឺចិត្តនោះត្រូវគិតប្រាកបង់ខាតក្នុងការធ្វើកិច្ចសន្យា និងប្រាក់ចំណាយផ្សេងៗ ដែលអ្នកទិញគិតបញ្ចូលទៅក្នុងវត្ថុនោះ តាំងពីថ្ងៃលក់មក ។

**<u>មាត្រា៤៧</u> -** បើអ្នកលក់ស្លាប់ កាតព្វកិច្ចនៃការទទួលរ៉ាប់រងត្រូវធ្លាក់ទៅលើទាយាទទាំងអស់នៃអ្នកលក់ ។

**<u>មាត្រា៤៨</u> -** បើវត្ថុដែលលក់នោះបានមកដោយអំពើល្មើសជាបទឧក្រិដ្ឋ ឬជាបទល្មើសមធ្យមអ្នកទិញកាលបើដឹងហើយ អាចប្តឹងទាមទារឱ្យរំលាយការលក់នោះវិញបាន ទោះបីគ្មានតតីយជនណាគំរាមកំហែងដកហូតវត្ថុនោះវិញក៏ដោយ ។

កិច្ចសន្យាដែលផ្ទុយពីសេចក្តីនេះ ត្រូវទុកជាមោឃៈ ។

**<u>មាត្រា៤៩</u> -** ប្រសិនបើវត្ថុដដែលហើយលក់ឱ្យច្រើននាក់ត១គ្នា អ្នកទិញក្រោយបង្អស់ត្រូវហៅអ្នកដែលលក់ឱ្យខ្លួនមកធានារ៉ាប់រង ។ អ្នកលក់នេះនិងប្រកាន់អ្នកដែលលក់ឱ្យខ្លួនត១គ្នាទៅទៀតតាមត្រូវការ ។

### <u>១. ភាតព្វកិច្ចនៃអ្នកទិញ</u>

**<u>មាត្រា៥០</u> -** អ្នកទិញត្រូវប្រគល់ប្រាក់នៅថ្ងៃ និងទីកន្លែងដែលបានកំណត់ ។ ប្រសិនបើកិច្ចសន្យាពុំមានកំណត់ទីកន្លែង និងថ្ងៃដែលត្រូវទទួលប្រាក់ទេ ត្រូវសន្មត់ថា ការប្រគល់ប្រាក់ត្រូវធ្វើនៅទីកន្លែង និងនៅពេលដែលប្រគល់វត្ថុ ។

**<u>មាត្រា៥១</u> -** កិច្ចសន្យាអាចតំរូវឱ្យអ្នកទិញបង់ការប្រាក់និងតំលៃវត្ថុ ក្នុងករណីមានការប្រគល់យឺតយ៉ាវ ។ អត្រានៃការប្រាក់នោះ មិនអាចគិតឱ្យលើសពី ៥ ភាគរយក្នុងមួយឆ្នាំ ។

ប្រសិនបើកិច្ចសន្យាមិនកំណត់អំពីការប្រាក់ទេ អ្នកទិញត្រូវចេញតែថ្លៃវត្ថុដែលចុះក្នុងកិច្ចសន្យា ប៉ុន្តែក្នុងករណីដែលវត្ថុនោះបង្កើតជាផល ឬជាផលទុន ការប្រាក់ត្រូវគិតតាមអត្រាដែលច្បាប់កំនត់ ។

**<u>មាត្រា៥២</u> -** បើអ្នកទិញបានទទួលវត្ថុហើយ ហើយមានគេប្រកាន់ថា និងប្តឹងឱ្យដកហូតវត្ថុនោះវិញ អ្នកទិញអាចមិនទាន់បង់ថ្លៃវត្ថុនោះបាន ។ អ្នកទិញត្រូវប្រគល់ថ្លៃនោះទៅឱ្យអ្នកលក់ កាលណាការរំខានបានត្រូវរំងាប់វិញហើយ ។

**<u>មាត្រា៥៣</u> -** ដរាបណាអ្នកទិញមិនទាន់ចេញថ្លៃឱ្យ ដរាបនោះអ្នកលក់មានសិទ្ធិផ្អាកវត្ថុនោះទុកដែរ ។

**<u>មាត្រា៥៤</u> -** បើដល់ថ្ងៃសន្មត់ហើយ អ្នកទិញមិនទាន់បានបង់ថ្លៃ អ្នកលក់អាចសុំរំលាយការលក់នោះវិញបាន ប្រសិន់បើអ្នកលក់មិនចង់ប្តឹងទារថ្លៃនោះទេ ។

ដរាបណាភាគខ្លះនៃថ្លៃមិនទាន់សងអស់ ដរាបនោះអ្នកលក់អាចសុំរំលាយការលក់បាន ។

**<u>មាត្រា៥៥</u> -** ការរំលាយការលក់ តំរូវឱ្យភាគីទាំងសងខាងនៃកាតព្វកិច្ច បង្វិលរបស់ដែលខ្លួនបានទទួលឱ្យគ្នាវិញ ។

អ្នកទិញត្រូវបង្វិលវត្ថុព្រមទាំងផល ឬផលទុនដែលខ្លួនបានយក ។

អ្នកលក់ត្រូវសងទៅអ្នកទិញវិញនូវប្រាក់ដែលអ្នកទិញបានចេញក្នុងថ្លៃវត្ថុ ហើយត្រូវគិតការប្រាក់តាមអត្រាដែលច្បាប់កំណត់ តាំងពីថ្ងៃដែលបានសងថ្លៃមួយលើកៗ ។

## ផ្នែកទី២. ការខ្ចីមានការប្រាក់

**មាត្រា៥៦-** ការខ្ចីមានការប្រាក់ ជាកិច្ចសន្យាដែលបុគ្គលម្នាក់ប្រគល់ប្រាក់ឱ្យទៅបុគ្គលម្នាក់ទៀត ហើយបុគ្គលក្រោយម្នាក់នេះមានកាតព្វកិច្ចសងវិញដោយមានតំឡើងទឹកប្រាក់ទៅតាមពេលវេលានៃកិច្ចសន្យា ។

**មាត្រា៥៧-** កិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខអក្សរ ។ កិច្ចសន្យាត្រូវកំណត់ឱ្យច្បាស់អំពីឈ្មោះ ទីលំនៅរបស់គូភាគី ចំនួនទឹកប្រាក់ដែលខ្ចី ចំនួនការប្រាក់ រយះពេលខ្ចី និងថ្ងៃសងវិញ ។ កូនបំណុលត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

**មាត្រា៥៨-** បើកិច្ចសន្យាមិនកំណត់ថ្ងៃសង និងមិនកំណត់ការប្រាក់ទេនោះ សន្មត់ថាគូភាគីព្រមព្រៀងចុះកិច្ចសន្យាសំរាប់រយះពេលមួយឆ្នាំ ដោលគ្មានការប្រាក់ ។

**មាត្រា៥៩-** និងអាចឱ្យយកការប្រាក់ខ្ចីបាន លុះត្រាតែមានការព្រមព្រៀងនៃគូភាគីក្នុងកិច្ចសន្យា ។ អត្រានៃការប្រាក់មិនត្រូវឱ្យលើសពី ៥ ភាគរយក្នុងមួយឆ្នាំ លើកលែងតែមានបទបញ្ញត្តិចែងផ្ទុយពីនេះ ។

**មាត្រា៦០-** ការប្រាក់ដែលអ្នកឱ្យខ្ចីបានយកលើសរហូតមកក្នុងពេលដែលជំពាក់ ត្រូវកាត់ដាច់ជាសំណងប្រាក់ដើម ។

បើអ្នកខ្ចីបានសងលើសពីប្រាក់ដើម និងការប្រាក់តាមច្បាប់កំណត់ អ្នកឱ្យខ្ចីនិងត្រូវបង្ខំឱ្យសងប្រាក់ដែលខ្លួនបានយកលើសខុសច្បាប់នោះទៅអ្នកខ្ចីវិញ ព្រមទាំងតំរូវឱ្យបង់ការប្រាក់ផង គិតពីថ្ងៃដែលបានសង ។ ក្នុងករណីនេះ អ្នកឱ្យខ្ចីត្រូវជាប់ចោទតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមានថែមទៀត ។

**មាត្រា៦១-** ការប្ដឹងទារប្រាក់មុនពេលផុតកំណត់នៃកិច្ចសន្យា មិនអាចធ្វើបានទេ ។ ប៉ុន្តែបើអ្នកជំពាក់បំណុលស្លាប់ ប្រាក់ដែលជំពាក់នោះតំរូវឱ្យទារភ្លាមបាន ហើយទាយាទនៃអ្នកស្លាប់ត្រូវកាត់មរតកសងជាមុនសិនរួចសឹមចែកមរតកជាក្រោយ ។

**មាត្រា៦២-**ដើមបំណុលត្រូវប្រគល់សំបុត្រជំពាក់ រឺសំបុត្របញ្ជាក់អំពីការសងប្រាក់ឱ្យកូនបំណុលនៅពេលកូនបំណុលសងប្រាក់ទៅខ្លួន។

**មាត្រា៦៣-**ការខ្ចីប្រាក់លើទ្រព្យសម្បត្តិចលនវត្ថុឯទៀត ត្រូវត្រិបត្តិតាមបទបញ្ញត្តិកំណត់សំរាប់ការខ្ចីប្រាក់ដែរ។

## ផ្នែកទី៣. ការបញ្ចាំចលនវត្ថុ

**មាត្រា៦៤ -** ការបញ្ចាំចលនវត្ថុជាកិច្ចសន្យាដែលកូនបំណុលយកទ្រព្យសម្បត្តិចលនវត្ថុរបស់ខ្លួនទៅទុកដៃដើមបំណុល ដើម្បីធានាសំណងបំណុល ។

ដើមបំណុលដែលមានចលនវត្ថុនៅក្នុងដៃ មានសិទ្ធិយកប្រាក់សំណងដែលបានមកពីការលក់ចលនវត្ថុបញ្ចាំ មុនដើមបំណុលឯទៀត ។

**មាត្រា៦៥ -** កិច្ចសន្យាបញ្ចាំចលនវត្ថុត្រូវធ្វើជាលាយល័ក្ខអក្សរ ។ ទ្រព្យដាក់ធានា ត្រូវបានប្រគល់ដល់ដៃនៃដើមបំណុល ទើបកិច្ចសន្យានោះទុកជាបានការ ។

កិច្ចសន្យាត្រូវកំណត់ចំនួនទឹកប្រាក់ដែលជំពាក់ និងវត្ថុដែលបញ្ចាំ ឱ្យច្បាស់លាស់ ។

បើកិច្ចសន្យាមិនកំណត់ថាត្រូវមានការប្រាក់ទេ មិនកំណត់ពេលវេលាដែលត្រូវសងទេ បំណុលនោះត្រូវទុកជាឱ្យខ្ចីដោយឥតយកការប្រាក់ក្នុងកំណត់មួយឆ្នាំ គិតពីថ្ងៃចុះកិច្ចសន្យានោះ ។

**មាត្រា៦៦ -** ដើមបំណុលគ្មានសិទ្ធិចាត់ចែងវត្ថុបញ្ចាំតាមទំនើងចិត្តរបស់ខ្លួនបានទេ ។ ដើមបំណុលមានករណីកិច្ចទុកវត្ថុនោះឱ្យគង់វង់ និងថែរក្សាឱ្យបានល្អ ។ ក្នុងករណីដែលវត្ថុបញ្ចាំនោះត្រូវខូចខាត ឬបាត់បង់បណ្តាលមកពីកំហុសរបស់ខ្លួន ដើមបំណុលត្រូវជួសជុលសំណងវត្ថុបញ្ចាំនោះ ។

**មាត្រា៦៧ -** ប្រសិនបើគ្មានកំណត់ក្នុងកិច្ចសន្យាជាលាយល័ក្ខអក្សរច្បាស់លាស់ទេ ដើមបំណុលមិនត្រូវបានអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះទៅប្រើប្រាស់ ឬទាញយកផលប្រយោជន៍ពីវត្ថុបញ្ចាំនោះបានទេ ។ ប៉ុន្តែដើមបំណុលត្រូវបានអនុញ្ញាតិឱ្យទទួលយកផលធម្មជាតិ នៃវត្ថុបញ្ចាំនោះបាន ។ ផលនោះទុកជាអាទិសំរាប់ចំណាយចាំបាច់ទាំងឡាយ ។

ប្រសិនបើដើមបំណុលប្រើវត្ថុបញ្ចាំនោះដោយរំលោភលើកិច្ចសន្យា កូនបំណុលអាចសុំប្តឹងដកវត្ថុបញ្ចាំមកវិញបាន ។

**មាត្រា៦៨ -** ប្រសិនបើដើមបំណុលចាត់ចែងចំណាយវត្ថុបញ្ចាំដោយគ្មានបានទទួលការព្រមព្រៀងជាមុនពីកូនបំណុល នោះដើមបំណុលនឹងត្រូវជាប់ចោទ តាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៦៩ -** កាលណាដល់ថ្ងៃកំណត់ហើយសំណងក៏ត្រូវបានប្រគល់ឱ្យគ្រប់ចំនួនរួចស្រេចនោះ ដើមបំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅម្ចាស់ដើមវិញ ។ បើកូនបំណុលមិនទាន់សងគ្រប់ចំនួនទេ ដើមបំណុលនឹងរក្សាទុកវត្ថុដែលបញ្ចាំនោះបាន ។

**មាត្រា៧០-** ប្រសិនបើដល់ថ្ងៃកំណត់ ហើយកូនបំណុលមិនលោះ ដើមបំណុលអាចទាមទារតាមរយៈតុលាការប្រជាជនឱ្យលក់វត្ថុបញ្ចាំ ។ ប្រាក់ដែលបានមកពីការលក់ ត្រូវសងទៅដើមបំណុលដែលបានទទួលបញ្ចាំវត្ថុនោះ ។ ប្រាក់សល់ពីនោះ ត្រូវប្រគល់ឱ្យកូនបំណុល ឬដើមបំណុលឯទៀតដែលមានបំណុលដល់កំណត់ត្រូវសង ។

បើប្រាក់ថ្លៃលក់វត្ថុនោះមិនគ្រប់គ្រាន់នឹងសងបំណុលដែលបញ្ចាំវត្ថុនោះ កូនបំណុលត្រូវនៅជំពាក់បំណុលដែលនៅសល់ទៅទៀត ។

**មាត្រា៧១-** ត្រូវទុកជាមោឃៈកិច្ចសន្យាទាំងឡាយណាដែលកំណត់ឱ្យដើមបំណុលទៅម្ចាស់កម្មសិទ្ធិនៃវត្ថុបញ្ចាំ ក្នុងករណីដែលកូនបំណុលមិនបានបំពេញកាតព្វកិច្ច ។

## ផ្នែកទី ៤. កិច្ចសន្យាសហគ្រាស

**មាត្រា៧២-** កិច្ចសន្យាសហគ្រាស ជាកិច្ចសន្យាដែលបុគ្គលមួយទទួលបន្ទុកធ្វើការងារអ្វីមួយឱ្យបុគ្គលមួយទៀត ដោយថ្លៃសមស្របនឹងទំហំនៃការងារនោះ ។

**មាត្រា៧៣-** ប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យា តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំលាប់នៃកន្លែងធ្វើការនោះ ។

**មាត្រា៧៤-** ការងារត្រូវធ្វើឱ្យត្រឹមត្រូវតាមកិច្ចសន្យា ។ បើការងារដែលបានធ្វើនោះ មិនត្រូវតាមកំណត់ដែលមានចែងក្នុងកិច្ចសន្យាទេ អ្នកជួលអាច :

ក- ឬមួយមិនព្រមទទួលយកការងារនោះ ហើយក្នុងករណីនេះកិច្ចសន្យាអាចរំលាយបានដោយតំរូវឱ្យអ្នកទទួលធ្វើបង់ជំងឺចិត្ត និងសងសំណងបង់ខាតផ្សេងៗ ប្រសិនបើមានទៅឱ្យអ្នកជួល ។

ខ- ឬមួយតំរូវឱ្យធ្វើការកែប្រែចាំបាច់ក្នុងរយៈពេលកំណត់តាមការព្រមព្រៀងនៃគូភាគី ដោយអ្នកទទួលធ្វើចេញប្រាក់ផ្ទាល់ខ្លួន ដើម្បីសំរួលតាមការកំនត់នៃកិច្ចសន្យាវិញ ។

គ- ឬមួយព្រមទទួលយកការនោះ ដោយបញ្ចុះថ្លៃ ។

**មាត្រា៧៥-** ប្រសិនបើកិច្ចសន្យាកំណត់រយៈពេល ដែលការងារត្រូវតែធ្វើឱ្យហើយក្នុងពេលណាមួយ ហើយបើការនោះធ្វើមិនហើយតាមពេលកំណត់ កិច្ចសន្យាអាចលប់ចោលវិញដោយពុំទាន់គិតដល់ជំងឺចិត្តដែលអ្នកជួលអាចទាមទារបាន ។

ប៉ុន្តែប្រសិនបើការយឺតយ៉ាវបណ្តាលមកពីប្រធានសក្តិ នោះជួលពុំអាចទាមទារជំងឺចិត្តបានឡើយ ។

**មាត្រា៧៦-** ស្រិនបើអ្នកជួលបានសន្យាថានឹងបើកប្រាក់ឱ្យមុនខ្លះ ឬវត្ថុធាតុដើមខ្លះឱ្យទាន់ពេលវេលា ហើយមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា នោះអ្នកជួលពុំអាចលើកយកការយឺតយ៉ាវក្នុងការអនុវត្តការងារ

មកសំអាងដើម្បីបញ្ឈប់កិច្ចសន្យានោះបានឡើយ ។

អ្នកទទួលធ្វើអាចសំអាងលើការខូចខាតពេលវេលារង់ចាំសំភារៈយូរ ដើម្បីលប់កិច្ចសន្យា ។ ក្នុងករណីនេះ អ្នកទទួលធ្វើត្រូវបានទទួលឈ្នួលសមស្របតាមការងារដែលខ្លួនបានធ្វើហើយ ។

__មាត្រា៧៧ -__ អ្នកជួលអាចលប់ចោលកិច្ចសន្យាបានជានិច្ច នៅមុនពេលការងារធ្វើហើយជាស្ថាពរ ប៉ុន្តែត្រូវគិតថ្លៃការងារដែលបានធ្វើ គិតចំណាយផ្សេងៗ និងជំងឺចិត្តទៅឱ្យអ្នកទទួលធ្វើ ។

__មាត្រា៧៨ -__ បើការងាត្រូវអន្តរាយមុនពេលធ្វើរួច ដោយកំហុសនៃអ្នកទទួលធ្វើ ហើយអ្នកជួលបានបើកប្រាក់ឱ្យមុន និងផ្តល់វត្ថុធាតុដើមឱ្យទៀត នោះអ្នកជួលមានសិទ្ធិទារសំណងស្មើនឹងការ ជូសជុលអន្តរាយបណ្តាលមកពីការបាត់វត្ថុ និងចំណាយផ្សេងៗដែលខ្លួនបានចាយក្នុងការធ្វើនោះ ។ ប៉ុន្តែបើការខូចខាតបណ្តាលមកពីករណីប្រធានសក្តិ ភាគីនៃកិច្ចសន្យាត្រូវទទួលផលវិបាក ដោយពុំអាចប្តឹងទាមទារពីគ្នាបានឡើយ ។

**មាត្រា៧៩ -** អ្នកទទួលធ្វើការងារនោះ ត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណី ចំពោះជនដែលខ្លួនប្រើធ្វើការងារនោះ ។

__មាត្រា៨០ -__ កាលបើការងារសំរេចបានហើយ អ្នកទទួលធ្វើការអាចទារថ្លៃនៅពេលប្រគល់ការងារបាន ។ ការប្រគល់ថ្លៃការងារ ទុកជាការព្រមទទួលយកការងារដែលធ្វើរួច ។

__មាត្រា៨១ -__ កាលបើក្រោយពីបានប្រគល់ការងារមក គុណវិបត្តិ និងវិការៈដ៏កំបាំងណាមួយបានផុសឡើងបណ្តាលមកពីកំហុសអ្នកទទួលធ្វើក្នុងពេលដែលធ្វើការងារនោះ កិច្ចសន្យាត្រូវតែរំលាយចោល ឬត្រូវបង្វិលថ្លៃឈ្នួលខ្លះមកឱ្យអ្នកជួលវិញ ឬក៏ការងារនោះត្រូវជួលជុលដោយបង់ខាតនៃអ្នកទទួលធ្វើ ។

អ្នកជួសអាចប្តឹងបានតែក្នុងករណីដែលវិការៈនោះ លេចឡើងក្នុងរយៈពេលដែលអ្នកទទួលធ្វើរ៉ាប់រងទទួលខុសត្រូវដូចមានចែងក្នុងកិច្ចសន្យា ។ បើគ្មានចែងអំពីរយៈពេលរ៉ាប់រងទទួលខុសត្រូវក្នុងកិច្ចសន្យាទេ អ្នកជួលអាចប្តឹងបានក្នុងរយៈពេល ៣ ឆ្នាំ គិតពីថ្ងៃដែលបានទទួលការងារនោះមក ។

__មាត្រា៨២ -__ ចំពោះរូបវន្តបុគ្គល បើអ្នកទទួលធ្វើស្លាប់ កិច្ចសន្យានោះត្រូវរលាយ ។

## ផ្នែកទី ៥_ កិច្ចសន្យាដឹកជញ្ជូន

__មាត្រា៨៣ -__ កិច្ចសន្យាដឹកជញ្ជូន ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូនសន្យាដឹកអ្នកដំណើរ ភារៈវត្ថុ ឬទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត ដោយយកថ្លៃតាមការព្រមព្រៀង ឬតាមថ្លៃកំណត់របស់រដ្ឋ ។

__មាត្រា៨៤ -__ កាលណាអ្នកដឹកជញ្ជូនយឺតយ៉ាវក្នុងការប្រគល់យានដឹកជញ្ជូន អ្នកបញ្ជូនមានសិទ្ធិបញ្ឈប់កិច្ចសន្យាហើយតំរូវ :

- ឱ្យសងប្រាក់ចំណាយក្នុងការលើកដាក់ និងប្រាក់ដែលបានបង់រួចហើយទៅឱ្យអ្នកដឹកជញ្ជូនផ្សេងទៀត ។

- ឱ្យសងជួសជុលអន្តរាយ បណ្តាលមកពីការយឺតយ៉ាវ "ករណីបាត់ ឬខូចសំភារៈវត្ថុ ឬទំនិញដែលត្រូវដឹកជញ្ជូន ឬការចុះតំលៃ បណ្តាលមកពីការយឺតយ៉ាវ ។

__មាត្រា៨៥-__ កាលណាអ្នកបញ្ជូនយឺតយ៉ាវក្នុងការលើកដាក់ភារៈវត្ថុ ឬទំនិញ អ្នកដឹកជញ្ជូនមានសិទ្ធិតំរូវឱ្យជួសជុលការខាតបង់ និងបញ្ឈប់កិច្ចសន្យា ។

__មាត្រា៨៦-__ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវអំពីការបាត់បង់ ឬការខូចខាតលើវត្ថុដឹកជញ្ជូន ។ អ្នកដឹកជញ្ជូនក៏ត្រូវទទួលខុសត្រូវអំពីគ្រោះថ្នាក់ដែលបណ្តាលឡើងដល់អ្នកដំណើរ ក្នុងពេលដែលខ្លួនដឹកជញ្ជូនដែរ ។

អ្នកដឹកជញ្ជូនត្រូវបានរួចខ្លួនពីការទទួលខុសត្រូវខាងលើ ក្នុងករណីប្រធានសក្តិ ឬក្នុងករណីអ្នកដំណើរត្រូវរងគ្រោះ ដោយមកពីការធ្វេសប្រហែសរបស់ខ្លួន ។

បើភារៈវត្ថុ ឬទំនិញដែលត្រូវគេប្រគល់ឱ្យដឹកជញ្ជូនអន្តរាយដោយចោរកម្ម អ្នកដឹកជញ្ជូនត្រូវជួសជុលសំណងនៃភារៈវត្ថុ ឬទំនិញនោះ ។

__មាត្រា៨៧-__ អ្នកដឹកជញ្ជូនត្រូវធានាអំពីការខូចខាតលើវត្ថុ ប្រសិនបើការខូចខាតនោះមិនមែនបណ្តាលមកពីករណីប្រធានសក្តិ ឬវិបត្តិផ្ទាល់នៃវត្ថុនោះ ។ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវជាពិសេសចំពោះការបាត់បង់ ឬការខូចខាត បណ្តាលមកពីការយឺតយ៉ាវដោយគ្មានមូលហេតុសមស្របនៅពេលដឹកជញ្ជូន ។

__មាត្រា៨៨-__ បណ្តឹងសុំជួសជុលការខូចខាត ត្រូវធ្វើក្នុងរយះពេល ១ ឆ្នាំ គិតពីថ្ងៃដែលម្ចាស់របស់បានដឹងថា បាត់ ឬខូចខាត ឬគិតពីថ្ងៃដែលអ្នកដំណើរបានទទួលរងគ្រោះ ។

## __ផ្នែកទី ៦. កិច្ចសន្យានៃការផ្ញើទុក__

__មាត្រា៨៩-__ កិច្ចសន្យានៃការផ្ញើទុក ជាកិច្ចសន្យាដែលជនម្នាក់ផ្ញើចលនវត្ថុណាមួយនឹងជនម្នាក់ទៀតឱ្យរក្សាទុក ដោយឥតយកឈ្នួល ឬយកឈ្នួល ហើយឱ្យប្រគល់វត្ថុនោះទៅជនដែលយកមកផ្ញើនោះវិញ ឬប្រគល់ឱ្យជនណាដែលអ្នកផ្ញើប្រាប់ឈ្មោះមកយ៉ាងច្បាស់ តាមពេលដែលសម្មត់ ឬនៅពេលដែលទារយកវត្ថុនោះវិញ ។

__មាត្រា៩០-__ តាមគោលការណ៍ បើកិច្ចសន្យាមិនបានចែងអំពីឈ្នួលទេ អ្នកទទួលបញ្ញើមិនត្រូវបានឈ្នួលឡើយ ។

__មាត្រា៩១-__ អ្នកទទួលបញ្ញើ ត្រូវរក្សាបញ្ញើឱ្យគង់វង់ ហើយត្រូវប្រគល់ឱ្យវិញនៅពេលដែលបានសន្មត់ ឬនៅពេលដែលអ្នកផ្ញើមកយក ។

អ្នកទទួលបញ្ញើ គ្មានសិទ្ធិយកបញ្ញើទៅប្រើប្រាស់ទេ បើគ្មានការអនុញ្ញាតពីអ្នកផ្ញើ ។

**មាត្រា៩២ -** អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវលើការខូចខាត ឬការបាត់បង់នៃបញ្ញើដែលបានកើតឡើងដោយកំហុសរបស់ខ្លួន ។

បើបញ្ញើអន្តរាយ ឬបាត់ដោយករណីប្រធានសក្តិ អ្នកទទួលខុសត្រូវមិនត្រូវសងទេ ។

**មាត្រា៩៣ -** បើផ្ញើមានឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើត្រូវសង ។

បើផ្ញើឥតឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើមិនត្រូវសងទេ ប្រសិនបើអ្នកទទួលបញ្ញើមានភស្តុតាងបញ្ជាក់ថា ខ្លួនមានការប្រុងប្រយ័ត្នដែរក្នុងការរក្សាបញ្ញើនោះ ។

ប៉ុន្តែម្ចាស់សណ្ឋាគារ ម្ចាស់ទៀម ម្ចាស់ភោជនាគារ ត្រូវទទួលសងទ្រព្យរបស់ជនទាំងឡាយ ដែលមកស្នាក់អាស្រ័យក្នុងគ្រឹះស្ថានរបស់ខ្លួន បានផ្ញើទ្រព្យនោះក្នុងគ្រឹះស្ថានរបស់ខ្លួន ហើយអន្តរាយដោយចោរកម្ម ។

## ផ្នែកទី ៧- កិច្ចសន្យានៃការឱ្យខ្ចីប្រើ

**មាត្រា៩៤ -** ការឱ្យខ្ចីប្រើ គឺគ្មានយកការប្រាក់ ឬការយកឈ្នួលអ្វីទេ ។ អ្នកដែលឱ្យវត្ថុណាមួយទៅគេខ្ចីប្រើនៅតែជាកម្មសិទ្ធិករនៃវត្ថុនោះដដែល ។

**មាត្រា៩៥ -** អ្នកខ្ចីមិនអាចលក់ ឬដូរវត្ថុ ឬឱ្យវត្ថុនោះទៅតតិយជនខ្ចីប្រើដោយគ្មានការព្រមព្រៀងពីអ្នកឱ្យខ្ចីបានឡើយ ។

**មាត្រា៩៦ -** អ្នកខ្ចីត្រូវប្រើប្រាស់វត្ថុនោះឱ្យល្អ ថែទាំបីដូចខ្លួនជាម្ចាស់វត្ថុ និងប្រើឱ្យសមស្របនឹងមុខការរបស់វា ។

**មាត្រា៩៧ -** បើវត្ថុនោះខូចខាត ឬបាត់ដោយករណីប្រធានសក្តិ អ្នកខ្ចីមិនត្រូវទទួលសងឡើយ ប៉ុន្តែបើការខូចខាត ឬការបាត់បណ្តាលមកពីកំហុសរបស់ខ្លួន អ្នកខ្ចីត្រូវទទួលសងតំលៃវត្ថុទៅឱ្យអ្នកឱ្យខ្ចី ។

**មាត្រា៩៨ -** អ្នកខ្ចីត្រូវប្រគល់វត្ថុទៅឱ្យម្ចាស់វត្ថុវិញ នៅពេលដែលបានកំណត់ ។ បើកិច្ចសន្យាគ្មានបានកំណត់យ៉ាងណាទេ អ្នកឱ្យខ្ចីអាចទារយកវត្ថុរបស់ខ្លួនវិញក្នុងពេលណាក៏បាន ។

**មាត្រា៩៩ -** បើអ្នកខ្ចីយកវត្ថុទៅប្រើការក្រៅពីមុខការរបស់វា អ្នកឱ្យខ្ចីអាចទារវត្ថុរបស់ខ្លួនភ្លាមវិញបាន ថ្វីបើមិនទាន់ដល់រយៈពេលកំណត់ ។

## ផ្នែកទី ៨- កិច្ចសន្យានៃការជួល

**មាត្រា១០០ -** ការជួលជាកិច្ចសន្យាដែលអ្នកជួលសន្យាថា និងផ្តល់ទៅឱ្យអ្នកទទួលជួលនៅវត្ថុណាមួយដើម្បីប្រើប្រាស់ជាបណ្តោះអាសន្ន ដោយតំរូវឱ្យគិតថ្លៃនៃការជួលវត្ថុនោះឱ្យអ្នកជួល ។

វត្ថុដែលអាចជួលបាននោះ គឺវត្ថុ ជាអចលនវត្ថុ ឬជាចលនវត្ថុ ។

**<u>មាត្រា១០១-</u>** កិច្ចសន្យានៃការជួល អាចកំណត់ ឬមិនកំណត់ក៏បាននូវរយៈពេលនៃការជួល ក្នុងករណីដែលគ្មានកំណត់រយៈពេលនៃការជួល ចិរវេលានៃកិច្ចសន្យាមានកំណត់ ១២ ឆ្នាំ យ៉ាងយូរ ។

កិច្ចសន្យានៃការជួលដែលមានកំណត់លើសពី ១ ឆ្នាំ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**<u>មាត្រា១០២-</u>** កាលបើកិច្ចសន្យានៃការជួលបានធ្វើដោយគ្មានសំបុត្រស្នាម ហើយប្រសិនបើភាគីម្ខាងប្រកែកបន្ទាល់នៃការជួលនេះនឹងសំអាងសាក្សីមកបញ្ជាក់បាន លុះណាតែកិច្ចសន្យានៃការជួលនោះ មានកំណត់ត្រឹមតែ ១ ឆ្នាំ ប៉ុណ្ណោះ ។

**<u>មាត្រា១០៣-</u>** អ្នកជួលត្រូវប្រគល់វត្ថុដែលមានភាពនៅល្អឱ្យទៅអ្នកទទួលជួល ត្រូវជៀសវាងនូវអំពើទាំងពួងដែលនាំឱ្យរំខានដល់អ្នកទទួលជួល ហើយត្រូវរ៉ាប់រងដល់អ្នកទទួលជួលអំពីការរំខានទាំងឡាយដែលបណ្តាលមកពីតតិយជនដែលទាមទារសិទ្ធិណាមួយលើវត្ថុជួលនោះ ដូចជាកម្មសិទ្ធិ ការបញ្ចាំជាដើម ។

**<u>មាត្រា១០៤-</u>** អ្នកជួល ត្រូវទទួលបន្ទុកនូវការជួសជុលធំៗចំពោះវត្ថុជួល លើកលែងតែច្បាប់ ឬកិច្ចសន្យាចែងផ្សេងពីនេះ ។

**<u>មាត្រា១០៥-</u>** អ្នកទទួលត្រូវបង់ប្រាក់ថ្លៃឈ្នួលតាមការកំណត់ ត្រូវប្រើប្រាស់វត្ថុជួលឱ្យសមស្របនឹងមុខការនៃវត្ថុជួល និងតាមការកំណត់នៃកច្ចសន្យា ត្រូវថែទាំវត្ថុនោះឱ្យបានគង់វង្ស ត្រូវទទួលបន្ទុកនូវការជួសជួលបន្តិចបន្តួចដែលជាការជួសជុលជាធម្មតា លើកលែងតែច្បាប់ ឬកិច្ចសន្យាចែងផ្សេងពីនេះ ។

**<u>មាត្រា១០៦-</u>** នៅពេលចប់កិច្ចសន្យា អ្នកទទួលជួលត្រូវប្រគល់ទៅឱ្យអ្នកជួលវិញនូវវត្ថុជួលដែលត្រូវនៅមានសភាពល្អ គឺគ្មានការបាក់បែក គ្មានការខូចខាត ឬគ្មានការកែប្រែនៃវត្ថុនោះដែលបណ្តាលមកពីអំពើនៃអ្នកទទួលជួល ។

**<u>មាត្រា១០៧-</u>** អ្នកជួលអាចរំលាយកិច្ចសន្យានៃការជួលបាន ប្រសិនបើអ្នកទទួលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬក៏យកវត្ថុជួលនោះទៅប្រើប្រាស់ខុសអំពីការដែលត្រូវប្រើ ឬក៏ប្រើក្នុងការដែលនាំឱ្យអន្តរាយដល់វត្ថុនោះ ។

**<u>មាត្រា១០៨-</u>** អ្នកទទួលជួលមិនអាចជួលវត្ថុបន្តឱ្យទៅអ្នកដទៃ ដោយគ្មានការអនុញ្ញាតិពីអ្នកជួលឡើយលើកលែងតែកិច្ចសន្យាចែងផ្ទុយពីនេះ ។

**<u>មាត្រា១០៩-</u>** អ្នកទទួលជួលដែលបានជួលវត្ថុបន្ត ត្រូវនៅជាប់កាតព្វកិច្ចជាមួយនឹងអ្នកជួលដដែល ជាអាទិអ្នកទទួលជួលត្រូវទទួលខុសត្រូវលើអ្នកទទួលជួលពីខ្លួន ចំពោះការមិនបង់ប្រាក់ថ្លៃឈ្នួល ការបែកបាក់ការខូចខាតទាំងឡាយនៃវត្ថុជួល ដែលបណ្តាលមកពីអំពើរបស់អ្នកទទួលជួលបន្ត ។

**<u>មាត្រា១១០-</u>** ចំពោះកិច្ចសន្យានៃការជួលសំរាប់ចិរវេលាគ្មានកំណត់ គូភាគីអាចនឹងរំលាយបាន លុះណាតែមានការឱ្យតំណឹងមុន ១ ខែ យ៉ាងតិច ឬ ២ ខែ យ៉ាងយូរ ។

**<u>មាត្រា១១១-</u>** ទោះអ្នកជួលស្លាប់ក្តី ក៏កិច្ចសន្យានៃការជួល ត្រូវតែអនុវត្តតទៅទៀត ។

បើអ្នកទទួលជួលស្លាប់វិញ កិច្ចសន្យានៃការជួលនឹងលែងយកមកអនុវត្តបាន លុះណាតែទាយាទលែងចង់ជួលតទៅទៀត ។

## <u>ផ្នែកទី ៩. កិច្ចធានាដោយបុគ្គល</u>

**<u>មាត្រា១១២-</u>** កិច្ចធានាដោយបុគ្គល ជាកិច្ចសន្យាមួយដែលតតីយជនម្នាក់ហៅថា អ្នកធានាសន្យានឹងដើមបំណុលថា ខ្លួនទទួលបំពេញកាតព្វកិច្ចរបស់កូនបំណុលជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះដើមបំណុល ។ កិច្ចសន្យានេះ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**<u>មាត្រា១១៣-</u>** បំណុលតែមួយ អាចមានអ្នកធានាច្រើនបាន ។

**<u>មាត្រា១១៤-</u>** កិច្ចធានាណាមួយចែងអំពីកាតព្វកិច្ចដែលច្បាប់ទុកជាមោឃៈ កិច្ចធានានោះទុកជាអសាបង់ ។ ប៉ុន្តែបើមោឃភាពនោះមានមូលហេតុមកពី កូនបំណុលជាអនិតិជន កិច្ចធាននោះនៅទុកជាបានការដដែល ។

**<u>មាត្រា១១៥-</u>** ដើមបំណុលអាចប្តឹងពីអ្នកធានាដំណាលគ្នានឹងប្តឹងកូនបំណុលក៏បាន ឬប្តឹងក្រោយក៏បាន ។

**<u>មាត្រា១១៦-</u>** ក្រោយពីមានសាលក្រមរបស់តុលាការប្រជាជន អ្នកធានាអាចទាមទារឱ្យដើមបំណុលអូសទ្រព្យរបសលកូនបំណុលលក់មុនសិន រួចសឹមសំរេចអូសទ្រព្យរបស់ខ្លួនជាក្រោយបាន ។

**<u>មាត្រា១១៧-</u>** បើលក់ទ្រព្យរបស់នៃកូនបំណុលទៅហើយ បានប្រាក់មិនគ្រាន់នឹងសងបំណុលទាំងអស់ទេ អ្នកធានាត្រូវនៅជំពាក់ប្រាក់ដែលនៅខ្វះ ។

**<u>មាត្រា១១៨-</u>** ក្នុងករណីដែលមានអ្នកធានាច្រើននាក់ នោះអ្នកធានាម្នាក់ៗត្រូវជាប់ធានាបំណុលទាំងមូលហាក់ដូចជាអ្នកធានាមានតែម្នាក់ ។ អ្នកធានាទាំងអស់ត្រូវរួបរួមគ្នាសងបំណុលនោះ ។

**<u>មាត្រា១១៩-</u>** បើអ្នកធានាបានសងប្រាក់ជូសកូនបំណុលដែលខ្លួនធានាហើយ សិទ្ធិទាំងប៉ុន្មាននៃដើមបំណុលត្រូវបានទៅអ្នកធានាទាំងអស់ ។ អ្នកធានាមានសិទ្ធិទារឱ្យកូនបំណុលសងប្រាក់ដែលខ្លួនបានសងជូសមកវិញ ព្រមទាំងការប្រាក់ និងសោហ៊ុយបង់ខាតតាំងពីថ្ងៃដែលខ្លួនបានសងជំនួស ។

**<u>មាត្រា១២០-</u>** កាលបើមានអ្នកធានាម្នាក់បានចេញប្រាក់សងជំនួលកូនបំណុល អ្នកធានានោះអាចប្តឹងទារសំណងបានពីអ្នកធានាដទៃទៀតដែលត្រូវសងតាមចំណែករៀងៗខ្លួន ក្នុងករណីកូនបំណុលស្ថិតនៅក្នុងអសាធនភាព ។

# <u>ជំពូកទី៣</u>

## <u>អំពីការទទួលខុសត្រូវក្រៅកិច្ចសន្យា</u>

**<u>មាត្រា១២១-</u>** ជនណាបានធ្វើឱ្យមានការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួន ជននោះត្រូវជួសជុលការខូចខាតនោះ ។

ទោះបីការខុចខាតកើតមកអំពីអំពើប្រព្រឹត្តិដោយចេតនា ដូចជាការធ្វេសប្រហែស ឬការខ្វះការប្រុងប្រយ័ត្នក្នុងការត្រួតមើល ថែទាំក៏ដោយ ក៏ជនល្មើសត្រូវតែជួសជុលការខូចខាតនោះដែរ ។

**<u>មាត្រា១២២-</u>** ជនវិកលចរិក និងអនិតិជនអាយុតិចជាង ១៤ ឆ្នាំ ជាអសមត្ថជន ។ ជនទាំងនោះមិនត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលខ្លួនបានធ្វើឱ្យកើតឡើងដល់អ្នកដទៃឡើយ ។

**<u>មាត្រា១២៣-</u>** ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ព្រមទាំងជនផ្សេងៗទៀតដែលទទួលបន្ទុកត្រូវមើលថែទាំអសមត្ថជន ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះការខូចខាត ដែលអសមត្ថជននោះបានធ្វើឱ្យកើតឡើង ។

**<u>មាត្រា១២៤-</u>** អនីតិជនអាយុច្រើនជាង ១៤ ឆ្នាំ ប៉ុន្តែមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ ត្រូវទទួលការខុសត្រូវចំពោះការខូចខាតដែលខ្លួនបានធ្វើដល់អ្នកដទៃ ។ ការជួសជុលការខូចខាត ត្រូវអនីតិជននោះ និងឪពុកម្តាយ ឬអ្នកអណាព្យាបាលនៃអនីតិជននោះទទួលខុសត្រូវរួម ។ ក្នុងករណីដែលអនីតិជននេះគ្មានប្រាក់ ឬទ្រព្យសម្បត្តិដើម្បីជួសជុលការខូចខាតនោះឪពុកម្តាយ ឬអ្នកអាណាព្យាបាល ត្រូវសងជួស ។

**<u>មាត្រា១២៥-</u>** អង្គការរដ្ឋ អង្គការសង្គម អង្គការសមូហភាព សហគ្រាស ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកម្មាភិបាល បុគ្គលិក កម្មកររបស់ខ្លួន បានធ្វើឱ្យកើតឡើងក្នុងពេល ឬពេលបំពេញភារកិច្ច របស់ជនទាំងនោះ ។

**<u>មាត្រា១២៦-</u>** និយោជក ត្រូវទទួលការខុសត្រូវចំពោះការខូចខាតដល់អ្នកដទៃ បណ្តាលមកពីនិយោជករបស់ខ្លួនក្នុងពេល ឬនៅពេលអនុវត្តការងារដែលនិយោជកបានប្រគល់ឱ្យធ្វើ ។

មាត្រា១២៧- កម្មសិទ្ធិករនៃសត្វ ឬជនដែលប្រើសត្វ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសារសត្វដែលនៅក្នុងការគ្រប់គ្រងរបស់ខ្លួន ទោះអន្តរាយនោះកើតឡើងនៅពេលសត្វរត់រួចក្តី ឬនៅពេលសត្វវង្វេងខ្ចាត់ភ្លាត់ក្តី ។

**<u>មាត្រា១២៨-</u>** កម្មសិទ្ធិករ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃដោយសារទ្រព្យរបស់ខ្លួន ប្រសិនបើការខូចខាតនោះបណ្តាលមកពីការខ្វះខាតថែទាំ ខ្វះការត្រួតពិនិត្យ ឬក៏ដោយសារសំណង់របស់ខ្លួនសង់មិនបានត្រឹមត្រូវល្អ ។

**មាត្រា១២៩ -** ប្រសិនបើការខូចខាតបណ្តាលមកពីជនប្រព្រឹត្តិបទល្មើសច្រើននាក់ ជនទាំងនោះត្រូវទទួលខុសត្រូវរួមចំពោះជនរងគ្រោះ ។ ក្នុងករណីខ្លះតុលាការប្រជាជនអាចសំរេចសេចក្តីឱ្យបុគ្គលម្នាក់ៗដែលបានធ្វើឱ្យមានការខូចខាត សងទៅជនរងគ្រោះតាមសមាមាត្រនៃការចូលរួម ប្រព្រឹត្តរបស់ខ្លួន ។

**មាត្រា១៣០ -** ជនដែលទទួលខុសត្រូវរួមជាមួយអ្នកទទួលខុសត្រូវឯទៀត ហើយបានសងជំងឺសជនទាំងនេះ ជននោះដែលមានសិទ្ធិទាមទារឱ្យជនដែលទទួលខុសត្រូវឯទៀតសងមកខ្លួនវិញ ដោយគិតទៅតាមកំរិតនៃអំពើប្រព្រឹត្តដែលម្នាក់ៗបានប្រព្រឹត្ត ។

**មាត្រា១៣១ -** អង្គការ ឬជនដែលបានទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីកំហុសរបស់ជនម្នាក់ទៀត អង្គការ ឬជននោះមានសិទ្ធិប្តឹងទារសំណងពីជនខាងក្រោយនេះវិញ ។

**មាត្រា១៣២ -** ក្នុងករណីដែលការខូចខាត បណ្តាលមកពីកំហុសរបស់ជនរងគ្រោះផងដែលនោះ ជនរងគ្រោះត្រូវទទួលខុសត្រូវចំពោះចំណែកនៃការខូចខាតនោះ ។

**មាត្រា១៣៣ -** ជនដែលធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ និងអាចឱ្យរួចខ្លួនពីការទទួលខុសត្រូវបានប្រសិនបើ :

១. ការខូចខាតបានកើតឡើងក្នុងករណីប្រធានសក្តិ ។

២. ការខូចខាតបណ្តាលមកពីកំហុសទាំងស្រុងរបស់ជនរងគ្រោះ ។

**មាត្រា១៣៤ -** ប្រសិនបើការខូចខាតបានកើតឡើងដោយមានការព្រមព្រៀងពីជនរងគ្រោះ ហើយអំពើនោះគ្មានប៉ះពាល់ ឬគំរាមកំហែងដល់ប្រយោជន៍សង្គមទេ នោះមិនត្រូវឱ្យមានការជួសជុលសំណងនៃការខូចខាត ឡើយ ។

**មាត្រា១៣៥ -** បណ្តឹងសុំជួសជុលសំណងនៃការខូចខាត មានអាជ្ញាយុកាលកំណត់ ៣ ឆ្នាំ ។

## ជំពូកទី៤

### អំពីបទបញ្ញត្តិអវសាន

**មាត្រា១៣៦ -** កិច្ចសន្យាទាំងឡាយណាដែលកើតឡើងមិនក្រិត្យ-ច្បាប់ ហើយមិនអាចដោះស្រាយតាមក្រឹត្យ-ច្បាប់នេះបាន នោះត្រូវដោះស្រាយតាមគោលនយោបាយរបស់បក្ស និងរដ្ឋតាមសមធម៌ ឬតាមទំនៀមទំលាប់និងប្រពៃណី ។

ដំណោះស្រាយនៃកិច្ចសន្យាខាងលើនេះមានកំនត់ ៥ ឆ្នាំ គិតពីថ្ងៃដែលក្រឹត្យ-ច្បាប់នេះចូលជាធរមាន ។

**មាត្រា១៣៧ -** ក្រុមប្រឹក្សារដ្ឋមន្ត្រី តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យ-ច្បាប់នេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា១៣៤-** ក្រឹត្យ-ច្បាប់នេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨
ជ. ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និងត្រា : ហេង សំរិន

ទទួលបន្ទុកអនុវត្ត
ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា : ហ៊ុន សែន

ដើម្បីចំលងចែក
អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ
ហត្ថលេខា និងត្រា : ចាន់ វ៉ែន

---

ក្រសួងយុត្តធម៌
លេខ : ............................

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ១៩៩៥
អនុប្រធានមន្ទីរ